អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

អូឌីស៊ី៖ ២០២៤/៣៣៥....

**សូមគោរពជូន**

**ឯកឧត្តម សាយ សំអាល់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ៖** ស្នើសុំបញ្ចូលធាតុចូលក្នុងសេចក្តីព្រាងច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា

**យោង៖** លិខិតលេខ ០៣៣ ជសន/ក.ក.ច ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ស្តីពីការអនុវត្តគោលការណែនាំអំពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

យោងតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ហៅកាត់ថាអូឌីស៊ី) បានទទួល សេចក្តីព្រាងច្បាប់ភូមិបាល ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤។

អង្គការអូឌីស៊ី បាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេសមកពី គំនិតផ្តួចផ្តើម Advancing Land-based Investment Governance (ALIGN) (អនុវត្តដោយវិទ្យាស្ថានអន្តរជាតិសម្រាប់បរិស្ថាន និងការអភិវឌ្ឍ (IIED) និងមជ្ឈមណ្ឌល Columbia Center on Sustainable Investment (CCSI) ក៏ដូចជាអង្គការ LANDESA ។ ក្នុងរយៈពេលដែលមានកំណត់ យើងបានពិនិត្យយ៉ាងយកចិត្តទុកដាក់លើសេចក្តីព្រាងច្បាប់ភូមិបាល និងបានរៀបចំកិច្ចពិភាក្សា ពិគ្រោះយោបល់ចំនួនពីរ នៅខេត្តសៀមរាប នាថ្ងៃទី១៣-១៤ ខែកុម្ភៈ និងរាជធានីភ្នំពេញនាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីប្រមូលធាតុចូលទៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាល។

តំណាងសហគមន៍ជនជាតិដើមភាគតិចក៏បានចូលរួមសិក្ខាសាលានេះផងដែរ ប៉ុន្តែពួកគេ បានសម្តែងការព្រួយបារម្ភអំពីរយៈពេលមានកំណត់សម្រាប់ឈ្វេងយល់ពីការផ្លាស់ប្តូរដែលបានស្នើឡើង ប្រាប់នូវចំណុចទាំងនោះទៅកាន់សហគមន៍ និងការប្រមូលធាតុចូលហើយជឿថាសិក្ខាសាលានេះគឺជា ការផ្តល់ព័ត៌មានជាជាងការពិគ្រោះយោបល់។ ដូច្នេះ សហគមន៍ជនជាតិដើមភាគតិច មិនអាចផ្តល់ ធាតុចូលរបស់ពួកគេទៅក្នុង សេចក្តីព្រាងច្បាប់ភូមិបាលបានទេ។ អង្គការអូឌីស៊ី និងក្រុមការងារចែករំលែកក្តីបារម្ភអំពីពេលវេលាមានកំណត់ ដើម្បីផ្តល់ធាតុចូលរបស់យើង។

ក្នុងបរិបទនេះ អង្គការអូឌីស៊ី និងក្រុមការងារសូមស្នើចំណុច និងអនុសាសន៍សំខាន់ៗ ខាងក្រោមជូនចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី៖**

អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

# យោបល់លើចំណុចសំខាន់ៗ

**១. ផ្តល់បន្ថែមពេលវេលា និងដំណើរការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងច្បាប់៖** តំណាងអង្គការសង្គម ស៊ីវិល និងសហគមន៍ជនជាតិដើមភាគតិច ស្នើសុំរដ្ឋាភិបាលឱ្យផ្តល់ពេល ៣ ទៅ ៦ខែ សម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងយ៉ាងហោចណាស់ឱ្យមានការពិគ្រោះយោបល់ពីរជុំ ដោយជុំទីមួយសម្រាប់ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់បច្ចុប្បន្ន និងមួយជុំទៀតសម្រាប់ការពិគ្រោះយោបល់លើអត្ថបទកែសម្រួលនៃសេចក្តីព្រាងច្បាប់ បន្ទាប់ពីរដ្ឋាភិបាល (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) បានពិចារណា និងឆ្លើយតបចំពោះមតិរបស់សាធារណជនដែលបានផ្តល់ក្នុងជុំទីមួយ។ គួរបញ្ជាក់ដែរថា តំណាងសហគមន៍ជនជាតិដើមភាគតិច បានបដិសេធក្នុងការផ្តល់យោបល់ជាក់លាក់ណាមួយលើសេចក្តីព្រាងច្បាប់បច្ចុប្បន្ននោះ លុះត្រាតែពួកគាត់ទទួលបានពេលវេលា និងការគាំទ្រគ្រប់គ្រាន់សម្រាប់ធ្វើការពិនិត្យ និងស្វែងយល់អំពីបទប្បញ្ញត្តិទាំងឡាយដែលប៉ះពាល់ដល់សិទ្ធិដីធ្លីរបស់ពួកគាត់។

**២. បន្តការពិគ្រោះយោបល់ជាសាធារណៈសម្រាប់ច្បាប់នេះ និងអនុក្រឹត្យពាក់ព័ន្ធ៖** ក្នុងការកែសម្រួលច្បាប់ភូមិបាលនេះ ត្រូវការពេលវេលាបន្ថែមទៀតក្នុងការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយអត្ថន័យ ស្របតាមទម្លាប់អនុវត្តល្អជាអន្តរជាតិ។ ខណៈពេលតួអង្គសង្គមស៊ីវិលមួយចំនួន អាចមានលទ្ធភាពមួយកម្រិតក្នុងការពិនិត្យមើលលើសេចក្តីព្រាងច្បាប់ភូមិបាលនេះ ជាការសំខាន់ណាស់ដែលត្រូវបន្ត និងពង្រីកអភិក្រមនៃការពិគ្រោះយោបល់នេះ ដើម្បីរួមបញ្ចូលនូវ សង្គមស៊ីវិល តំណាងសហគមន៍ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងក្រុមស្ត្រី វិស័យឯកជន និងផ្នែកផ្សេងទៀត ក្នុងដំណើរការតាក់តែង និងកែសម្រួលសេចក្តីព្រាងច្បាប់នេះ ព្រមទាំងអនុក្រឹត្យពាក់ព័ន្ធ។

**៣. កែលម្អការផ្តល់កម្មសិទ្ធិសមូហភាពលើដីរបស់ជនជាតិដើមភាគតិច៖** ការការពារសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាតម្លៃដ៏សំខាន់នៃច្បាប់អន្តរជាតិ ដែលមានចែងនៅក្នុងលិខិតតូបករណ៍ជាច្រើន រួមមានសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើម (UNDRIP) ដែលកម្ពុជាបានអនុម័តទាំងស្រុងដោយគ្មានការលើកលែងអ្វីទាំងអស់។ មាត្រា ១០ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើម ចែងថា "ជនជាតិដើម មិនត្រូវបានគេបណ្តេញចេញដោយបង្ខំពីដី ឬ ដែនដីរបស់ពួកគាត់ឡើយ។" ដើម្បីការពារដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឱ្យបានត្រឹមត្រូវ សេចក្តីព្រាងច្បាប់ភូមិបាលនេះ គួរតែត្រូវបានកែលម្អដោយការបន្ថែមចំណុចដូចជា៖

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

ក. ការធានានូវ សិទ្ធិចូលទៅប្រមូលអនុផលព្រៃឈើ និងចូលទៅប្រើដែនទឹកលើដីដែលត្រូវបានវិនិច្ឆ័យ និងចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ ឋិតនៅក្រៅព្រំដែននៃក្បាលដីដែលបានចុះបញ្ជីជាដីសមូហភាពក្រោមកម្មសិទ្ធិពេញលេញរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានរក្សា (មាត្រា ៣៨)។[1]

ខ. ការធានាថា កម្មសិទ្ធិសមូហភាពលើដីរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានការពារ គឺជាគោលដៅមួយនៃសេចក្ដីព្រាងច្បាប់ភូមិបាលនេះ បន្ថែមលើការការពាររបបកម្មសិទ្ធិឯកជន របបកម្មសិទ្ធិសមូហភាពផ្សេងទៀត និងរបបកម្មសិទ្ធិសាធារណៈលើដីធ្លី (មាត្រា ១ ចំណុចទី ៣)។

គ. ការបញ្ជាក់ឱ្យច្បាស់ថា ដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មិនត្រូវក្លាយជាកម្មវត្ថុនៃការដកហូត (អស្សាមិករណ៍) ការធ្វើលទ្ធកម្មដោយបង្ខំ ឬ សកម្មភាពស្រដៀងគ្នា សម្រាប់បម្រើ "ផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ" ណាមួយឡើយ (មាត្រា ៣៩)។

ឃ. ការធានាថាសហគមន៍ជនជាតិដើមភាគតិច ហើយមិនមែនរដ្ឋាភិបាល ជាអ្នកទទួលខុសត្រូវក្នុងការកំណត់ និងអនុវត្តនូវបទបញ្ជាផ្ទៃក្នុងស្ដីពីសមាជិកភាពរបស់សហគមន៍ ធ្វើជាគ្រាមភាសា និង/ឬភាសាខ្មែរ ជាលាយលក្ខណ៍អក្សរ ឬជាការថតសំឡេង តាមជម្រើសរបស់ពួកគាត់ (មាត្រា៤០ និងមាត្រា១៤៧)។

ង. ការអនុញ្ញាតឱ្យសហគមន៍ជនជាតិដើមភាគតិច ផ្ដល់ឧបសិទ្ធិលើដីរបស់ពួកគាត់ ដល់បុគ្គល និងស្ថាប័ន/អង្គភាពនានា ដូចជាសម្រាប់ការបង្កើតឥណទានកាបូន ការអនុញ្ញាតឱ្យធ្វើអាជីវកម្មរ៉ែ សេវភាពសម្រាប់ប្រព័ន្ធប្រើប្រាស់សាធារណៈ ឬហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត ប៉ុន្តែបានតែបន្ទាប់ពីអនុវត្តដំណើរការយ៉ាងម៉ត់ចត់ដើម្បីធានានូវការយល់ព្រមធ្វើឡើងក្រោយពីបានទទួលព័ត៌មានគ្រប់គ្រាន់ជាមុន និងដោយសេរីគ្មានការបង្ខិតបង្ខំ (FPIC) ហើយមានសេរីភាពក្នុងការដក ឬបញ្ចប់នូវការយល់ព្រម ឬបញ្ចប់កិច្ចព្រមព្រៀងពាក់ព័ន្ធដោយគ្មានការទទួលខុសត្រូវចំពោះការខូចខាតណាមួយត្រូវបានកំណត់សហគមន៍ជនជាតិដើមភាគតិចឡើយ (មាត្រា ៤១)

ច. រៀបចំជាប្លង់នៃដំណើការសម្រាប់សហគមន៍ជនជាតិដើមភាគតិច ប្ដឹងទៅតុលាការ ប្រសិនបើអាជ្ញាធរពាក់ព័ន្ធខកខានក្នុងការការពារដីសហគមន៍ជនជាតិដើមភាគតិច ដែលបានកំណត់ក្នុងអំឡុងពេល

[1] ឧទាហរណ៍នៃការផ្ដល់បែបនេះអាចរកឃើញនៅក្នុងមាត្រា ២៣ នៃច្បាប់ស្ដីពីសិទ្ធិប្រពៃណីលើដីធ្លី របស់ប្រទេស សេរ៉ាឡេអូន (២០២២)៖ (១) "សហគមន៍ដែលមានដីនៅក្នុង នៅជិត ឬជាប់នឹងធនធានធម្មជាតិ ដូចជាព្រៃឈើ ដីស្រែ ទន្លេ និងវាលភក់ ហើយដែលជាប្រពៃណី និងប្រវត្តិសាស្ត្រពឹងផ្អែកលើធនធានធម្មជាតិទាំងនោះ សម្រាប់ចិញ្ចឹមជីវិត សម្រាប់គោលបំណងផ្នែកជំនឿ ឬសាសនា ត្រូវមានសិទ្ធិប្រើប្រាស់ធនធានសម្រាប់គោលបំណងទាំងនោះ។
(២) ការប្រើប្រាស់ធនធានធម្មជាតិដោយសហគមន៍ដែលយោងក្នុងអនុផ្នែកទី (១) អាចត្រូវបានរឹតបន្តឹង ឬបញ្ឈប់ដោយរដ្ឋាភិបាលដោយសហការជាមួយក្រុមប្រឹក្សា Chiefdom នៅពេលមើលឃើញពីហានិភ័យនៃការថយចុះធនធានទាំងនោះ។
(៣) រដ្ឋាភិបាលត្រូវអនុវត្តនូវការរៀបចំតាមជម្រើសផ្សេងៗ ដើម្បីទប់ទល់ឥទ្ធិពលនៃការរឹតត្បិត ឬ ការបញ្ចប់នូវការប្រើប្រាស់របស់សហគមន៍។
( https://www.parliament.gov.sl/uploads/acts/THE%20CUSTOMARY%20LAND%20RIGHTS%20ACT,%202022.pdf )

ការពារ បណ្ដោះអាសន្ន ក៏ដូចជា ក្នុងដំណើរការស្នើសុំផ្ដល់ប័ណ្ណកម្មសិទ្ធិសមូហភាពលើដីរបស់សហគមន៍ជនជាតិដើមភាគតិច (មាត្រា ១៤៨)។

ឆ. ផ្ដល់អាណត្តិច្បាស់លាស់ដល់ក្រសួងទទួលបន្ទុកវិស័យសុរិយោដី (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ឱ្យផ្ដល់ជំនួយបច្ចេកទេស និងធនធានដល់សហគមន៍ជនជាតិដើមភាគតិច ដើម្បីជួយរៀបចំផែនទីនៃទ្រព្យសម្បត្តិសមូហភាពរបស់ពួកគាត់ (មាត្រា ៣៦, មាត្រា ១៤៨)។

ជ. ពង្រឹងវិធានការការពារបណ្ដោះអាសន្នសម្រាប់ដីដែលទាមទារដោយសហគមន៍ ឬក្រុមជនជាតិដើមភាគតិច ដោយមិនគិតពីស្ថានភាពនៃការបង្កើតជានីតិបុគ្គល មុនពេល និងចាប់ពីពេលចាប់ផ្ដើមដំណើរការចុះបញ្ជីដីសមូហភាព ដើម្បីការការពារដីទាំងនោះ ពីការទាមទារ ឬការចេញ ឬ/និងប្រតិបត្តិការសម្បទានណាមួយ មិនថាជាសម្បទានដី សម្បទានរុករក/ធ្វើអាជីវកម្មរ៉ែ សម្បទានទំបន់វារីអគ្គិសនី សម្បទានអភិវឌ្ឍទេសចរណ៍ សម្បទានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឬទម្រង់សម្បទានផ្សេងទៀត រហូតដល់ការទាមទាររបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានវាយតម្លៃ និងដោះស្រាយចប់ (មាត្រា ៣៦, មាត្រា ៦២, មាត្រា ៦៦, មាត្រា ១៤៨)។

**៤. បញ្ជាក់សមាសភាព និងស្ថានភាពគតិយុត្តនៃកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច៖** សមាសភាពនៃទ្រព្យសមូហភាព គួរតែរួមបញ្ចូល ដីប្រើប្រាស់សម្រាប់ធ្វើកសិកម្មក្នុងទម្រង់ណាមួយក៏បាន មិនមែនត្រឹមតែកសិកម្មដែលធ្វើឡើងតាមទម្លាប់ប្រពៃណីប៉ុណ្ណោះទេ។ ការកំណត់បែបនេះ នឹងលុបបំបាត់នូវការកម្រិតរិតត្បិតលើសហគមន៍ដែលចង់ទទួលយកបច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើប។ លើសពីនេះ ដីដែលបានចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មិនត្រូវចាត់ទុក ឬ ចាត់ថ្នាក់ថាជាទ្រព្យសម្បត្តិរបស់រដ្ឋទៀតទេ ដើម្បីឱ្យសហគមន៍ជនជាតិដើមភាគតិចដែលកាន់ប័ណ្ណកម្មសិទ្ធិ អាចប្រើប្រាស់ដោយស្របច្បាប់ និងពេញលេញនូវសិទ្ធិលើទ្រព្យសម្បត្តិ ដើម្បីការពារដីរបស់ពួកគាត់ និងប្រើប្រាស់ដីនោះបម្រើឧត្តមប្រយោជន៍របស់សហគមន៍ ហើយអាចត្រឹមតែស្ថិតក្រោមអាណាព្យាបាលនៃស្ថាប័នរដ្ឋដែលបានកំណត់ (ឧ. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ) សម្រាប់ទង្វើនៃការចាត់ចែងទ្រព្យ រួមមាន ការលក់ ការដោះដូរ ឬការផ្ទេរផ្ដាច់នូវកម្មសិទ្ធិលើអចលនវត្ថុ ទៅឱ្យ/ជាមួយ បុគ្គល/ស្ថាប័នណាមួយនៅខាងក្រៅសហគមន៍ជនជាតិដើមភាគតិច។

**៥. ទទួលស្គាល់សិទ្ធិបែបប្រពៃណីទាំងអស់៖** សេចក្ដីព្រាងច្បាប់ភូមិបាលនេះ ផ្ដោតលើ "កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច" និងការទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីជាផ្លូវការ។ សេចក្ដីព្រាងច្បាប់នេះ គួររួមបញ្ចូលសហគមន៍ផ្សេងទៀតដែលអនុវត្តប្រព័ន្ធកាន់កាប់ប្រើប្រាស់ដីធ្លីតាមបែបប្រពៃណី និងសហគមន៍/ក្រុមជនជាតិដើមភាគតិចដែលមិនទាន់បានចុះបញ្ជី និងទទួលស្គាល់ជាផ្លូវការថាជានីតិបុគ្គល ផងដែរ។ ការធ្វើបែបនេះ គួរធានាបាននូវសុវត្ថិភាពនៃការប្រើប្រាស់ដីសម្រាប់សហគមន៍មូលដ្ឋានដែលមានដីសាធារណៈសមស្រប ហើយពឹងផ្អែកលើការប្រើប្រាស់ដីនោះតាមបែបប្រពៃណីក្នុងការ

ចិញ្ចឹមជីវិត ជួយកាត់បន្ថយនូវអសន្តិសុខនៃការចិញ្ចឹមជីវិត និងការបណ្តេញចេញដោយបង្ខំ[2] ព្រមទាំងទប់ស្កាត់ជម្លោះដីធ្លីបន្ថែមទៀត។ ការកែសម្រួលមួយចំនួនដែលអាចធ្វើបាន រួមមាន៖

ក. បញ្ចូលឃ្លាទទួលស្គាល់សិទ្ធិប្រើប្រាស់តាមបែបប្រពៃណីនូវ ដីរដ្ឋ ដែលឋិតនៅជាប់ ជុំវិញ ឬជិតសហគមន៍ (មាត្រា ៥)។

ខ. បញ្ចូលឃ្លាដូចជា សិទ្ធិធ្វើជាម្ចាស់ កាន់កាប់ ប្រើប្រាស់ ស្នងមរតក ទទួលសិទ្ធិបន្ត ឬ ធ្វើកិច្ចណាមួយលើដីធ្លី ត្រូវបានធានាចំពោះស្ត្រី និងបុរសស្មើភាពគ្នា ហើយទម្លាប់អនុវត្តណាមួយដែលមិនរាប់បញ្ចូល កម្រិត ឬរារាំងស្ត្រី ពីការធ្វើជាម្ចាស់ កាន់កាប់ ប្រើប្រាស់ ផ្ទេរ ស្នងមរតក ទទួលសិទ្ធិបន្ត ឬ ធ្វើកិច្ចណាមួយលើដីធ្លី និងអចលនវត្ថុផ្សេងទៀត ត្រូវទុកជាមោឃៈ និងត្រូវលុបចោល (មាត្រា ៧)។[3]

**៦. បញ្ជាក់អំពីបទប្បញ្ញត្តិទាក់ទងនឹងការពង្រីកផ្លូវដែលប៉ះពាល់ដល់ ឬការដកហូតពីក្បាលដីដែលឋិតក្រោមភោគៈ ឬ កម្មសិទ្ធិឯកជន ឬសមូហភាព៖** ដំណើរការចាត់ថ្នាក់ និង/ឬការការធ្វើចំណាត់ថ្នាក់ឡើងវិញ និងការកំណត់ព្រំដីនៃដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ការពង្រីកផ្លូវ និងដីចំណីផ្លូវ ព្រមទាំងការបម្រុងដីទុកសម្រាប់ផ្លូវសាធារណៈ មានលក្ខណៈមិនច្បាស់លាស់ ហើយទុកចន្លោះឱ្យកើតមានវិវាទដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការដោះស្រាយចំពោះការទាមទារដីធ្លី និងការអភិវឌ្ឍសហគមន៍ឱ្យបានរីកចម្រើន។ អាស្រ័យហេតុនេះ មាត្រា ២២ គួរតែត្រូវបានលុបចេញ ហើយមាត្រា ២៤, មាត្រា ៣០ និង មាត្រា ៧៨ គួរតែមានការកែសម្រួលដើម្បីដោះស្រាយកង្វល់នេះ។ ការចែងបំភ្លឺមាត្រាទាំងនេះ និងការបង្កើនតម្លាភាព រួមទាំង ចែងច្បាស់លាស់ឱ្យមានការជូនដំណឹង និងការពិគ្រោះយោបល់ជាមួយសហគមន៍ពាក់ព័ន្ធ ព្រមទាំងការអនុញ្ញាតឱ្យប្ដឹងតវ៉ាចំពោះដីដែលបានចាត់ថ្នាក់ និង/ឬបានចាត់ថ្នាក់ឡើងវិញ ឬចំពោះការពង្រីកផ្លូវ ឬការបម្រុងដី អាចធានាបានថា អ្នកកាន់កាប់សិទ្ធិស្របច្បាប់ ត្រូវបានគោរព និងការពារដោយរដ្ឋ។

**៧. កំណត់ឱ្យច្បាស់នូវឃ្លា "ផលប្រយោជន៍សាធារណៈ" "ផលប្រយោជន៍ជាតិ" និង "សំណងត្រឹមត្រូវ និងយុត្តិធម៌" និងរបៀបគណនាសំណងត្រឹមត្រូវ និងយុត្តិធម៌៖** នៅពេលនរណាម្នាក់ត្រូវបានដកហូតទ្រព្យសម្បត្តិសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ សំណងចាំបាច់គ្របដណ្តប់នូវរាល់ការខូចខាត បាត់បង់បណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ ឬរាល់ការប៉ះពាល់លើកម្មសិទ្ធិ ឬសិទ្ធិប្រត្យក្សផ្សេងៗទៀត រួមទាំងសិទ្ធិភោគៈ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិផលុបភោគ និងសិទ្ធិក្រោមកិច្ចសន្យាសម្បទានដីសង្គមកិច្ច។ មធ្យោបាយនៃការគណនាសំណងបែបនេះគួរតែមានតម្លាភាព មានលក្ខណៈអាចយល់បាន និងស្របតាមគោលការណ៍អន្តរ

[2] ការបណ្តេញចេញដោយបង្ខំ គឺជាការរំលោភលើសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិយ៉ាងទូលំទូលាយ (រួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (មាត្រា ១១ កថាខណ្ឌទី១) អនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា ២៧ កថាខណ្ឌទី៣) បទប្បញ្ញត្តិស្តីពីការមិនរើសអើងដែលមាននៅក្នុងមាត្រា ១៤ កថាខណ្ឌទី២ (h) នៃ CEDAW និងមាត្រា ៥ (e) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍) ហើយអាចធ្វើបានតែក្នុងកាលៈទេសៈពិសេស និងស្របតាមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស (គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងផ្លាស់ទីលំនៅដោយសារការអភិវឌ្ឍ ដូចមានក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានគ្រប់គ្រាន់ ជាធាតុផ្សំនៃសិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ Miloon Kothari (២០០៧))

[3] សូមមើលច្បាប់ស្តីពីសិទ្ធិដីធ្លីប្រពៃណីរបស់សៀរ៉ាឡេអូន (ឆ្នាំ២០២២) មាត្រា ៥(១), (២)។

ជាតិ។ ច្បាប់នេះគួរតែចែងយោងយ៉ាងច្បាស់ទៅច្បាប់ស្តីពីអស្សាមិករណ៍ (ឆ្នាំ២០១០) ពេលចែងអំពីសំណងត្រឹមត្រូវ និងយុត្តិធម៌។ មានចម្លោះដើម្បីកែលម្អបន្ថែមលើសំណងឱ្យលើសពីអ្វីដែលមានចែងនៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍ ជាឧទាហរណ៍ក្រោម គោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់ដោយសារការធ្វើលទ្ធកម្មដីដោយគ្មានការស្ម័គ្រចិត្ត។ សំណងទាំងអស់គួរតែរួមបញ្ចូល ជាអប្បបរមា មិនត្រឹមតែតម្លៃពេញលេញនៃសិទ្ធិណាមួយដែលបុគ្គលមានចំពោះចលនទ្រព្យ និងអចលនទ្រព្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង សំណងសម្រាប់ការប៉ះពាល់ផ្លូវកាយ ឬ ផ្លូវចិត្ត ការបាត់បង់ឱកាស ការបាត់បង់ប្រាក់ចំណូល និងសម្រាប់ថ្លៃចំណាយផ្សេងៗដែលកើតឡើងក្នុងដំណើរការផ្លាស់ប្តូរទីតាំង។ "ផលប្រយោជន៍សាធារណៈ" "ផលប្រយោជន៍ជាតិ" និង "សំណងត្រឹមត្រូវ និងយុត្តិធម៌" គួរត្រូវបានកំណត់យ៉ាងច្បាស់។ ដោយសន្មត់ថាច្បាប់នេះ (មិនកំណត់ពន្យល់ដោយផ្ទាល់នូវពាក្យទាំងនេះ) ទាញយកនិយមន័យពីច្បាប់ស្តីពីអស្សាមិករណ៍ និយមន័យនៅក្នុងច្បាប់ទាំងពីរគួរតែត្រូវបានពង្រឹងដើម្បីឆ្លុះបញ្ចាំងនូវទម្លាប់អនុវត្តល្អជាអន្តរជាតិ ទាក់ទងនឹងការដកហូត (ក្នុងមួយកថាខណ្ឌ ១៦.១ នៃគោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីធ្លី ជលផល និងព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ (VGGT))។ ជាពិសេស "ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ" គួរតែមានលក្ខណៈជាក់លាក់ជាងនេះ ហើយរួមបញ្ចូលនូវបញ្ជីនៃគោលបំណងដែលបានកំណត់ ដែលរាប់ជា "ផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ"។ គោលបំណងទាំងនេះអាចរួមបញ្ចូលការដឹកជញ្ជូន អគារសាធារណៈ សេវាសាធារណៈ និងសួនសាធារណៈ។

**៨. បង្កើតអភិក្រមលម្អិតបន្ថែមទៀតក្នុងការដោះស្រាយចំពោះការកាន់កាប់ដីធ្លីក្រោយឆ្នាំ២០០១ (មាត្រា ២៩ និងមាត្រាផ្សេងៗទៀត)៖** ខណៈការបង្កើតឱ្យច្បាស់លាស់មានសារៈសំខាន់ នូវដំណើរការដែលការកាន់កាប់ ឬ ទម្រង់នៃសិទ្ធិប្រើប្រាស់ផ្សេងទៀត ដែលមិនទាន់ក្លាយជាសិទ្ធិកម្មសិទ្ធិពេញលេញ អាចប្រែក្លាយទៅជាកម្មសិទ្ធិស្របច្បាប់ ការរឹតបន្តឹងនាពេលបច្ចុប្បន្នដែលចែងថា ការកាន់កាប់ណាមួយ ត្រូវតែកើតឡើងមុនឆ្នាំ២០០១ មិនឆ្លុះបញ្ចាំងពីការប្រើប្រាស់ដីក្នុងរយៈពេល ២០ឆ្នាំ ចុងក្រោយនេះទេ។ ដរាបណាអ្នកកាន់កាប់ដីបច្ចុប្បន្នបានកាន់កាប់ដីក្នុងរយៈពេលសមស្របណាមួយ ពួកគេគួរតែទទួលបានឱកាសដើម្បីទាមទារនូវសិទ្ធិភោគៈ និង/ឬសិទ្ធិប្រើប្រាស់ផ្សេងទៀត ដូចជា សិទ្ធិផលុបភោគ ឬ ទទួលបានសិទ្ធិជួលអចិន្ត្រៃយ៍បែបសម្បទាន។[4]

**៩. បញ្ជាក់អំពីតម្រូវការបែងចែក និងដកហូតសម្បទានដីសង្គមកិច្ច៖** ពិចារណាបន្ថែមនិយមន័យនៃ "គ្រួសារក្រីក្រ" ដែលមានសិទ្ធិទទួលបានសម្បទានសង្គមកិច្ចក្នុងមាត្រា ៦៣។ ហើយនៅក្នុងមាត្រា ៧០ ច្បាប់គួរតែបញ្ជាក់ថាសម្បទានដីសង្គមកិច្ច ត្រូវចេញតាមរយៈដំណើរការប្រកបដោយតម្លាភាព និងមានការចូលរួម ហើយ

---

[4] ច្បាប់នេះគួរតែរួមបញ្ចូលនូវដំណើរការដ៏ងាយស្រួលមួយដែលអ្នកកាន់កាប់អាចបំប្លែងភោគៈរបស់ពួកគេទៅជាកម្មសិទ្ធិ រួមទាំងគោលការណ៍ណែនាំលម្អិតដែលចេញដោយក្រសួងទទួលបន្ទុក រដ្ឋបាលសុរិយោដី លើគោលការណ៍ដែលគួរត្រូវយកមកពិចារណាក្នុងការវាយតម្លៃការទាមទារ និងទម្រង់នៃភស្តុតាងដែលអាចផ្តល់ជូនដើម្បីបញ្ជាក់។ ភស្តុតាងទាំងនេះអាចរួមបញ្ចូលសក្ខីកម្មផ្ទាល់មាត់ពីសមាជិកសហគមន៍ ឬមន្ត្រីរដ្ឋាភិបាល ប្លង់ទន់ដែលចេញដោយរដ្ឋាភិបាលក្នុងតំបន់ កិច្ចសន្យាជួល កិច្ចសន្យាលក់ កិច្ចព្រមព្រៀង ឬបណ្ណអនុញ្ញាតដែលចេញដោយស្ថាប័នរដ្ឋាភិបាល ភស្តុតាងនៃការបង់ពន្ធ ការបែងចែកដី និងការអនុញ្ញាតសាងសង់។ ភស្តុតាងទាំងអស់គួរតែត្រូវបានវាយតម្លៃនៅក្នុងបរិបទដែលត្រូវបានចេញផ្សាយដោយមានការយកចិត្តទុកដាក់ ជាពិសេសទៅលើសក្តានុពលនៃការរើសអើងប្រឆាំងនឹងស្ត្រី ជនជាតិដើមភាគតិច យុវជន និងក្រុមដែលងាយរងគ្រោះផ្សេងទៀត។

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

ធានាបាននូវការពិគ្រោះយោបល់ជាមួយមុខសញ្ញាអ្នកទទួលដី ដើម្បីដោះស្រាយឆ្លើយតបចំពោះផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពួកគាត់ ដែលបន្សីជាមួយ ការប៉ាន់ប្រមាណហេតុប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន។ ការផ្ដល់សម្បទានដីសង្គមកិច្ច គួរតែជៀសវាងតំបន់ដែលជម្លោះដីធ្លីដែលអាចកើតមាន រួមទាំង ជាមួយ អ្នកកាន់កាប់សិទ្ធិបែបប្រពៃណី (ក្នុងករណីដែលអ្នកកាន់កាប់សិទ្ធិបែបប្រពៃណីនេះ ត្រូវបានទទួលស្គាល់ - សូមមើលចំណុចខាងលើ) និងតំបន់នៅជិតសហគមន៍ជនជាតិដើមភាគតិច ដែលមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពលើដីរបស់សហគមន៍ជនជាតិដើមភាគតិចនៅឡើយ។ សូមពិចារណាផងដែរនូវវិធានការ និងយន្តការដែលមានប្រសិទ្ធភាពបន្ថែមទៀតសម្រាប់ការត្រួតពិនិត្យលើការអនុវត្តរបស់អ្នកទទួលដីសម្បទានសង្គមកិច្ច និងការដកហូតសម្បទានដីសង្គមកិច្ចដែលអសកម្ម និងការលុបចោលកិច្ចព្រមព្រៀងផ្ទេរកម្មសិទ្ធិឯកជនខុសច្បាប់ដែលបានធ្វើឡើងក្នុងអំឡុងពេលអាជ្ញាយុកាល និងការផ្ដល់សម្បទានដីសង្គមកិច្ចក្នុងទម្រង់ផ្សេងទៀតនៃការប្រើប្រាស់ដីធ្លី ដូចជា ក្នុងទម្រង់ជាសិទ្ធិផលុបភោគ និង/ឬ សិទ្ធិជួលអចិន្ត្រៃយ៍ដែលគ្មានថ្លៃឈ្នួល។

**១០. បង្កើតការរឹតបន្តឹងលើការផ្ដល់សម្បទានដីសេដ្ឋកិច្ច៖** ប្រសិនបើអំណាចក្នុងការផ្ដល់សម្បទានដីសេដ្ឋកិច្ចត្រូវបានរក្សាទុក នោះ ត្រូវតែមានការដាក់កំហិតយ៉ាងម៉ឺងម៉ាត់ដើម្បីធានាថាសម្បទានបែបនេះ មិនរំខានរារាំងចំពោះការទាមទារដីស្របច្បាប់របស់អ្នកដទៃ ឬ មិននាំទៅដល់កំណើនជម្លោះដីធ្លី។ ការកំណត់លើទំហំ និងការកាត់បន្ថយរយៈពេលនៃសម្បទានដីសេដ្ឋកិច្ចនៅក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីគួរត្រូវបានចែងបញ្ជាក់ឡើងវិញ និងចែងពង្រឹងបន្ថែម រួមជាមួយការដាក់កំហិតនៃការផ្ដល់សម្បទានដីសេដ្ឋកិច្ចតែមួយកន្លែង សម្រាប់បុគ្គល ឬនីតិបុគ្គលមួយ និងបញ្ចូលលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់កំណត់សិទ្ធិគ្រប់គ្រងរបស់នីតិបុគ្គលមួយដោយនីតិបុគ្គលផ្សេងទៀត។ បន្ថែមពីនេះទៀត គួរតែមានគោលការណ៍ណែនាំច្បាស់លាស់អំពីកត្តាដែលតម្រូវឱ្យបង្កើតឡើងសម្រាប់បម្រើគោលបំណងសេដ្ឋកិច្ចសមហេតុផលក្នុងការផ្ដល់សម្បទានដីសេដ្ឋកិច្ច។ អ្នកកាន់ដីសម្បទានសេដ្ឋកិច្ច គួរតែត្រូវបានតម្រូវក្រោមគោលការណ៍ណែនាំនោះ ឱ្យរាយការណ៍អំពីវឌ្ឍនភាពរបស់ពួកគេឆ្ពោះទៅរកការសម្រេចបាននូវគោលដៅសេដ្ឋកិច្ច។ ហើយលក្ខខណ្ឌឱ្យចាប់ផ្ដើមប្រើដីសម្បទានក្នុងរយៈពេល ១២ខែ ត្រូវតែចែងបញ្ជាក់ឡើងវិញ។

លើសពីនេះ គួរបន្ថែមបទប្បញ្ញត្តិដែលតម្រូវឱ្យអ្នកកាន់កាប់ដីសម្បទានសេដ្ឋកិច្ច គោរពតាមគោលការណ៍ដែលមានការទទួលស្គាល់ជាអន្តរជាតិ អំពីការវិនិយោគប្រកបដោយទំនួលខុសត្រូវ ដូចមាននៅក្នុងគោលការណ៍សម្រាប់ការវិនិយោគប្រកបដោយទំនួលខុសត្រូវក្នុងវិស័យកសិកម្ម និងប្រព័ន្ធស្បៀងអាហារ។ បទប្បញ្ញត្តិនេះគួរតែរួមបញ្ចូល ការចូលរួមពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់ (ដោយគោរពសិទ្ធិរបស់ពួកគេក្នុងការផ្ដល់ ឬរក្សានូវការយល់ព្រមក្រោយពីបានទទួលព័ត៌មានគ្រប់គ្រាន់ជាមុន និងដោយសេរីគ្មានការបង្ខិតបង្ខំ) ការប៉ាន់ប្រមាណហេតុប៉ះពាល់បរិស្ថាន និងសង្គមមុនពេលធ្វើការសម្រេចចិត្តណាមួយ ថាតើត្រូវបន្តការវិនិយោគឬទេ និងបញ្ចូលយន្តការបណ្ដឹងសារទុក្ខដែលធានបានយុត្តិធម៌ និងងាយស្រួលប្រើប្រាស់ ព្រមទាំង ការត្រួតពិនិត្យហេតុប៉ះពាល់អវិជ្ជមានក្នុងអំឡុងពេលអនុវត្តគម្រោង។ ក្នុង

ករណីដែលសម្បទានដីត្រូវបានផ្តល់ឱ្យនៅលើដីដែលមានការកាន់កាប់ និងប្រើប្រាស់តាមបែបប្រពៃណីដោយសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មិនមែនជនជាតិដើមភាគតិចផ្សេងទៀត គួរមានការផ្តល់សំណងជាដីថ្មី និងករណីដែលអាចធ្វើទៅបាន គួរមានការប្រគល់ដីនោះឱ្យសហគមន៍វិញ។

រដ្ឋាភិបាលក៏គួរតែពិចារណាធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលគ្របដណ្តប់លើសម្បទានទាំងអស់ផង។

**១១. បង្កើតដំណើរការពិគ្រោះយោបល់ជាសាធារណៈ និងការប៉ាន់ប្រមាណហេតុប៉ះពាល់បរិស្ថាន និងសង្គម មុនពេលផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច និងការប្រកាសព័ត៌មានលម្អិតជាសាធារណៈ៖** ខណៈពេលដែលភាពស្មុគ្រស្មាញសម្រាប់ដំណើរការផ្តល់ និងការចុះបញ្ជីសម្បទានដី ត្រូវបានដាក់ចេញក្នុងអនុក្រឹត្យ វាចាំបាច់ណាស់ក្នុងការចែងក្នុងច្បាប់នេះថាដំណើរការបែបនេះត្រូវតែរួមបញ្ចូលការប៉ាន់ប្រមាណហេតុប៉ះពាល់បរិស្ថាន និងសង្គម និងការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយអត្ថន័យជាមួយអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោងសម្បទានដី ជាពិសេស ជនជាតិដើមភាគតិច ប្រជាជនសហគមន៍ប្រពៃណីក្នុងស្រុក ស្ត្រី យុវជន និងក្រុមងាយរងគ្រោះផ្សេងទៀត។ ការពិគ្រោះយោបល់ជាសាធារណៈបែបនេះធានាថា វិវាទដីធ្លីដែលអាចកើតមានឡើង ឬវិវាទផ្សេងទៀតត្រូវបានបង្ហាញជាមុន នៅក្នុងដំណើរការ ហើយអាចជៀសវាង ឬចរចាបានកាន់តែមានប្រសិទ្ធភាព។ លើសពីនេះ ព័ត៌មានលម្អិតទាំងអស់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច (ដូចជាឈ្មោះសម្បទានិក ព័ត៌មានទំនាក់ទំនងលម្អិត ទំហំសម្បទានដី សេចក្តីពណ៌នាអំពីគម្រោងសម្បទាន និងពេលវេលាអនុវត្ត ។ល។) គួរតែផ្សព្វផ្សាយជាសាធារណៈដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់បានដឹងអំពីលក្ខណៈ វិសាលភាព និងស្ថានភាពនៃការវិនិយោគលើដីទាំងនេះ។

**១២. ការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រ និងបរិយាបន្នសង្គម៖** ស្របតាមការប្តេជ្ញាចិត្តនៅក្នុងរដ្ឋធម្មនុញ្ញចំពោះសិទ្ធិ និងសេរីភាពស្មើគ្នារបស់ស្ត្រី និងកុមារ និងចំពោះការគ្មានការរើសអើង (មាត្រា ៣១ និងមាត្រា ៤៥) ច្បាប់អន្តរជាតិ (ឧ. អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ) និងទម្លាប់អនុវត្តល្អជាអន្តរជាតិ (ឧ. អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីធ្លី ជលផល និងព្រៃឈើក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ) សេចក្តីព្រាងច្បាប់ភូមិបាលនេះ គួរមានបញ្ចូលប្រការដាក់លាក់ដែលគាំទ្រចំពោះសិទ្ធិស្មើគ្នារបស់ស្ត្រីក្នុងការគ្រប់គ្រង ការទទួលបាន និងការធ្វើជាម្ចាស់ ព្រមទាំង ប្រការហាមឃាត់ការរើសអើងប្រឆាំងនឹងស្ត្រី។ ការប្តេជ្ញាចិត្តនេះអាចឆ្លុះបញ្ចាំងនៅក្នុងអត្ថបទដំបូងដែលបញ្ជាក់ពីគោលបំណង និងគោលការណ៍នៃច្បាប់ (មាត្រា ១ និងមាត្រា ៥) ក៏ដូចជានៅក្នុងអត្ថបទទាំងមូល។

ក. មាត្រា ១ អាចចែង ជានាការការពារកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀត រួមទាំងការប្រើប្រាស់តាមបែបប្រពៃណី លើដីធ្លី និងអចលនវត្ថុផ្សេងទៀតរបស់បុគ្គលឯកជន ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន ស្ត្រី យុវជន និងក្រុមងាយរងគ្រោះ។

ខ. មាត្រា ៥ អាចបន្ថែមគោលការណ៍ពីរទៀតគឺ៖

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

i. ជានាសមធម៌ តម្លាភាព និងគណនេយ្យភាពក្នុងការបែងចែក និងការគ្រប់គ្រងសិទ្ធិដីធ្លី។

ii. សិទ្ធិធ្វើជាម្ចាស់ កាន់កាប់ ប្រើប្រាស់ ស្នងមរតក ទទួលសិទ្ធិបន្ត ឬ ធ្វើកិច្ចណាមួយលើដីធ្លី ត្រូវបានធានាចំពោះស្ត្រី និងបុរសស្មើភាពគ្នា។

**១៣. អនុញ្ញាតឱ្យមានការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី មកតុលាការកម្ពុជា៖** ខណៈពេលដែលវាមានសារៈសំខាន់ក្នុងការមានស្ថាប័នពិសេសសម្រាប់ដោះស្រាយវិវាទដីធ្លី គណៈកម្មការសុរិយោដីមិនគួរមានសិទ្ធិអំណាចផ្តាច់មុខលើវិវាទដីធ្លីចំពោះការបដិសេធសិទ្ធិនៃការប្តឹងតវ៉ាណាមួយ និង/ឬសិទ្ធិទទួលបានយុត្តិធម៌ទាន់ពេលវេលានោះទេ។ ក្នុងករណីដែលភាគីវិវាទយល់ថា សកម្មភាព ឬសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី មិនបានអនុវត្តតាមច្បាប់ ឬ តាមពេលវេលាកំណត់ ពួកគេគួរតែមានសិទ្ធិយ៉ាងច្បាស់លាស់ក្នុងការទាមទារឱ្យមានការវិនិច្ឆ័យចុងក្រោយ និងជាប់កាតព្វកិច្ច ដោយគ្មានពន្យារពេលយ៉ាងអយុត្តិធម៌។ លក្ខខណ្ឌដែលភាគីជម្លោះអាចស្វែងរកដំណោះស្រាយតាមផ្លូវតុលាការគួរតែត្រូវបានដាក់ឱ្យច្បាស់ក្នុងបទប្បញ្ញត្តិបន្ថែមទៀត។ ពាក់ព័ន្ធចំណុចនេះ គណៈកម្មការសុរិយោដី គួរតែត្រូវបានតម្រូវឱ្យចេញសេចក្តីសម្រេចក្នុងរយៈពេលកំណត់ ដើម្បីជៀសវាងការពន្យារពេលមិនសមហេតុផល និងធានាថា ការសម្រេចចិត្តត្រូវបានចេញ ឬយុត្តាធិការរបស់គណៈកម្មការសុរិយោដី ត្រូវបានផុតរលត់។

**១៤. ផ្តល់ឋានៈនីតិបុគ្គល និងកំណត់សញ្ជាតិខ្មែរនៃនីតិបុគ្គលក្រៅពីសហគ្រាសពាណិជ្ជកម្ម៖** សេចក្តីព្រាងច្បាប់នេះគួរតែត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយគម្លាតផ្លូវច្បាប់សម្រាប់ការផ្តល់ឋានៈនីតិបុគ្គល និងការកំណត់សញ្ជាតិនៃសហគមន៍មូលដ្ឋាន/ក្នុងស្រុក រួមទាំងនៃសហគមន៍ជនជាតិដើមភាគតិច សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ផងដែរ។

**១៥. ការចែងឱ្យមានការទទួលខុសត្រូវរបស់រដ្ឋបាលសុរិយោដី រដ្ឋាភិបាល និងស្ថាប័នរដ្ឋ ដែលធ្វើទង្វើដែលប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់បុគ្គលឯកជន ក្រុមសមូហភាព និងនីតិបុគ្គល ជាពិសេសចំពោះ តតីយជនដែលគ្មានកំហុស៖** ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលការណ៍នៃការធានារបស់រដ្ឋចំពោះកម្មសិទ្ធិ (រួមទាំងសិទ្ធិប្រត្យក្សស្របច្បាប់ផ្សេងៗទៀត) ច្បាប់គួរតែចែងអំពីការការទទួលខុសត្រូវ ប្រសិនបើទង្វើ ឬការសម្រេចចិត្តរបស់ រដ្ឋបាលសុរិយោដី (និងភ្នាក់ងារដែលធ្វើសកម្មភាពក្នុងនាមរដ្ឋបាលសុរិយោដី) រដ្ឋាភិបាល និងស្ថាប័នរដ្ឋ (ដូចជា ក្រសួងទទួលបន្ទុកវិស័យសុរិយោដី) នាំឱ្យប៉ះពាល់អវិជ្ជមានដល់សិទ្ធិរបស់តតិយជនដែលគ្មានកំហុស ដែលពឹងផ្អែកទាំងស្រុងលើព័ត៌មានដែលបានកត់ត្រាក្នុងបញ្ជីដីធ្លី និង/ឬ ផ្តល់ឱ្យនៅក្នុងសាលាកបត្រព័ត៌មាន/វិញ្ញាបនបត្រសុរិយោដី ដែលទទួលបានពីរដ្ឋបាលសុរិយោដី។ នៅពេលដែលរដ្ឋ អនុវត្តសិទ្ធិដកហូតកម្មសិទ្ធិឯកជន រដ្ឋត្រូវផ្តួចផ្តើម និងចេញចំណាយលើរាល់ថ្លៃ និងការចំណាយពាក់ព័ន្ធទាំងអស់សម្រាប់ការកែតម្រូវក្បាលដីដែលរងផលប៉ះពាល់ដោយសកម្មភាពនៃការដកហូត ឬអស្សាមិករណ៍របស់រដ្ឋ និងលើការចុះបញ្ជីបន្តនៃការប្រែប្រួលលើក្បាលដី។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

**សទ្ទានុក្រម៖** បច្ចុប្បន្ននេះ សទ្ទានុក្រម មិនមាននិយមន័យនៃពាក្យសំខាន់ៗ និងមានពាក្យជាច្រើនដែលមិនបង្ហាញនៅក្នុងខ្លឹមសាររបស់ច្បាប់។ ពាក្យដែលគួរតែមាននិយមន័យ មានដូចជា "សិទ្ធិប្រពៃណី" "អចលនវត្ថុ" "អចលនទ្រព្យ" "ផលប្រយោជន៍សាធារណៈ" "ផលប្រយោជន៍ជាតិ" "សំណងត្រឹមត្រូវ និងយុត្តិធម៌"។ល។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណដល់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានផ្តល់ឱកាសឱ្យអង្គការអូឌីស៊ី បានត្រួតពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ភូមិបាលនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ភូមិបាលចុងក្រោយ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ៧ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤
**នាយកប្រតិបត្តិ**

អង្គការទិន្នន័យអំពីការអភិវឌ្ឍ OPEN DEVELOPMENT CAMBODIA ORGANIZATION

**ធី ទ្រី**

# យោបល់លើសេចក្តីព្រាងច្បាប់ភូមិបាល

| | |
|---|---|
| ស្ថាប័ន៖ | អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ហៅកាត់ថា អូឌីស៊ី) និងក្រុមការងារបច្ចេកទេស |
| ឈ្មោះ៖ | លោក ធី ទ្រី |
| តួនាទី៖ | នាយកប្រតិបត្តិ នៃអង្គការទិន្នន័យអំពីការអភិវឌ្ឍ |
| លេខទូរសព្ទ និងអ៊ីម៉ែល៖ | try@opendevcam.net |
| កាលបរិច្ឆេទនៃការផ្តល់យោបល់៖ | ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ |
| ឯកសារយោង៖ | លិខិតលេខ ០៣៣ ជនស/ក.ក.ច ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| មាត្រា ១ | របបកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងរបស់វត្ត មិនដូចរបបកម្មសិទ្ធិរបស់រដ្ឋ និងរបបកម្មសិទ្ធិរបស់បុគ្គលឯកជនទេ។<br><br>ដើម្បីឱ្យស្របតាមការប្តេជ្ញាក្នុងរដ្ឋធម្មនុញ្ញចំពោះសិទ្ធិស្មើគ្នារវាងស្ត្រី និងកុមារ ព្រមទាំងចំពោះការគ្មានភាពរើសអើងអ្វីទាំងអស់ (មាត្រា ៣១ និង ៤៥) ក្នុងច្បាប់អន្តរជាតិ (ឧ. កតិកាសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ) និងទម្លាប់អនុវត្តល្អជាអន្តរជាតិ (ឧ. គោលការណ៍ណែនាំបែបស្ម័គ្រចិត្តរបស់ UNFAO ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីធ្លី ជលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងជាតិ) សេចក្តីព្រាងច្បាប់នេះអាចត្រូវបានកែលម្អដោយការបញ្ចូលនូវប្រការដាក់លាក់មួយចំនួនដែលគាំទ្រចំពោះសិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រង ការចូលទៅប្រើប្រាស់ និងការធ្វើជាម្ចាស់ ព្រមទាំងការហាមឃាត់នូវការរើសអើងចំពោះស្ត្រីភេទ ដែលឆ្លុះបញ្ចាំងក្នុងមាត្រា ៣១ និងមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ។ | សូមចែងបន្ថែម ការធានាការពារកម្មសិទ្ធិសមូហភាព សិទ្ធិប្រើប្រាស់ អាស្រ័យផល និងសិទ្ធិផ្សេងៗទៀតលើដី និងអចលនវត្ថុដទៃទៀត របស់សហគមន៍ជនជាតិដើមភាគតិច និងរបស់វត្ត ឱ្យមានរបបកម្មសិទ្ធិខុសពីរបបកម្មសិទ្ធិឯកជននៃបុគ្គលឯកជនផង។<br><br>ចែងថា ធានាការពារកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត រួមទាំងការប្រើប្រាស់តាមលក្ខណៈប្រពៃណីលើដី និងអចលនវត្ថុដទៃទៀតរបស់បុគ្គលឯកជន និងសមូហភាព រួមទាំងជនជាតិដើម សហគមន៍ក្នុងមូលដ្ឋាន ស្ត្រី យុវជន និងក្រុមជនងាយរងគ្រោះនានា។ |

| មាត្រា | ឃោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ចែងបញ្ជាក់ថា ការការពារនូវរបបកម្មសិទ្ធិសមូហភាពលើដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច គឺជាគោលបំណងនៃសេចក្តីព្រាងច្បាប់នេះ បន្ថែមលើការការពារនូវរបបកម្មសិទ្ធិឯកជនរបស់បុគ្គលឯកជន របបកម្មសិទ្ធិសមូហភាពផ្សេងទៀតលើដីធ្លី និងរបបកម្មសិទ្ធិនៃទ្រព្យសាធារណៈ។<br><br>ចែងបន្ថែមប្រការឃោងអំពីកិច្ចការពារនូវសិទ្ធិប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានផ្សេងៗទៀត ព្រមទាំងនូវសិទ្ធិរបស់ស្ត្រី យុវជន និងជនងាយរងគ្រោះ ស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា (មាត្រា ៣១ និងមាត្រា ៤៥) គោលការណ៍ណែនាំបែបស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីធ្លី ជលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងជាតិ UN FAO (VGGT) កតិកាសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW) និងសេចក្តីថ្លែងការណ៍របស់ UN ស្តីពីសិទ្ធិរបស់ជនជាតិដើម (UNDRIP)។ តាមការចែងបែបនេះ កម្ពុជាមិនត្រឹមតែអាចបំពេញកាតព្វកិច្ចជាតិ និងអន្តរជាតិរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែអាចថែមទាំងកាត់បន្ថយនូវទំនាស់ដីធ្លី ទៀតផង។ | |
| មាត្រា ៣ | សទ្ទានុក្រម ដែលដាក់ជាឧបសម្ព័ន្ធនៃច្បាប់ មិនត្រូវបានដាក់ឱ្យអង្គនីតិបញ្ញត្តិ ពិនិត្យ និងអនុម័ត ដូច្នេះវាមិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការបកស្រាយច្បាប់ ហើយក៏មិនមានប្រយោជន៍ក្នុងការពន្យល់ផ្សព្វផ្សាយច្បាប់ និងក្នុងការអនុវត្តច្បាប់ ទេ។<br><br>ដើម្បីពង្រឹងអភិបាលកិច្ចនៃច្បាប់ និងនីតិរដ្ឋ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា គួរតែប្រើប្រាស់ពាក្យសាមញ្ញ ដែលក្រុមគោលដៅរបស់ច្បាប់អាចងាយយល់ ហើយពាក្យគន្លឹះ ឬឃ្លាសង្ខេប ឬអក្សរកាត់ ដែលប្រើក្នុងច្បាប់ គួរតែចែងពន្យល់ក្នុងអត្ថបទច្បាប់ ជំនួសឱ្យការដាក់ក្នុងឧបសម្ព័ន្ធនៃច្បាប់ដែលគ្មានការកំណត់អត្ថន័យ និងចេតនានៃការប្រើប្រាស់ច្បាស់លាស់ទេនោះ។ | សូមប្រើប្រាស់ពាក្យសាមញ្ញ ដែលក្រុមគោលដៅរបស់ច្បាប់អាចងាយយល់ ហើយសូមពន្យល់ ឬ ផ្តល់និយមន័យនៃពាក្យគន្លឹះ ឬឃ្លាសង្ខេប ឬអក្សរកាត់ ដែលប្រើក្នុងច្បាប់នេះ នៅក្នុងអត្ថបទច្បាប់តែម្តង និងលុបចោលសទ្ទានុក្រម។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ការធ្វើសទ្ធានុក្រម គួរទុកឱ្យរាជបណ្ឌិតសភាកម្ពុជា ឬនិងក្រុមការងាររៀបចំពាក្យច្បាប់ដឹកនាំដោយក្រសួងយុត្តិធម៌ ជាអ្នករៀបចំសម្រាប់ផ្សព្វផ្សាយបង្កើនការយល់ដឹងទូទៅដល់សាធារណជន។ | |
| មាត្រា ៤ និងមាត្រាពាក់ព័ន្ធផ្សេងៗទៀត | គួរជៀសវាងការប្រើប្រាស់ឈ្មោះពេញរបស់ក្រសួងស្ថាប័នបច្ចុប្បន្ន ដែលមានមុខងារគ្រប់គ្រងលើវិស័យច្រើននៅក្នុងច្បាប់ ដើម្បីកុំឱ្យការកែប្រែផ្លាស់ប្តូរឈ្មោះ និងមុខងាររបស់ក្រសួងនោះ នាពេលអនាគត ប៉ះពាល់ដល់ច្បាប់នេះ។ | សូមប្រើពាក្យថា ក្រសួងទទួលបន្ទុកគ្រប់គ្រងវិស័យសុរិយោដី ជំនួសឱ្យ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ |
| មាត្រា ៥ | របបកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងរបស់វត្ត មិនដូចរបបកម្មសិទ្ធិរបស់រដ្ឋ និងរបបកម្មសិទ្ធិរបស់បុគ្គលឯកជនទេ។<br><br>ក្នុងកំណែទម្រង់ច្បាប់តាមរយៈច្បាប់ភូមិបាលថ្មីនេះ គួរមានចែងបញ្ជាក់ និងផ្លាស់ប្តូររបបកម្មសិទ្ធិសមូហភាពសហគមន៍ជនជាតិដើមភាគតិច និងរបស់វត្ត ដើម្បីពង្រឹងអភិបាលកិច្ច និងផ្តល់សិទ្ធិអំណាចបន្ថែមដល់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ពុទ្ធបរិស័ទចំណុះជើងវត្ត។<br><br>ជាការចាំបាច់ដែលរដ្ឋត្រូវលើកកម្ពស់គោលការណ៍ និងការទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដែលមានកំណត់ក្នុង មាត្រា ៣ ដល់មាត្រា ៥ មាត្រា ២៥ ដល់មាត្រា ២៧ និងមាត្រា ៣២ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលប្រទេសកម្ពុជាបានចុះហត្ថលេខា ទទួលស្គាល់ទាំងស្រុង ដោយគ្មានបំរុងទុកលើប្រការណាមួយ នៅឆ្នាំ២០០៧។<br><br>សម្រាប់ហេតុផលផ្សេងៗទៀត សូមមើល VGGT, CEDAW, UNDRIP, រដ្ឋធម្មនុញ្ញ ។ល។ ហើយជាគំរូល្អមួយសូមមើល ច្បាប់ស្តីពីសិទ្ធិលើដីធ្លីតាមលក្ខណៈប្រពៃណីរបស់ប្រទេស Sierra Leone។ | សូមបន្ថែមក្នុងចំណុចទ្រទីពីរនៃមាត្រានេះ នូវ ទ្រព្យសម្បត្តិ និង សិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងសិទ្ធិរបស់វត្ត។<br>ហើយសូមបន្ថែមនូវ ការគោរព ពង្រឹង និងលើកកម្ពស់ស្វ័យភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងរបស់សហគមន៍ពុទ្ធសាសនិកចំណុះជើងវត្តផង។<br><br>ចែងបន្ថែមអំពីសមធម៌យេនឌ័រ និងការការពារចំពោះសិទ្ធិរបស់សហគមន៍ជនជាតិដើម និងសហគមន៍ក្នុងមូលដ្ឋាននានា ដោយៈ<br>• ធានានូវសមធម៌ តម្លាភាព និងគណនេយ្យភាពក្នុងការបែងចែក និងការគ្រប់គ្រងសិទ្ធិលើដីធ្លី;<br>• សិទ្ធិក្នុងការធ្វើជាម្ចាស់ កាន់កាប់ ប្រើប្រាស់ ស្នងមរតក ទទួលសិទ្ធិបន្ត ចំពោះ ឬកិច្ចទំនាក់ទំនងជាមួយដីធ្លី ត្រូវបានធានាចំពោះស្ត្រី និងបុរស យ៉ាងស្មើគ្នា។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ដាក់បញ្ចូលនូវឃ្លាដែលទទួលស្គាល់ សិទ្ធិក្នុងការប្រើប្រាស់តាម លក្ខណៈប្រពៃណីលើដីនៅជាប់ជុំវិញ ឬក្បែរទីតាំងដីរដ្ឋ។<br><br>បន្ថែមកិច្ចធានានូវសមធម៌ តម្លាភាព និងគណនេយ្យភាពក្នុងការបែងចែក និងការគ្រប់គ្រងសិទ្ធិលើដីធ្លី; និងសិទ្ធិក្នុងការធ្វើជាម្ចាស់ កាន់កាប់ ប្រើប្រាស់ ស្នងមរតក ទទួលសិទ្ធិបន្តចំពោះ ឬកិច្ចទំនាក់ទំនងជាមួយដីធ្លី ត្រូវបានធានាចំពោះស្ត្រី និងបុរសយ៉ាងស្មើគ្នា ។ | |
| មាត្រា ៦ | បន្ថែមប្រការយោងអំពីការប្រើប្រាស់ដីតាមបែបប្រពៃណី សម្រាប់ ហេតុផលដែលបានផ្តល់ជូនខាងលើ។ | |
| មាត្រា ៧ | ដូចយោបល់សម្រាប់មាត្រា ៥។<br><br>សេចក្តីព្រាងច្បាប់នេះផ្តោតលើ "កម្មសិទ្ធិសមូហភាពរបស់ជនជាតិដើម" និងលើការទទួលស្គាល់ចំពោះសហគមន៍ជនជាតិដើមដែលបានចុះបញ្ជីត្រឹមត្រូវ។ វាគួរបញ្ចូលនូវសហគមន៍ផ្សេងៗទៀត ដែលអនុវត្តប្រព័ន្ធកាន់កាប់ដីធ្លីតាមបែបប្រពៃណី ព្រមទាំងក្រុម ឬសហគមន៍ជនជាតិដើម ដែលមិនទាន់បានចុះបញ្ជី និងទទួលស្គាល់ជាផ្លូវការថាជានីតិបុគ្គល។ ការមើលរំលងសហគមន៍ក្នុងមូលដ្ឋាននានា ដែលមានដីសាធារណៈសមស្រប ដែលពឹងអាស្រ័យលើទម្លាប់ប្រពៃណីក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅ អាចនាំឱ្យមានអសន្តិសុខផ្នែកជីវភាព ការបណ្តេញចេញដោយបង្ខំ ទំនាស់ដីធ្លីដែលមិនចង់ឱ្យកើតមាន។<br><br>បន្ថែមឃ្លាថា សិទ្ធិក្នុងការធ្វើជាម្ចាសើ កាន់កាប់ ប្រើប្រាស់ ស្នងមរតក ឬទទួលសិទ្ធិបន្ត ឬកិច្ចទំនាក់ទំនងលើដីធ្លី ត្រូវបានធានា ចំពោះស្ត្រី និងបុរសយ៉ាងស្មើភាពគ្នា ហើយរាល់ទម្លាប់អនុវត្តដែលមិនបញ្ចូល កម្រិត ឬរិតត្បិតចំពោះស្ត្រីលើការធ្វើជាម្ចាស់ ការកាន់កាប់ ការប្រើប្រាស់ ការផ្ទេរ ការស្នងមរតក ការទទួលសិទ្ធិបន្ត ឬកិច្ចទំនាក់ទំនងលើដីធ្លី និងអចលនវត្ថុផ្សេងៗទៀត ត្រូវបានទុកជាមោឃៈ និងត្រូវបានលុបបំបាត់ចោល។ | សូមចែង អំពីអត្ថន័យនៃការធានាដោយរដ្ឋ ចំពោះកម្មសិទ្ធិលើអចនវត្ថុ ដូចជាថា រដ្ឋទទួលខុសត្រូវចំពោះការប៉ះពាល់ និងការខូចខាតបាត់បង់នូវកម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុ ដែលបង្កឡើងដោយអំពើចេតនា ឬការធ្វេសប្រហែសរបស់ភ្នាក់ងាររដ្ឋ ក្នុងពេលបំពេញភារកិច្ចដែលមានទំនាក់ទំនង ឬប៉ះពាល់ដោយខុសច្បាប់ លើអចលនវត្ថុរបស់បុគ្គលឯកជន សហគមន៍ជនជាតិដើមភាគតិច ឬវត្ត។<br><br>ចែងបន្ថែមថា រាល់បុគ្គលទាំងអស់ត្រូវគោរពកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត រួមទាំងសិទ្ធិតាមលក្ខណៈប្រពៃណី លើអចលនវត្ថុរបស់រដ្ឋ របស់នីតិបុគ្គលសាធារណៈ ព្រមទាំងរបស់បុគ្គលឯកជន និងសមូហភាព រួមទាំងរបស់សហគមន៍ជនជាតិដើម និងសហគមន៍ក្នុងមូលដ្ឋាន ស្ត្រី យុវជន និងក្រុមជនងាយរងគ្រោះនានា។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | លើសពីនេះ មាត្រានេះ គួរចែងពន្យល់ឱ្យច្បាប់អំពីគោលការណ៍នៃការធានាដោយរដ្ឋ និងគាំពារដោយច្បាប់ចំពោះកម្មសិទ្ធិលើអចលនវត្ថុ ព្រមទាំង សិទ្ធិស្របច្បាប់ផ្សេងទៀតលើអចលនវត្ថុ ជាពិសេសសិទ្ធិភោគៈស្របតាមលក្ខខណ្ឌនៃច្បាប់ និងសិទ្ធិកាន់កាប់ប្រើប្រាស់អាស្រ័យផលតាមបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលបានចាប់ផ្ដើមមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០១ និងមុនពេលមានច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា កំណត់ដី ឬអចលនវត្ថុពាក់ព័ន្ធជាក់លាក់ និងមានទីតាំងព្រំប្រទល់ច្បាស់លាស់ថាជាទ្រព្យសម្បត្តិសាធារណៈ ឬទីតាំងមានលក្ខណៈសាធារណៈ (របស់រដ្ឋ ឬរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត ឬដែលបានដាក់ឱ្យឋិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរកាន់កាប់ដីរដ្ឋ)។<br><br>រាល់ការប្រកាស ឬកំណត់ថាជាទ្រព្យរដ្ឋ ឬទ្រព្យរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត ទោះថាជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋក្ដី មិនត្រូវមានអានុភាពលុបចោល បដិសេធ ឬទុកជាមោឃៈ ចំពោះភោគៈស្របច្បាប់ដែលមានការកាន់កាប់តាំងពីមុនពេលមានលិខិតបទដ្ឋានគតិយុត្តិ ឬសេចក្ដីសម្រេចរដ្ឋបាលដែលធ្វើការប្រកាស ឬធ្វើការកំណត់ទ្រព្យនោះទេ ដើម្បីជៀសវាងនូវអំពើដកហូតសិទ្ធិឯកជនស្របច្បាប់ដោយគ្មានផ្ដល់ជាមុននូវសំណងសមរម្យ និងយុត្តិធម៌ ហាមឃាត់ដោយមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ។ | |
| មាត្រា ៩ | រដ្ឋធម្មនុញ្ញ មាត្រា ៤៤ ចែងថា ៖<br><br>ជនណាក៏ដោយ ទោះជាបុគ្គលក្ដី ជាសមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។<br><br>កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់។ | សូមកែចំណងជើងនៃមាត្រានេះ ដោយពង្រីកវិសាលភាពឱ្យដូចការចែងក្នុងច្បាប់ស្ដីពីអស្សាមិករណ៍ និងសូមចែងយោងទៅ ច្បាប់ស្ដីពីអស្សាមិករណ៍ ក្នុងមាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយផ្តល់សំណងជាមុន ដោយ សមរម្យ និងយុត្តិធម៌។ ច្បាប់ស្តីពីអស្សាមិករណ៍ មាត្រា ៣ និងមាត្រា ៤ គ្របដណ្តប់លើការដកហូតកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សលើអចនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ និងលើម្ចាស់អចលនវត្ថុ ឬ/និងម្ចាស់សិទ្ធិ (កម្មសិទ្ធិករ ភោគី និងអ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដីដែលជាអ្នកទទួលរងនូវផលប៉ះពាល់។<br><br>ដូច្នេះទាំងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិដែលមានជាធរមាន ធានាការពារ និងគ្របដណ្តប់លើការដកហូតកម្មសិទ្ធិ និងសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន សមូហភាព និងនីតិបុគ្គលសាធារណៈ។<br><br>សូមមើល មាត្រា ១១ មាត្រា ២៥ ដល់មាត្រា ២៨ និងមាត្រា ៣២ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចផង។<br><br>ក្នុងករណីដែលបុគ្គលណាមួយត្រូវបានដកហូតនូវសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួនសម្រាប់ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ ជាការសំខាន់ដែលសំណងមានផ្តល់ជូនទាំងលើការបាត់បង់ ឬខូចខាតជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ចំពោះកម្មសិទ្ធិ ឬសិទ្ធិប្រត្យក្សផ្សេងៗទៀត រួមទាំងសិទ្ធិភោគៈ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិផលុបភោគ សិទ្ធិក្រោមកិច្ចសន្យាសម្បទានសង្គមកិច្ច ហើយរបៀបគណនានូវសំណងនោះគួរមានតម្លាភាព មានលក្ខណៈអាចយល់បាន និងស្របតាមគោលការណ៍អន្តរជាតិ។ ច្បាប់នេះគួរចែងយោងយ៉ាងច្បាស់ទៅច្បាប់ស្តីពីអស្សាមិករណ៍ (២០១០) ពេលនិយាយអំពីសំណងសមរម្យ និងយុត្តិធម៌។ នៅមានចន្លោះសម្រាប់កែលម្អចំពោះបញ្ហាសំណងឱ្យហួសពីអ្វីដែលមានចែងក្នុងច្បាប់ស្តីពីអស្សាមិករណ៍ ជាឧទាហរណ៍ ការផ្តល់សំណងក្រោមគោលនយោបាយដោះស្រាយផលប៉ះពាល់នៃការធ្វើលទ្ធកម្មដីដោយគ្មានការស្ម័គ្រចិត្ត។ រាល់សំណង គួរមានបញ្ចូល យ៉ាងហោច មិនត្រឹមតែស្មើនឹងថ្លៃពេញលេញនៃសិទ្ធិណា | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | មួយដែលគេមានលើចលនវត្ថុ និងអចលនវត្ថុនោះទេ ប៉ុន្តែថែមទាំងសំណងចំពោះការប៉ះពាល់ផ្នែករាងកាយ ឬស្មារតី ការបាត់បង់ឱកាស ឬបាត់បង់ប្រាក់ចំណូល និងថ្លៃចំណាយលើដំណើរការផ្លាស់ប្តូរទីតាំង ផងដែរ។<br><br>សំណងសមរម្យ និងយុត្តិធម៌ គួរគោរពតាមគោលការណ៍អន្តរជាតិ នហើយគោលការណែនាំស្តីពីសំណងសមរម្យ និងយុត្តិធម៌ ត្រូវរៀបចំដោយក្រសួងមានសមត្ថកិច្ច ដោយយោងទៅសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការដោះស្រាយផលប៉ះពាល់ ដែលការិយាល័យ OHCHR ប្រចាំប្រទេសកម្ពុជា បានស្នើជា យោបល់ជូនរដ្ឋាភិបាលកម្ពុជាក្នុងការកំណត់សំណងយុត្តិធម៌៖<br>១. ក្នុងករណីដែលការបណ្តេញចេញ មិនជៀសវាងបាន ហើយជាការចាំបាច់សម្រាប់លើកកម្ពស់សុខមាលភាពទូទៅ សំណងត្រឹមត្រូវ យុត្តិធម៌ និងសមរម្យ ចំពោះរាល់ការបាត់បង់ចលនទ្រព្យ អចលនវត្ថុយ និងទ្រព្យសម្បត្តិ ឬរបស់របរផ្សេងៗទៀត រួមទាំងសិទ្ធិ ឬផលប្រយោជន៍នានាលើទ្រព្យ គួរត្រូវបានជានា។ គណៈកម្មការអន្តរក្រសួង និងអនុគណៈកម្មការនានា គួរមានការទទួលខុសត្រូវចំពោះរាល់បញ្ហាពាក់ព័ន្ធនឹងសំណង។ សំណង គួរតែត្រូវបានផ្តល់ឱ្យចំពោះរាល់ការខូចខាតដែលប៉ាន់ប្រមាណតម្លៃខាងសេដ្ឋកិច្ចបាន ស្របតាមសមាមាត្រនៃកម្រិតប៉ះពាល់សិទ្ធិ និងកាលៈទេសៈនៃករណីនីមួយៗ ដូចជា (ក) ការបាត់បង់ជីវិត ឬអវយវៈ; (ខ) ការប៉ះពាល់ផ្នែករាងកាយ ឬស្មារតី; (គ) ការបាត់បង់ឱកាសនានា រួមទាំងឱកាសការងារ ឱកាសអប់រំ និងឱកាសទទួលបានអត្ថប្រយោជន៍សង្គមកិច្ច; (ឃ) ការខូចខាតសម្ភារៈ និងការបាត់បង់ប្រាក់ចំណូល រួមទាំងការបាត់បង់ឱកាសរកប្រាក់ចំណូល; (ង) ការបាត់បង់ ឬខូចខាតក្រៅពីផ្នែកសេដ្ឋកិច្ច; និង (ច) ថ្លៃចំណាយលើជំនួយផ្នែកច្បាប់ ឬអ្នកជំនាញ ថ្នាំពេទ្យ និងសេវាវេជ្ជសាស្ត្រ ព្រមទាំងសេវាផ្នែកសង្គមកិច្ច និងចិត្តសាស្ត្រ។<br><br>២. សំណងជាប្រាក់ មិនគួរជំនួសឱ្យការសងជាទ្រព្យក្នុងទម្រង់ជាដី និង ធនធានរួមសម្រាប់សហគមន៍ឡើយ។ ករណីមានការដកហូតដី ជនរងផលប៉ះពាល់ គួរទទួលបានសំណងជាដីដែលមាន | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | គុណភាព ទំហំ និងតម្លៃ ប្រហែលគ្នា ឬប្រសើរជាង។ (មានការសិក្សាចំនួន ៥៧ ស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅទីតាំងនៃការតាំងទីលំនៅថ្មីនៅកម្ពុជា និងអំពីសេចក្តីព្រាងគោលការណ៍ណែនាំសម្រាប់ការដោះស្រាយផលប៉ះពាល់)។<br><br>៣. រាល់ជនដែលត្រូវបានបណ្តេញចេញ ដោយមិនគិតថាពួកគេមានសិទ្ធិលើទ្រព្យនោះឬអត់ទេ គួរទទួលបានសំណងចំពោះការបាត់បង់ ការខូចខាត និងថ្លៃដឹកជញ្ជូនចេញនូវទ្រព្យសម្បត្តិរបស់ពួកគេដែលរងផលប៉ះពាល់ រួមទាំងលំនៅដ្ឋានដើម និងដីដែលត្រូវបានបាត់បង់ ឬខូចខាតក្នុងដំណើការបណ្តេញចេញនោះ។ ការពិចារណាលើកាលទេសៈនៃករណីនីមួយៗ ត្រូវអនុញ្ញាតឱ្យមានការផ្តល់សំណងចំពោះការបាត់បង់នូវការកាន់កាប់ទ្រព្យបែបមិនរៀបរយ ដូចជា សំណង់បណ្តោះអាសន្ន ការបរបាញ់សត្វ ការនេសាទ និងការប្រមូលអនុផល។<br><br>៤. ស្ត្រី និងបុរសជាសហព័ទ្ធ ត្រូវតែជាសហអត្ថគាហកនៃកញ្ចប់សំណងទាំងអស់។ ស្ត្រីនៅលីវ និងមេមាយ គួរទទួលបានសំណងដោយផ្ទាល់។<br><br>៥. ត្រឹមកម្រិតដែលមិនគ្របដណ្តប់ដោយជំនួយសម្រាប់ការផ្លាស់ប្តូរទីតាំង ការប៉ាន់ប្រមាណអំពីការខូចខាតផ្នែកសេដ្ឋកិច្ច គួរពិចារណាលើការខូចខាត និងថ្លៃចំណាយ ជាឧទាហរណ៍ លើដី និងសំណង់ផ្ទះសម្បែង របស់របរនានា ហេដ្ឋារចនាសម្ព័ន្ធ ការពិន័យចំពោះបំពានលើហ៊ីប៉ូតែក ឬលើបំណុល ការចំណាយលើកន្លែងស្នាក់នៅជាបណ្តោះអាសន្ន  ឬថ្លៃសេវារដ្ឋបាល និងសេវាផ្នែកច្បាប់  ថ្លៃចំណាយលើផ្ទះថ្មីជំនួសឱ្យផ្ទះដែលបាត់បង់ ការបាត់បង់ប្រាក់ឈ្នួល និងចំណូល ការបាត់បង់ឱកាសអប់រំ សេវាពិនិត្យ និងថែទាំងសុខភាព ថ្លៃចំណាយលើការដឹកជញ្ជូន និងការតាំងទីលំនៅថ្មី (ជាពិសេសក្នុងករណីធ្វើការផ្លាស់ប្តូរទៅទីតាំងឆ្ងាយពីប្រភពរកចំណូលចិញ្ចឹមជីវិត)។ ករណីដែលផ្ទះ និងដីនោះ ផ្តល់ផងដែរនូវប្រភពចំណូលចិញ្ចឹមជីវិតរបស់ជនស្នាក់នៅដែលត្រូវបណ្តេញចេញ ត្រូវមានការគិតគូប៉ាន់ប្រមាណលើផលប៉ះពាល់ និងការខូចខាតជាតម្លៃនៃការខូច | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ខាតផ្នែកអាជីវកម្ម សម្ភារៈ/សារពើភ័ណ្ឌ សត្វចិញ្ចឹម ដី ដើមឈើ/ដំណាំ និង ការបាត់បង់ ឬថយចុះនូវប្រាក់ឈ្នួល/ប្រាក់ចំណូលដែលបានទទួលតាមរយៈការងារក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ( https://cambodia.ohchr.org/sites/default/files/report/other-report/Resettlement%20report_En%20FINAL.pdf ) | |
| មាត្រា ១១ | ច្បាប់នេះគួរតែទទួលស្គាល់ និងការពារទាំងដីភោគៈស្របច្បាប់ និងប្រពៃណី | ភោគៈស្របច្បាប់ និងប្រពៃណីអាចនាំទៅដល់ការទទួលបានកម្មសិទ្ធិ។<br>ភោគៈស្របច្បាប់ និងប្រពៃណីអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ ការផ្ទេរ ឬប្រតិបត្តិការពាណិជ្ជកម្មក្រោមលក្ខខណ្ឌ ឬអាណាព្យាបាលដែលមានចែងក្នុងច្បាប់នេះ។ |
| មាត្រា ១២ | បច្ចុប្បន្នពុំមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ ដែលចែងអំពីយន្តការ និងនីតិវិធីក្នុងការកំណត់សញ្ជាតិរបស់សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទេ។<br><br>ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហគមន៍កសិកម្ម គ្រាន់តែចែងផ្តល់នីតិបុគ្គលភាពដល់ សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីត្រឹមត្រូវជាមួយស្ថាប័នមានសមត្ថកិច្ចប៉ុណ្ណោះ។<br><br>ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨ អនុវត្តចំពោះតែរូបវន្តបុគ្គលប៉ុណ្ណោះ។<br><br>លើសពីនេះទៀតមាន អនុក្រឹត្យ លេខ ៨៣ អនក្រ បក ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច មាត្រា ៤ ចែងពីការទទួលបាននីតិបុគ្គលភាពរបស់សហគមន៍ជនជាតិដើមភាគតិច ក្រោយពីបានចងក្រង និងចុះបញ្ជីទទួលស្គាល់ជាផ្លូវការ នៅក្រសួងមហាផ្ទៃ ប៉ុន្តែពុំមានមូលដ្ឋានច្បាប់ដែលផ្តល់នីតិបុគ្គលភាពដល់សហគមន៍ជនជាតិដើមភាគតិចថាជានីតិបុគ្គលមានសញ្ជាតិខ្មែរ ជាហេតុធ្វើឱ្យសហគមន៍ជនជាតិដើមភាគតិច ពុំទទួលបាននូវ | សូមចែងក្នុងច្បាប់នេះ ផ្តល់សិទ្ធិអំណាច និងភារកិច្ចជូនក្រសួងមហាផ្ទៃក្នុងការបង្កបរិយាកាស ជម្រុញ និងកំណត់យន្តការ និងនីតិវិធីទន់ភ្លន់ងាយស្រួលឆាប់រហ័ស សម្រាប់ការចុះបញ្ជីផ្តល់នីតិបុគ្គលភាព ដល់សហគមន៍ជនជាតិដើមភាគតិចទាំងឡាយនៅកម្ពុជា ហើយលើកកម្ពស់ស្វ័យភាពរបស់សហគមន៍ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងអាស្រ័យផលដី និងអចលនវត្ថុផ្សេងៗទៀតរបស់សហគមន៍ ស្របតាមបទបញ្ជាផ្ទៃក្នុង ដែលមានលក្ខណៈជាវិជានប្រពៃណីរបស់សហគមន៍ ប៉ុន្តែឋិតក្រោមអាណាព្យាបាលរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ លើការចាត់ចែងចំណែករួមនៃដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។<br><br>និងសូមចែង ផ្តល់យន្តការ និងនីតិវិធីសម្រាប់កំណត់សញ្ជាតិរបស់សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | កម្មសិទ្ធិពេញលេញលើដីដែលត្រូវបានកាន់កាប់ និងប្រើប្រាស់ជាលក្ខណៈប្រពៃណី និងដោយស្របច្បាប់ទេ។<br><br>ដូច្នេះច្បាប់ភូមិបាលថ្មីនេះគួរតែអាចប្រើប្រាស់ដើម្បីបំពេញភាពខ្វះចន្លោះក្នុងច្បាប់ជាធរមាន។<br><br>សេចក្តីព្រាងច្បាប់នេះគួរតែត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយគម្លាតផ្លូវច្បាប់សម្រាប់ការផ្តល់ឋានៈនីតិបុគ្គល និងកំណត់សញ្ជាតិនៃសហគមន៍មូលដ្ឋាន/ក្នុងស្រុក រួមទាំងសហគមន៍ជនជាតិដើមភាគតិច សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ | បាលក្នុងស្រុក ដើម្បីផ្តល់លទ្ធភាពតាមផ្លូវច្បាប់ពេញលេញឱ្យសហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលជានីតិបុគ្គលសញ្ជាតិខ្មែរអាចធ្វើលទ្ធកម្មដីនៅកម្ពុជាដោយស្របច្បាប់ ផងដែរ។ |
| មាត្រា ១៣ | ដូចយោបល់ ចំពោះមាត្រា ១២។<br><br>ការសម្រេចរឹបអូសដីដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ គួរជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងរាជធានី ខេត្តដែលមានយុត្តាធិការលើទីតាំងទ្រព្យ តាមពាក្យសុំរបស់រដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកគ្រប់គ្រងវិស័យ សុរិយោដី ឬតំណាងរបស់រដ្ឋមន្ត្រីនេះ ក្រោយពីផុតអំឡុងពេលកំណត់ក្នុងមាត្រា ១៥ និងបន្ទាប់ពីមានការទាញហេតុផល ឬស្តាប់យោបល់របស់បុគ្គល និងភាគីពាក់ព័ន្ធ។<br><br>ដើម្បីដោះស្រាយបញ្ហាកង្វះភាពច្បាស់លាស់នៅក្នុងស្ថាប័នណាដែលទទួលខុសត្រូវក្នុងការកំណត់ ក្រសួងមហាផ្ទៃអាចទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណសញ្ជាតិរបស់សហគ្រាសពាណិជ្ជកម្ម ឬនីតិបុគ្គលផ្សេងទៀតតាមបទប្បញ្ញត្តិនេះ។<br><br>ទាក់ទងនឹងការចុះបញ្ជីការរឹបអូសនៅពេលរកមិនឃើញសញ្ជាតិខ្មែរ គួរតែមានយន្តការមួយសម្រាប់ជំទាស់នឹងនីតិវិធី និងរយៈពេលបណ្តោះអាសន្ន ដែលដីកំពុងស្ថិតក្រោមការត្រួតពិនិត្យ ប៉ុន្តែមិនត្រូវរឹបអូសមុនការសម្រេចចុងក្រោយទាក់ទងនឹងបណ្តឹងឧទ្ធរណ៍។ | សូមចែងថា ការសម្រេចរឹបអូសដីដើម្បីទប់ស្កាត់ការបង្កើតសិទ្ធិ ការផ្អកផ្តាក់ឱ្យចុះបញ្ជីការរឹបអូស និងការបង្គាប់ឱ្យលក់ដោយបង្ខំ ដោយផ្តល់សិទ្ធិអាទិភាពឱ្យសហកម្មសិទ្ធិករសញ្ជាតិខ្មែរ (ប្រសិនបើមាន) ទិញយកសិទ្ធិនោះ ជាសមត្ថកិច្ច ផ្តាច់មុខរបស់សាលាដំបូងរាជធានី ខេត្ត ដែលមានយុត្តាធិការលើទីតាំងទ្រព្យ តាមពាក្យសុំរបស់រដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកគ្រប់គ្រង វិស័យសុរិយោដី ឬតំណាងរបស់រដ្ឋមន្ត្រី ក្រោយពីផុតអំឡុងពេលកំណត់ក្នុងមាត្រា ១៥ និងបន្ទាប់ពីមានការទាញហេតុផល ឬស្តាប់យោបល់របស់បុគ្គល និងភាគីពាក់ព័ន្ធ។<br><br>ក្រោយពីការសម្រេចបាននូវការលក់ដោយបង្ខំ តាមដីកាសម្រេចផ្អកផ្តាក់ចុះបញ្ជី រដ្ឋបាលសុរិយោដី ត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិលើដីនោះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | | «ត្រូវធ្វើឡើងដោយក្រសួងមហាផ្ទៃតាមបញ្ញត្តិនៃច្បាប់...»។<br><br>"នឹងចេញសេចក្ដីសម្រេចបណ្ដោះអាសន្នមួយស្ដីពីការចុះបញ្ជីរឹបអូស ដែលកំពុងរង់ចាំបណ្ដឹងឧទ្ធរណ៍នៃសញ្ជាតិ។ នៅពេលប្ដឹងតវ៉ា សេចក្ដីសម្រេចចុងក្រោយត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដីមានសមត្ថកិច្ច ដើម្បីអនុវត្ត"។ |
| មាត្រា ១៤ ដល់មាត្រា ១៨ | គួរមានការយកចិត្តទុកដាក់ និងញែកឱ្យដាច់ពីគ្នារវាងចេតនារបស់ជនបរទេសក្នុងការក្លែងបន្លំឯកសារសញ្ជាតិខ្មែរ និងការរងគ្រោះរបស់ជនបរទេសដោយសារអំពើអូសទាញ ឬអំពើបំពានច្បាប់ក្លែង ឯកសារសញ្ជាតិខ្មែរឱ្យជនបរទេស ដោយបុគ្គលផ្សេងទោះជាមន្ត្រី ឬមិនមែនមន្ត្រី។<br><br>ទាក់ទងនឹងមាត្រា ១៤ ដើម្បីការពារជនរងគ្រោះពីការក្លែងបន្លំ បទប្បញ្ញត្តិនេះគួរតែបញ្ជាក់តែការក្លែងបន្លំដោយចេតនាប៉ុណ្ណោះ។ អ្នកដែលមិនមានបំណងបោកប្រាស់ ប៉ុន្តែត្រូវបានទាញយកប្រយោជន៍ពីអ្នកក្លែងបន្លំ មិនគួរត្រូវបានពិន័យទេ។ | សូមចែងឱ្យ សាលាដំបូងរាជធានី ខេត្ត មានសមត្ថកិច្ចផ្ដាច់មុខក្នុងការសម្រេចរឹបអូសដីរបស់បុគ្គលនោះ តាមពាក្យសុំរបស់រដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកគ្រប់គ្រងវិស័យសុរិយោដី ឬតំណាងរបស់រដ្ឋមន្ត្រី និងបន្ទាប់ពីមានការទាញហេតុផល ឬស្ដាប់យោបល់របស់បុគ្គល និងភាគីពាក់ព័ន្ធ។<br><br>ជនបរទេសដែលទំនងជា ឬត្រូវបានរកឃើញថាជាជនរងគ្រោះនៃអូសទាញ ឬអំពើបំពានច្បាប់ក្លែងឯកសារសញ្ជាតិខ្មែរដោយបុគ្គលផ្សេងទោះជាមន្ត្រី ឬ មិនមែនមន្ត្រី ត្រូវមានសិទ្ធិទទួលបានសំណងសមរម្យចំពោះការវិនិយោគរបស់ខ្លួនចេញពីផលនៃការលក់ដោយបង្ខំនូវទ្រព្យនោះ តាមការសម្រេចរបស់សាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។<br><br>ក្រោយពីការសម្រេចបាននូវការលក់ដោយបង្ខំ ដោយអនុវត្តដូចសំណើចែងក្នុងមាត្រា ១៣ រដ្ឋបាលសុរិយោដី ត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិលើដី។ |

| មាត្រា | ឃោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | | សូមចែងឱ្យអនុវត្តដូចគ្នា ចំពោះករណីមានការក្លែងបន្លំឯកសារសញ្ជាតិ ហើយនាំដល់ការទទួលបានកម្មសិទ្ធិលើចំណែកឯកជននៃទ្រព្យសហកម្មសិទ្ធិដោយខុសច្បាប់។<br><br>មាត្រា១៤៖ ជនបរទេសដែលក្លែងបន្លំឯកសារ... |
| ជំពូកទី២ | ការដាក់ចំណងជើងថា កម្មសិទ្ធិសាធារណៈ ធ្វើឱ្យមានការយល់ច្រឡំអំពីប្រភេទទ្រព្យ និងកម្មសិទ្ធិលើទ្រព្យ | សូមកែ ថា កម្មសិទ្ធិរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ |
| មាត្រា ២០ | រដ្ឋធម្មនុញ្ញ មាត្រា ៥៨ ចែងថា ៖<br><br>ទ្រព្យសម្បត្តិរបស់រដ្ឋ មានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។<br><br>ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរបស់រដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់។<br><br>តាមខ្លឹមសារនៃមាត្រារបស់រដ្ឋធម្មនុញ្ញ ដើម្បីចាត់ទុកថាជាទ្រព្យសម្បត្តិរបស់រដ្ឋ លុះត្រាតែមានការកំណត់ច្បាស់លាស់ដោយច្បាប់ ហើយមិនមែនមានន័យថាទ្រព្យទាំងអស់នោះ ត្រូវតែ ឬសុទ្ធតែជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នោះទេ។ ម៉្យាងទៀត ភ្នំ កោះ សមុទ្រដែនដី ឆ្នេរសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹង គឺជា ភាគចំណែកនៃដីធ្លី។<br><br>ជាងនេះទៅទៀត មិនមែនព្រៃឈើទាំងអស់សុទ្ធតែជាសម្បត្តិរបស់រដ្ឋនោះទេ (សូមមើលមាត្រា ១០ នៃច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២)។ | ដើម្បីឱ្យស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន និងជៀសវាងនូវការប៉ះពាល់ដល់សិទ្ធិស្របច្បាប់លើដីធ្លីរបស់ប្រជាពលរដ្ឋ សូមលុបចោលចំណុចទ្រទី១ នៃមាត្រានេះ ហើយជំនួសវិញដោយឃ្លាថា អចលនវត្ថុដែលបានចុះបញ្ជីត្រឹមត្រូវតាមនីតិវិធីក្នុងសៀវភៅគោលបញ្ជីដីធ្លី ថាជាកម្មសិទ្ធិរបស់រដ្ឋតំណាងដោយក្រសួងស្ថាប័នថ្នាក់ជាតិ ក្រៅពីនីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត (ដូចកំណត់ក្នុងមាត្រា ២១) ដែលមានស្វ័យភាពរដ្ឋបាល ពីអំណាចរបស់រដ្ឋបាលថ្នាក់កណ្តាល (ថ្នាក់ជាតិ)។<br>លើសពីនេះ សូមលុបចោល ឃ្លាទី១ នៃចំណុចទ្រទី ៧ ផងដែរ។<br><br>ចំពោះចំណុចទ្រទី ៨ ទាមទារឱ្យមានការបញ្ជាក់អំពីអត្ថន័យនៃពាក្យ "ច្បាប់" ថាសំដៅដល់ លិខិតូបករណ៍គតិយុត្ត |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | សូមមើលមាត្រា ១៧៩ ដល់១៨៦ នៃក្រមរដ្ឋប្បវេណី និងមាត្រា ២៩ ដល់មាត្រា ៣៥ នៃច្បាប់ភូមិបាល ឆ្នាំ១៩៩២ ព្រមទាំង មាត្រា ១២ មាត្រា ១៥ និងមាត្រា ៩៩ ដល់មាត្រា ១០៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ផង។<br><br>ហើយច្បាប់ជាធរមាន មិនទទួលស្គាល់របបកម្មសិទ្ធិលើដីធ្លី មុនឆ្នាំ១៩៧៩ ខណៈដែលចន្លោះពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៩ ដីធ្លីទាំងអស់នៅកម្ពុជា ជាសម្បត្តិរបស់រដ្ឋ (តាមស្មារតី មាត្រា ១ និងមាត្រា ៤នៃច្បាប់ភូមិបាល ឆ្នាំ១៩៩២ ចែងថា ដីធ្លីនៃរដ្ឋកម្ពុជា ជាសម្បត្តិរបស់រដ្ឋ ហើយ រ៉ែ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រជាតិដែលមាននៅក្នុងដី នៅលើដី នៅបាតសមុទ្រ និងនៅក្រោមបាតសមុទ្រ ក៏ជាសម្បត្តិរបស់រដ្ឋ) ដែលក្នុងនោះដីធ្លីខ្លះមានលក្ខណៈសម្បត្តិជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ (ដែលហាមមិនមានសិទ្ធិឯកជន តាមស្មារតីមាត្រា ៥ នៃច្បាប់ភូមិបាល ឆ្នាំ ១៩៩២ គឺ ដែនបំរុងរុក្ខា នេសាទអាង តំកល់ទឹកស្រោចស្រព បរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រជាតិ វត្តអារាម ទីស្មសាន សាលារៀន សួន និងទួលសាធារណៈ អតីតសំណង់រដ្ឋ ដីបំរុង និងដីចំណីសំរាប់ថ្នល់ ដីបំរុង និងដីសំរាប់ផ្លូវដែក ទន្លេ សមុទ្រ ពោលពុំមានរាប់បញ្ចូលកោះដែលដុះថ្មី ឬចាស់នោះទេ) ព្រមទាំងហាមមិនឱ្យមានការសាងសង់លើទីធ្លាដែលមាន លក្ខណៈសាធារណៈ លើកលែងតែសំណង់ ឬលំនៅដ្ឋានធុនស្រាល បណ្តោះអាសន្ន (មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤) ហើយសល់ពីនេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ លើកលែងតែមានការកំណត់ចំណាត់ថ្នាក់សារជាថ្មី ស្របតាមច្បាប់អនុប្រយោគ (មាត្រា ១៦ នៃច្បាប់ភូមិបាល ឆ្នាំ២០០១)។<br><br>ចាប់ពីឆ្នាំ១៩៨៩ រហូតដល់ថ្ងៃដែលច្បាប់ភូមិបាល ឆ្នាំ២០០១ ចូលជាធរមាន (៣១ សីហា ២០០១) ដីធ្លីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាច្រើន នៅគ្រប់ភូមិសាស្ត្ររដ្ឋបាល ត្រូវបានប្រជាពលរដ្ឋខ្មែរកាន់កាប់ ប្រើប្រាស់ អាស្រ័យផល ក្នុងរូបភាពជា ភោគៈស្របច្បាប់ ដែលរដ្ឋមាន | អនុម័តដោយអង្គនីតិបញ្ញត្តិ ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រម។<br><br>លុបកថាខណ្ឌទី៤<br><br>5. អចលនវត្ថុដែលទទួលបានដោយការអនុវត្តរបស់រដ្ឋស្របតាមផលប្រយោជន៍សាធារណៈឬជាតិ។<br><br>៧. អចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិឯកជនសិទ្ធិប្រពៃណី ឬដែលមិនត្រូវបានកាន់កាប់ដោយឯកជនស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | កាតព្វកិច្ចការពារ ដូចករណីសិទ្ធិកម្មសិទ្ធិដែរ ហើយរដ្ឋមិនអាចសម្រេចតាមឆន្ទានុសិទ្ធិក្នុងការបដិសេធ លុបចោល ទុកជាមោឃៈ ឬដកហូត តាមការចេញសេចក្តីសម្រេចរដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់ បានទេ។ សេចក្តីសម្រេចរដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់ ដែលកំណត់ចាត់ទុក ឬធ្វើចំណាត់ថ្នាក់ក្បាលដី ឬតំបន់ដីផ្លូណាមួយថាជាទ្រព្យសម្បត្តិរដ្ឋមានអានុភាពគតិយុត្តិដែលមិនអាចជំទាស់បាន តែក្នុងករណីក្បាលដីនោះ ឬផ្នែកនៃដីក្នុងតំបន់នោះ មិនមានបន្ទុកភោគៈស្របច្បាប់។<br><br>ប្រសិនបើគោលការណ៍អំពីបន្ទុកភោគៈស្របច្បាប់លើដីឯកជនរបស់រដ្ឋ ដែលបានលើកជាយោបល់ខាងលើនេះ មិនត្រូវបានការពារទេនោះ លិខិតបទដ្ឋានគតិមួយចំនួនធំដែលបានចេញកន្លងមក ដូចជា អនុក្រឹត្យដែលកំណត់ដែនបម្រុងព្រៃឈើអចិន្ត្រៃយ៍ចេញក្រោយឆ្នាំ ១៩៩៣ ជាពិសេសក្រោមច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ អនុក្រឹត្យលេខ ៥៣ អនក្រ បក ឆ្នាំ១៩៩៥ ស្តីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ (ដែលប្រកាសថា ដីដែលដុះចាស់ ឬថ្មី ជាកោះនៅសមុទ្រ ទន្លេ ព្រែកស្ទឹង បឹងបួរ ទូទាំងព្រះរាជាណាចក្រកម្ពុជា ជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតអោយឯកជន ឬសមូហភាពណា ប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ) ព្រមទាំងអនុក្រឹត្យដែលកំណត់តំបន់ដីរដ្ឋផ្សេងៗទៀត អាចមិនស្របនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលទេ ហើយគួរតែសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងបកស្រាយអំពីធម្មនុញ្ញភាពនៃលិខិតបទដ្ឋានគតិយុត្តទាំងនោះ។<br><br>"ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ" និង "ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ" គួរតែត្រូវបានប្រើជាលក្ខខណ្ឌពេញលេញដើម្បីបញ្ជាក់នៅពេលដែលដីត្រូវបានកាន់កាប់ដោយរដ្ឋធៀបនឹងភាគីផ្សេងទៀត។ ណែនាំបន្ថែមឱ្យប្រើពាក្យច្បាស់លាស់នៅផ្នែកទាំងនេះ និងផ្នែកផ្សេងទៀត។ ប្រសិនបើ "ដី" និង "អចលនវត្ថុ" មាននិយមន័យផ្សេងគ្នា ពួកវាគួរតែត្រូវបាននិយាយឡើងវិញពេញមួយអត្ថបទ កំណត់យ៉ាងច្បាស់ និងកំណត់នៅក្នុងសទ្ទានុក្រម។ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | លើសពីនេះ មាត្រា ១ ណែនាំថា "អចលនវត្ថុ" ទាំងអស់ក្នុងប្រទេសជាកម្មសិទ្ធិរបស់រដ្ឋ នេះគួរតែត្រូវបានកែសម្រួលដើម្បីឆ្លុះបញ្ចាំងតែអចលនវត្ថុដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។<br><br>កថាខណ្ឌទី៤ អាចបណ្ដាលឱ្យមានការរឹបអូសយកដីដែលកាន់កាប់ដោយម្ចាស់សិទ្ធិស្របច្បាប់ រួមទាំងអ្នកដែលប្រើប្រាស់ដីក្រោមប្រព័ន្ធប្រពៃណី។ ការទទួលស្គាល់សិទ្ធិប្រពៃណី និងការគូសផែនទីដែលមានការចូលរួមយ៉ាងប្រុងប្រយ័ត្ននៃដីនៅកម្រិតសហគមន៍អាចជួយជៀសវាងជម្លោះបន្ថែមទៀតលើការទាមទារដីធ្លី។ | |
| មាត្រា ២២ | ជាការចាំបាច់ត្រូវគោរព រដ្ឋធម្មនុញ្ញ មាត្រា ៥៨ ដែលហាមមិនឱ្យមានការដកហូតតាមទំនើងចិត្ត និងដោយគ្មានសំណងសមរម្យ និងយុត្តិធម៌ ជាមុន។<br><br>សូមមើល មាត្រា ១១ មាត្រា ២៥ ដល់មាត្រា ២៨ និងមាត្រា ៣២ នៃសេចក្ដីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិចផង។<br><br>អត្ថបទនេះគួរតែត្រូវបានលុប ឬកែប្រែ។ អចលនវត្ថុគួរត្រូវបានរឹបអូសដោយអាជ្ញាធរជាក់លាក់ប៉ុណ្ណោះ មិនមែន "អាជ្ញាធរសាធារណៈ" ដែលមិនបានកំណត់ដែលអាចទុកឱ្យដីងាយរងគ្រោះដោយសារការរឹបអូសមិនត្រឹមត្រូវ។ ហេតុផលដែលត្រូវបានអនុម័តសម្រាប់ការរឹបអូសក៏គួរតែត្រូវបានរាប់បញ្ចូល និងកំណត់នៅកន្លែងផ្សេងទៀតនៅក្នុងច្បាប់។ ដំណើរការនៃការចាត់ថ្នាក់ និង/ឬ ការចាត់ថ្នាក់ឡើងវិញ និងការបោះបង្គោលកំណត់ដីជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ការពង្រីកផ្លូវសាធារណៈ និងសិទ្ធិធ្វើផ្លូវ និងការទុកដីសម្រាប់ផ្លូវសាធារណៈគឺមិនច្បាស់លាស់ ហើយទុកកន្លែងសម្រាប់វិវាទដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការដោះស្រាយការទាមទារដីធ្លី និងការអភិវឌ្ឍសហគមន៍ដែលមានភាពរីកចម្រើន។ | សូម លុបចោល និងនិរាករណ៍បទបញ្ញត្តិដូចក្នុងមាត្រា ២២ នេះ។ សូមចែងថា ត្រូវអនុវត្តតាមខ្លឹមសារនិងស្មារតីនៃច្បាប់ស្ដីពីអស្សាមិករណ៍។<br><br>លុបអត្ថបទ<br>ឬ<br>"ក្នុងករណីដែលអចលនវត្ថុត្រូវបានរឹបអូស ដោយហេតុផលត្រឹមត្រូវដោយអាជ្ញាធរសមស្រប នោះអចលនវត្ថុ..." |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| មាត្រា ២៣ | ចំណងជើងនៃមាត្រានេះ មិនស្របតាមខ្លឹមសារនៃមាត្រា ដែលចែងអំពីទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន របស់នីតិបុគ្គលសាធារណៈ។<br><br>បញ្ជាក់ពាក្យដែលកំពុងប្រើប្រាស់ "ទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គល" គឺមិនច្បាស់លាស់ និងមានការយល់ច្រឡំដោយសារលក្ខណៈបុគ្គលឯកជនសាធារណៈ។ | សូមកែចំណងជើងនៃមាត្រានេះថា ទ្រព្យសម្បត្តិរបស់រដ្ឋ និងរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត។ |
| មាត្រា ២៤ | ដូចយោបល់ចំពោះមាត្រា ២០។<br><br>សូមមើលមាត្រា ១៧៩ ដល់១៨៦ នៃក្រមរដ្ឋប្បវេណីផង។<br><br>ការផ្លាស់ប្តូរចំណាត់ថ្នាក់ដី (ក្នុងករណីនេះទៅជាទ្រព្យសម្បត្តិសាធារណៈ) ដោយគ្មានដំណើរការដើម្បីបញ្ជាក់/វាយតម្លៃថាមិនមានការទាមទារស្របច្បាប់ផ្សេងទៀត ឬដំណើរការដើម្បីប្រកួតប្រជែងការទាមទារអាចបណ្តាលឱ្យមានការដកហូត និងវិវាទដីធ្លីបន្ថែមទៀត។ ឧទាហរណ៍៖ បើមានការពង្រីកផ្លូវ ហើយរដ្ឋចង់ដកហូតដីពីគ្រួសារដើម្បីពង្រីកផ្លូវ ប្រសិនបើគ្រួសារមិនអនុញ្ញាតឱ្យរដ្ឋយកដីសម្រាប់សាងសង់ផ្លូវទេ ពួកគេនឹងមិនទទួលបានលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីទេ។ ដូច្នេះពួកគេត្រូវលះបង់ដីតាមចំនួនណាដែលរដ្ឋទាមទារជាថ្នូរនឹងការចេញប័ណ្ណកម្មសិទ្ធិ (ប្លង់កម្មសិទ្ធិដី)។ នេះជាការមិនសមរម្យនិងគួរត្រូវបានជៀសវាង ដូច្នេះឃ្លានេះគួរតែត្រូវបានដកចេញ ឬកែប្រែ។<br><br>បន្ថែម "តំបន់ព្រៃកោងកាង" ទៅក្នុងបញ្ជីអចលនវត្ថុដែលមានប្រភពចេញពីដីធម្មជាតិ ដើម្បីជួយបញ្ជាក់ពីយុត្តាធិការលើព្រៃឈើអន្តរដែន។ | ចំណុចលេខ ១ នៃមាត្រា សូមលុបពាក្យថា ដីព្រៃឈើ ភ្នំ និងកោះ ចេញ ហើយជំនួសដោយ ដែនបម្រុងព្រៃឈើអចិន្ត្រៃយ៍របស់រដ្ឋ ដែលពុំមានបន្ទុកភោគៈស្របច្បាប់។<br><br>ក្នុងចំណុចលេខ ៥ នៃមាត្រានេះ សូមចែងបន្ថែមខាងចុងឃ្លាថា ដែលពុំមានបន្ទុកភោគៈស្របច្បាប់។<br><br>ក្នុងឃ្លាចុងក្រោយនៃមាត្រានេះ ដើម្បីធានាអភិបាលកិច្ចល្អ សូមចែងបញ្ជាក់អំពី អាជ្ញាធរមានសមត្ថកិច្ច ក្នុងការចាត់ប្រភេទទ្រព្យសម្បត្តិផ្សេងទៀតជាទ្រព្យសម្បត្តិសាធារណៈ (ដូចជា គណៈកម្មការគ្រប់គ្រងដីរដ្ឋ ឬនិង រាជរដ្ឋាភិ បាល)។<br><br>ដក៖ «បន្ថែមលើទ្រព្យសម្បត្តិសាធារណៈខាងលើជាអចលនវត្ថុ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់ថ្នាក់អចលនវត្ថុផ្សេងទៀតជាទ្រព្យសម្បត្តិសាធារណៈ ដើម្បីដាក់ឱ្យប្រើប្រាស់ស្របតាមរបបច្បាប់ដែលកំណត់ដោយច្បាប់នេះ និងឯកសារច្បាប់ពាក់ព័ន្ធ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | | "ភ្នំ ទឹកជ្រោះ បឹង អាងស្តុកទឹក ទន្លេ អូរ ព្រែក ព្រៃក តំបន់ព្រៃកោងកាង ប្រឡាយដែលកប៉ាល់ ឬក្បូនអាចអណ្តែត និងរុករក..." |
| មាត្រា ២៥ | ជាការចាំបាច់ត្រូវគោរព រដ្ឋធម្មនុញ្ញ មាត្រា ៥៨ និងគោលការណ៍ច្បាប់ស្តីពីសិទ្ធិភោគៈស្របច្បាប់ ដើម្បីរារាំង ឬហាមឃាត់ចំពោះលទ្ធកម្មកម្មសិទ្ធិតាមរយៈភោគៈ អចលនវត្ថុនោះត្រូវតែបានកំណត់ច្បាស់លាស់ជាក់ស្តែង នូវទីតាំង ព្រំប្រទល់ និងទំហំ មុនពេលចាប់ផ្តើមភោគៈស្របច្បាប់លើអចលនវត្ថុនោះ។<br><br>សូមមើលយោបល់ក្នុងមាត្រា ៥ និង ក្រមរដ្ឋប្បវេណី មាត្រា ១៦២ ផង។<br><br>ជាការចាំបាច់ដែលត្រូវបញ្ឈប់ជាបន្ទាន់នូវការចាត់ទ្រព្យសម្បត្តិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ថាជាទ្រព្យសម្បត្តិសាធារណៈ ឬថាជាទ្រព្យសម្បត្តិរបស់រដ្ឋ ព្រោះជនជាតិដើមភាគតិចជារូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ហើយនីតិបុគ្គលនៃសហគមន៍ជនជាតិដើមភាគតិចចាំបាច់ត្រូវតែមានសញ្ជាតិខ្មែរ ដោយស្របច្បាប់ ដូច្នេះជនជាតិដើមភាគតិច ដែលមិនចូលរួមរស់តាមទំនៀមទម្លាប់ប្រពៃណីរបស់សហគមន៍ ឬដែលសុំចាកចេញពីសហគមន៍ ឬដែលត្រូវបានបណ្តេញចេញពីសហគមន៍ មានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុតាមរបបកម្មសិទ្ធិឯកជនដូចប្រជាពលរដ្ឋខ្មែរទូទៅដែរ ហើយនីតិបុគ្គលនៃសហគមន៍ជនជាតិដើមភាគតិច ត្រូវមានសិទ្ធិធ្វើជាកម្មសិទ្ធិករដោយពេញច្បាប់លើអចនវត្ថុដែលសមាជិករបស់សហគមន៍កាន់កាប់ ប្រើប្រាស់អាស្រ័យផល តាមបែបប្រពៃណី តាំងពីមុនច្បាប់ភូមិបាល ឆ្នាំ២០០១ ចូលជាធរមាន។<br>សូមមើល មាត្រា ១១ មាត្រា២៥ ដល់មាត្រា ២៨ និងមាត្រា ៣២ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចផង។ | សូមកែសម្រួលមាត្រានេះត្រង់កថាខណ្ឌដែលចែងពាក់ព័ន្ធរបបលទ្ធកម្មពិសេសនៃភោគៈ។<br>លើសពីនេះ សូមចែងបន្ថែមអំពីការហាមឃាត់មិនឱ្យមានការធ្វើលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលនៃនីតិសាធារណៈដែលបានចុះបញ្ជីកម្មសិទ្ធិពេញលេញរួចហើយ។<br><br>សូមលុបចោលករណីលើកលែងក្នុងកថាខណ្ឌទី៣ នៃមាត្រានេះ ពាក់ព័ន្ធនឹងកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។<br><br>ដកៈ "អចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត ដែលបានបាត់បង់ផលប្រយោជន៍សាធារណៈ ឬលែងជាកម្មវត្ថុនៃសេវាសាធារណៈ អាចនឹងក្លាយជាកម្មសិទ្ធិឯកជនរបស់រដ្ឋ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ដើម្បីកាត់បន្ថយឧបទ្ទវហេតុនៃវិវាទដីធ្លី និងការទាមទារដីមានទំនាស់ គួរតែមានដំណើរការច្បាស់លាស់ និងតម្លាភាពក្នុងការបំប្លែងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាកម្មសិទ្ធិឯកជនរបស់រដ្ឋ។ អាចលុបនៅទីនេះ ហើយបញ្ចូលការផ្តល់ផ្សេងទៀតដែលដោះស្រាយដំណើរការនោះ។<br><br>"យុត្តាធិការដែលផុតកំណត់" ដាក់កម្រិតសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចរបស់យើង។ | |
| មាត្រា ២៦ | ដោយផ្អែកលើយោបល់ក្នុងមាត្រា ២៥ ការចែងក្នុងមាត្រា ២៦ គួរសំដៅដល់ទ្រព្យសម្បត្តិរបស់រដ្ឋ ឬរបស់នីតិបុគ្គលនៃនីតិសាធារណៈ ដែលបានចុះបញ្ជីកម្មសិទ្ធិរួច ហើយហាមមិនឱ្យមានការធ្វើលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាល ស្របតាមក្រមរដ្ឋប្បវេណី។<br>សូមមើល ក្រមរដ្ឋប្បវេណី មាត្រា ១៦២។<br><br>អត្ថបទនេះអាចធ្វើឱ្យមន្ត្រីរដ្ឋបាលសុរិយោដីមានគុណវិបត្តិ ដោយសារពួកគេអាចក្លាយជាជនរងគ្រោះនៃការក្លែងបន្លំ ឬមិនដឹងអំពីព្រំប្រទល់ទ្រព្យសម្បត្តិសាធារណៈ ដោយសារមន្ត្រីសុរិយោដីជាច្រើនមិនមានធនធានគ្រប់គ្រាន់ក្នុងការចាត់ចែង។ | សូមកែសម្រួលមាត្រានេះ ដើម្បីកម្រិតចំពោះតែការធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុដែលត្រូវបានកំណត់ច្បាស់លាស់ ជាក់ស្តែងថាជាទ្រព្យសម្បត្តិសាធារណៈ និងកម្រិតចំពោះការធ្វើលទ្ធកម្មកម្មសិទ្ធិតាមអាជ្ញាយុកាលលើអចលនវត្ថុដែលត្រូវបានចាត់ថ្នាក់ និងចុះបញ្ជីកម្មសិទ្ធិថាជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលនៃនិតិសាធារណៈដទៃទៀត។ |
| មាត្រា ២៧ | ដូចយោបល់ក្នុងមាត្រា ២៦ | សូមចែងឱ្យស្របតាមគោលការណ៍ដែលបានស្នើកែសម្រួលក្នុងមាត្រា ២៦។<br><br>ក្នុងករណីដែលគ្មានការដៅបង្ហាញត្រឹមត្រូវ ច្បាស់លាស់នូវចំណុចព្រំដី ឬនិងគ្មានការចូលរួម ឬការតវ៉ាជំទាស់ ដោយតំណាងរបស់អាជ្ញា ធរកាន់កាប់ដីរដ្ឋ ឬសមាជិកនៃយន្តការគ្រប់គ្រងដីរដ្ឋ ក្នុងនីតិវិធីចុះបញ្ជីដីនោះ មន្ត្រីមានសមត្ថកិច្ចដែលបញ្ជាក់អំពីស្ថានភាពកាន់កាប់ដីជាក់ ស្តែង ឬចុះបញ្ជី និងចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប័ណ្ណសម្គាល់សិទ្ធិភោគៈ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ មុនពេលច្បាប់ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | | នេះចូលជាធរមាន ឬ ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ក្រោយពេលច្បាប់នេះចូលជាធរមាន ត្រូវរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ( ទាំងផ្នែករដ្ឋបាល រដ្ឋប្បវេណី និងព្រហ្មទណ្ឌ )លើកលែងតែមន្រ្តីនោះបានអនុវត្តកិច្ចនោះដោយចេតនាបំពានច្បាប់ ពុករលួយ ឬចេតនាសមគំនិតបំពានលើទ្រព្យសម្បត្តិរបស់រដ្ឋដែលបានកំណត់ច្បាស់។<br><br>"មន្ត្រីមានសមត្ថកិច្ចដែលចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិ ឬឯកសារដោយចេតនា..." |
| មាត្រា ២៨ | សូមមើលមាត្រា ៦២ អំពីសម្បទានដែលមិនឋិតក្រោមច្បាប់នេះ | សូមចែងបញ្ជាក់ក្នុងកថាខណ្ឌទី២ ថា ជាកម្មវត្ថុនៃសម្បទានដីដែលឋិតក្រោមវិសាលភាពនៃច្បាប់នេះ និងក្នុងលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ ។ |
| មាត្រា ២៩ | ជាក់ស្តែង តាមរយៈការអនុវត្តយុទ្ធសាស្ត្រស្បែកខ្លា ឬការអនុវត្តនូវគោលនយោបាយដោះស្រាយផលប៉ះពាល់ ឬដោះស្រាយសំណង់អនាធិបតេយ្យ ការរំលោភបំពាន កាន់កាប់ ឬប្រើប្រាស់អចលនវត្ថុជាទ្រព្យសម្បត្តិរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ មួយចំនួន ត្រូវបានធ្វើនិយ័តកម្មឱ្យស្របច្បាប់ និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ជាហូរហែរ ដូច្នេះ ការចែងថា មិនអាចធ្វើនិយ័តកម្ម ទោះតាមរូបភាពក៏ដោយ ពុំមានប្រសិទ្ធភាពឡើយ។<br><br>សូមមើល មាត្រា ៦០ ដល់ ៦២ នៃសេចក្តីព្រាងច្បាប់នេះផង។<br><br>អត្ថបទនេះហាមប្រាមការពិចារណាលើ "សិទ្ធិអ្នកកាប់បំផ្លាញ" ក្នុងការកាន់កាប់ដីធ្លី។ នេះជាបញ្ហាចាប់តាំងពីច្បាប់នេះរក្សាការកាត់ផ្តាច់សិទ្ធិកាន់កាប់ស្របច្បាប់ក្នុងឆ្នាំ ២០០១។ ដោយមើល | សូមលុប ឃ្លាថា មិនអាចធ្វើនិយ័តកម្ម ទោះតាមរូបភាពក៏ដោយ  ក្នុងកថាខណ្ឌទី១ ចោល ហើយជំនួសដោយការចែងបន្ថែមថា លើកលែងតែមានគោលការណ៍សម្រេចផ្សេងពីនេះពីរាជរដ្ឋា ភិបាល ដើម្បីដោះស្រាយសំណូមពរ និងជីវភាពរស់នៅ របស់ប្រជាពលរដ្ឋដែលកាន់កាប់ ឬប្រើប្រាស់ដីជាក់ស្តែង។<br><br>ក្នុងឃ្លាចុងក្រោយនៃចំណុចទី១ សូមជំនួសឃ្លាថា ដែលបានកំណត់កន្លងមក ដោយឃ្លាថា ដែលបានកំណត់មុនពេលចាប់ផ្តើមការចូលកាន់កាប់ជាភោគៈ យ៉ាងចំហ ជាសា |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ឃើញពីចំនួនដ៏ច្រើននៃចលនា និងការផ្លាស់ទីលំនៅនៅទូទាំងប្រទេសកម្ពុជាក្នុងរយៈពេល ២៣ ឆ្នាំ នេះខកខានឱកាសមួយដើម្បីគ្រប់គ្រងស្ថានការណ៍នៅលើដីប្រកបដោយភាពច្នៃប្រឌិត។ ជរាបណាអ្នកកាន់កាប់ដីបច្ចុប្បន្នបានកាន់កាប់ដីក្នុងរយៈពេលសមស្រប ពួកគេគួរតែត្រូវបានផ្ដល់ឱកាសដើម្បីអះអាងការកាន់កាប់ និង/ឬសិទ្ធិប្រើប្រាស់ផ្សេងទៀត ដូចជាផលុបភោគ ឬទទួលបានសិទ្ធិជួលអចិន្ត្រៃយ៍សម្បទាន។<br><br>កថាខណ្ឌទី ៣ មានលក្ខណៈទូលំទូលាយ ហើយបង្កប់ន័យថា ការបំពានលើបទប្បញ្ញត្តិនៃច្បាប់នេះ ដោយដឹង ឬមិនដឹង នឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ្នកកាន់កាប់សម្បទាន។ វាគួរតែមានជម្រើសមួយដើម្បីដោះស្រាយការបំពាននេះក្នុងរយៈពេលកំណត់។<br><br>កថាខណ្ឌទី ៤៖ កាលបរិច្ឆេទកាត់ផ្ដាច់នេះគួរតែត្រូវបានពិចារណាឡើងវិញ ដើម្បីគ្រប់គ្រងកិច្ចខិតខំប្រឹងប្រែងផ្ដល់ប័ណ្ណកម្មសិទ្ធិដីជនបទឱ្យកាន់តែមានប្រសិទ្ធភាព និងបង្កើនសុច្ឆន្ទៈក្នុងសហគមន៍ជនបទ។ ភោគី "ខុសច្បាប់" ជាច្រើនបានកាន់កាប់ដីដោយសន្តិភាព និងផលិតភាពអស់ជាច្រើនឆ្នាំ។ | ធារណៈ ដាក់ស្ដែង ហើយគ្មានការជំទាស់ពីសមត្ថកិច្ច (តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យរដ្ឋ ឬសមាជិកនៃយន្តការគ្រប់គ្រងដីរដ្ឋ) ក្នុងអំឡុងពេលសមស្រប (ដូចជា ក្នុងអំឡុងពេល ៣ ឆ្នាំ គិតពីពេលចាប់ផ្ដើម ការកាន់កាប់នោះ)។<br>ក្នុងចំណុចលេខ ៣ នៃមាត្រានេះ សូមចែងថា រាល់ការផ្ដល់ ឬការទទួលបានសម្បទានដីសេដ្ឋកិច្ច ឬសម្បទានដីសង្គមកិច្ច ដែលមិនស្របនឹងបញ្ញត្តិនៃច្បាប់នេះ។<br><br>ផ្លាស់ប្ដូរ "សម្បទានដែលឆ្លើយតបទៅនឹងផលប្រយោជន៍សង្គម" ទៅជា "សម្បទានដីសង្គមកិច្ច"។ |
| មាត្រា ៣០ | បុគ្គលដែលទទួលបាននូវការផ្ទេរសិទ្ធិដោយសុចរិត ដោយគ្មានកំហុស និងមិនបានដឹងអំពីការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិជាអចលនវត្ថុរបស់រដ្ឋដោយខុសច្បាប់ ដែលមានប័ណ្ណឬលិខិតបញ្ជាក់ការកាន់កាប់ ចេញដោយអាជ្ញាធរដែនដី ឬរដ្ឋបាលសុរិយោដី ដែលជាភ្នាក់ងាររបស់រដ្ឋ គួរត្រូវបានធានាដោយរដ្ឋ និងការពារដោយច្បាប់នេះ ហើយគួរមានសិទ្ធិទាមទារឱ្យធ្វើបដិទាននូវតម្លៃវិនិយោគក្នុងការធ្វើលទ្ធកម្មទ្រព្យនោះ (ករណីទិញ ឬដោះដូរទ្រព្យ) ពីអ្នកផ្ទេរសិទ្ធិក្នុងអំឡុងពេលអាជ្ញាយុកាលនៃសិទ្ធិទាមទារតាមការចែងក្នុងក្រមរដ្ឋប្បវេណីចំពោះអ្នកផ្ទេរសិទ្ធិ ឬពីរដ្ឋក្រោយផុតអំឡុងពេលអាជ្ញាយុកាលនៃសិទ្ធិទាមទារចំពោះអ្នកផ្ទេរសិទ្ធិ ព្រមទាំងសិទ្ធិទាមទារសំណងទូទាត់ ឬសោហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំដែលបានធ្វើនៅលើ | សូមកែកថាខណ្ឌទី១ នៃមាត្រានេះ ឱ្យផ្ដល់កិច្ចធានា និងការពារចំពោះបុគ្គលដែលទទួលបាននូវការផ្ទេរសិទ្ធិដោយសុចរិត ដោយគ្មានកំហុស និងមិនបានដឹងអំពីការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិជាអចលនវត្ថុរបស់រដ្ឋដោយខុសច្បាប់ដែលមានប័ណ្ណ ឬលិខិតបញ្ជាក់ការកាន់កាប់ ចេញដោយអាជ្ញាធរដែនដី ឬរដ្ឋបាលសុរិយោដី ដែលជាភ្នាក់ងាររបស់រដ្ឋ ព្រមទាំងទទួលស្គាល់សិទ្ធិទាមទារឱ្យធ្វើបដិទាននូវតម្លៃវិនិយោគក្នុងការធ្វើលទ្ធកម្មទ្រព្យនោះ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | អចលនវត្ថុនោះ ស្របតាមគោលការណ៍ក្នុងគោលនយោបាយដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារគម្រោងអភិវឌ្ឍនានា។<br><br>ការបណ្តេញចេញដោយបង្ខំ គឺជាការរំលោភលើសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ (រួមទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ (មាត្រា ១១ កថាខណ្ឌទី១) អនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា ២៧ កថាខណ្ឌទី៣) បទប្បញ្ញត្តិមិនរើសអើងដែលមាននៅក្នុងមាត្រា ១៤ កថាខណ្ឌទី២ (h) នៃ CEDAW និងមាត្រា ៥ (e) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍) ហើយអាចអនុវត្តបានតែក្នុងកាលៈទេសៈពិសេស និងស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ (គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងផ្លាស់ទីលំនៅដោយសារការអភិវឌ្ឍ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានគ្រប់គ្រាន់ជាធាតុផ្សំនៃសិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ Miloon Kothari (២០០៧)) ។<br><br>ការការពារគួរតែត្រូវបានបង្កើតឡើងនៅទីនេះផងដែរ សម្រាប់តួអង្គដែលគ្មានសាក្សីដែលពាក់ព័ន្ធក្នុងការក្លែងបន្លំលទ្ធកម្មទ្រព្យសម្បត្តិសាធារណៈ។ | និងសិទ្ធិទាមទារសំណងទូទាត់ ឬសោហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំដែលបានធ្វើនៅលើអចលនវត្ថុនោះ។<br><br>ការកាន់កាប់ដីចំណីផ្លូវដែលចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ត្រូវអនុវត្តចំពោះតែករណីការចូលកាន់កាប់នោះចាប់ផ្តើមក្រោយពេលដែលដីចំណីផ្លូវត្រូវបានកំណត់ និងសម្រេចអនុម័តជាផ្លូវការស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន។<br><br>សូមកំណត់ឱ្យច្បាស់អំពីអាជ្ញាធរមានសមត្ថកិច្ច ដែលចែងក្នុងកថាខណ្ឌចុងក្រោយនៃមាត្រានេះ។<br><br>«អាចនឹងចាប់ផ្តើមការបណ្តេញចេញដែលអនុវត្តតាមនីតិវិធីត្រឹមត្រូវមួយដើម្បីដកជនល្មើសចេញពីដី»។<br><br>"បុគ្គលដែលប្រព្រឹត្តដោយចេតនា ឬទទួលបានការចុះបញ្ជី និងចេញអាជ្ញាប័ណ្ណសម្រាប់ការរំលោភលើការកាន់កាប់ខុសច្បាប់" |
| មាត្រា ៣១ | គួរមានការចែងថាកម្មសិទ្ធិសមូហភាពលើអចលនវត្ថុរបស់វត្ត ឋិតក្រោម អាណាព្យាបាលរដ្ឋបាលរបស់រដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកវិស័យសាសនា លើការចាត់ចែងអចលនវត្ថុរបស់វត្ត តាមការចាំបាច់ ដើម្បីជាឧត្តមប្រយោជន៍របស់សហគមន៍ពុទ្ធសាសនិកចំណុះជើងវត្ត។ | សូមចែងបន្ថែមថា កម្មសិទ្ធិសមូហភាពលើអចលនវត្ថុរបស់វត្ត ឋិតក្រោម អាណាព្យាបាលរដ្ឋបាល របស់រដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកវិស័យសាសនា។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | នៅពេលដែលដីលែងប្រើប្រាស់សម្រាប់វត្ត យើងគួរតែផ្តល់ជម្រើសមួយសម្រាប់សហគមន៍ក្នុងការប្រើប្រាស់ដីដើម្បីផលប្រយោជន៍រួម។ ឧទាហរណ៍ បើអាចគេអាចយកដីដែលធ្លាប់ជាវត្តសម្រាប់ដាំបន្លែសម្រាប់សហគមន៍។ ម្យ៉ាងទៀត ប្រសិនបើសំណង់ប្រាសាទមួយត្រូវបានខូចខាត ឬខូចខាតយ៉ាងខ្លាំងនោះ សហគមន៍គួរតែមានឱកាសចរចាក្នុងការផ្លាស់ប្តូរដីរវាងសហគមន៍ និងគណៈកម្មការវត្ត។ | |
| មាត្រា ៣២ | គួរមានការចែងអំពីការចាត់ចែងអចលនវត្ថុរបស់វត្តក្នុងករណីដែលវត្តអារាមនោះត្រូវបានបិទទ្វារលែងមានការប្រើប្រាស់រយៈពេលច្រើនឆ្នាំ ឬត្រូវបានបោះបង់ចោលជាអចិន្ត្រៃយ៍ ហើយគណៈកម្មការវត្តក៏ត្រូវបានរំលាយ ឬលែងមានដំណើរការ។ | សូមចែងបន្ថែមថា ការចាត់ចែងអចលនវត្ថុរបស់វត្តអារាមក្នុងករណីដែលវត្តនោះត្រូវបានបិទទ្វារលែងមានការប្រើប្រាស់រយៈពេលច្រើនឆ្នាំ ឬត្រូវបានបោះបង់ចោលជាអចិន្ត្រៃយ៍ ហើយ គណៈកម្មការវត្តក៏ត្រូវបានរំលាយ ឬលែងមានដំណើរការ ត្រូវធ្វើឡើងតាមសំណើរបស់តំណាងពុទ្ធបរិស័ទចំណុះជើងវត្ត ទៅរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសាសនា ដើម្បីសម្រេចអនុម័ត។ |
| មាត្រា ៣៤ និងមាត្រា ៣៥ | ប្រជាពលរដ្ឋខ្មែរភាគច្រើននិយមបូជាសព ហើយមានតែប្រជាពលរដ្ឋដែលជាប់ខ្សែស្រឡាយចិនវៀតណាម និងដែលរក្សាជំនឿ ទំនៀមទម្លាប់ប្រពៃណីចិន វៀតណាមមួយចំនួន ព្រមទាំង ប្រជាពលរដ្ឋដែលកាន់គ្រីសសាសនាមួយចំនួន និងជនជាតិដើមភាគតិច ដែលនៅរក្សាជំនឿ ទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន ទើបយកសពទៅបញ្ចុះ ឬកប់ ដូច្នេះមិនមែនប្រជាពលរដ្ឋទូទៅទេ។<br><br>បញ្ញត្តិស្តីពីដីបញ្ចុះសព គួរមានការចែងបញ្ជាក់ថាមិនអនុវត្តចំពោះដីកប់សពរបស់សហគមន៍ជនជាតិដើមភាគតិចទេ ដែលឋិតក្នុងរបបគតិយុត្តពិសេសនៃកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងឋិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរប្រពៃណី ឬគណៈកម្មការប្រពៃណីតាមវិធានប្រពៃណីរបស់សហគមន៍ ដែលខុសពីវិធាន ឬលក្ខខណ្ឌ និងនីតិវិធីកំណត់ដោយអាជ្ញាធររដ្ឋ។ | សូមលុបពាក្យថា ប្រជាពលរដ្ឋទូទៅ ក្នុងមាត្រា ៣៤ ចេញ ហើយជំនួសដោយ ប្រជាពលរដ្ឋដែលជាប់ខ្សែស្រឡាយចិនវៀតណាម និងរក្សាជំនឿ ទំនៀមទម្លាប់ប្រពៃណីចិន វៀតណាមមួយចំនួន ព្រមទាំងប្រជាពលរដ្ឋដែលកាន់គ្រីសសាសនាមួយចំនួន។<br>សូមបញ្ជាក់ថាបញ្ញត្តិនេះមិនអនុវត្តចំពោះដីកប់សពដែលជាកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិចទេ។<br>សូមចែងបញ្ជាក់ថាច្បាប់អនុញ្ញាតឱ្យធ្វើចេតតីយ និងមានការបញ្ចុះសពលើក្បាលដីឯកជនរបស់រូបវន្តបុគ្គល ឬគ្រួសារ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | លើសពីនេះ គួរមានការចែងបញ្ជាក់ថាតើច្បាប់អនុញ្ញាតឱ្យធ្វើចេតតីយ និងមានការបញ្ចុះសពលើក្បាលដីឯកជនរបស់រូបវន្តបុគ្គល ឬគ្រួសារ ឬទេ។ ប្រសិនបើអនុញ្ញាត ច្បាប់គួរតែចែងអំពីលក្ខខណ្ឌកំណត់មួយចំនួន ដើម្បីជៀសវាងការប៉ះពាល់ចំពោះក្បាលដីជិតខាង។<br><br>គួរចែងផងដែរអំពីអាណាព្យាបាលរដ្ឋបាល សម្រាប់ការចាត់ចែងកម្មសិទ្ធិសមូហភាពនៃដីបញ្ចុះសព ក្នុងករណីមានការសម្រេចឯកភាពផ្លាស់ប្តូរទីតាំងដីបញ្ចុះសព ឬការកាត់បន្ថយទំហំនៃដីបញ្ចុះសព។ | ឬអត់ ហើយបើអនុញ្ញាត ចែងកំណត់លក្ខខណ្ឌចាំបាច់មួយចំនួន ដើម្បីជៀសវាងការប៉ះពាល់ចំពោះក្បាលដីជិតខាង។<br><br>សូមចែងថា រដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកវិស័យសាសនា ជាអាណាព្យាបាលរដ្ឋបាល សម្រាប់ការចាត់ចែងកម្មសិទ្ធិសមូហភាពនៃដីបញ្ចុះសព តាមលក្ខខណ្ឌកំណត់ក្នុងច្បាប់នេះ។ |
| មាត្រា ៣៦ | សូមមើលយោបល់ក្នុងមាត្រា ១។<br><br>គួរមានការចែងកំណត់ភារកិច្ចឱ្យក្រសួងមហាផ្ទៃ ត្រូវជម្រុញ និងសម្របសម្រួលនីតិវិធី យន្តការ និងកម្មវិធីរៀបចំ និងចុះបញ្ជីលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិចទាំងអស់នៅកម្ពុជាឱ្យបានឆាប់រហ័សរួចរាល់ក្នុងអំឡុងពេលមិនលើសពី ៥ឆ្នាំ ដើម្បីជានាការពារ និងបង្កលទ្ធភាពចុះបញ្ជីអចលនវត្ថុរបស់សហគមន៍ជនជាតិដើមទាំងឡាយ។<br><br>ក្នុងពេលរង់ចាំនូវការរៀបចំ និងចុះបញ្ជីលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច ច្បាប់នេះគួរចែងអនុញ្ញាតឱ្យអាជ្ញាធរប្រពៃណី ឬតំណាងដែលក្រុមជនជាតិដើមភាគតិច ឬសហគមន៍ជនជាតិដើមភាគតិចជ្រើសរើសតាមវិធានប្រពៃណី ធ្វើការចង្អុលបង្ហាញទីតាំង និងចំនុចព្រំប្រទល់នៃដីដែលអះអាងថាបានកាន់កាប់ ប្រើប្រាស់ អាស្រ័យផលជាក់ស្តែងចាប់តាំងពីមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ ដើម្បីឱ្យក្រុមការងារទទួលបន្ទុកការពារជាបណ្តោះអាសន្ននូវដីរបស់សហគមន៍ជនជាតិ (ដែលសុំឱ្យបង្កើតឡើង ឯករាជ្យពីអាជ្ញាធរដែនដី និងអាជ្ញាធរកាន់កាប់ដីរដ្ឋ) ចុះដាំបង្គោលសម្គាល់ និងគូសជាប្លង់ផែនទី ព្រមទាំងធ្វើការអង្កេតបឋម ធ្វើកំណត់ហេតុបរិយាយស្ថានភាពដីជាក់ស្តែង រួមទាំងការអះអាងផ្សេងៗរបស់អាជ្ញាធរមានសមត្ថកិច្ចនានា និងរបស់ប្រជា | សូមចែងកែសម្រួលបំពេញបន្ថែមតាមខ្លឹមសារនៃយោបល់ចំពោះមាត្រានេះ។ |

| មាត្រា | ឃោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ពលរដ្ឋផ្សេងក្រៅពីសមាជិកនៃក្រុម ឬសហគមន៍ជនជាតិដើមភាគតិចនោះ ដើម្បីទុកជាជំនួយស្មារតីក្នុងការ វិនិច្ឆ័យក្បាលដីពាក់ព័ន្ធនាពេលអនុវត្តនីតិវិធីចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច។<br><br>គួរចែងតម្រូវឱ្យអនុវត្ត និងបញ្ចប់នីតិវិធីចុះបញ្ជីដីធ្លីលើកដំបូង ចំពោះដីដែលគ្មានទំនាស់ ក្នុងរយៈពេលមិនលើសពី ៣ ឆ្នាំក្រោយពីមានការចុះបញ្ជីលក្ខន្តិកៈទទួលស្គាល់សហគមន៍ជាផ្លូវការ។<br><br>ផ្អែកតាមភាពជាក់ស្តែង អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច មិនគួរត្រូវបានកម្រិតដោយព្រំប្រទល់រដ្ឋបាលឡើយ។<br><br>ក្បាលដីមានទំនាស់ ត្រូវមានការសម្របសម្រួលដោះស្រាយដោយ ក្រុមការងារពិសេសចាត់តាំងដោយក្រសួងទទួលបន្ទុកគ្រប់គ្រងវិស័យសុរិយោដី ហើយចាំបាច់ត្រូវមានការសម្រុះសម្រួល ឬនិងសម្រេចដោយយន្តការថ្នាក់ជាតិ (គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយមិនតម្រូវឱ្យឆ្លងកាត់យន្តការគណៈកម្មការសុរិយោដីថ្នាក់ក្រុងស្រុកខណ្ឌ និងរាជធានី ខេត្ត ដែលច្រើនតែមានទំនាស់ផលប្រយោជន៍ក្នុងវិវាទ) ក្នុងរយៈពេលយ៉ាងយូរ ៥ឆ្នាំ គិតចាប់ពីថ្ងៃចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីលើកដំបូងដែលវិនិច្ឆ័យក្បាលដីមានទំនាស់នោះ ហើយបើគ្មានការសម្រេចក្នុងរយៈពេលកំណត់ ៥ឆ្នាំនេះទេត្រូវបានចាត់ទុកថាការអះអាងរបស់សហគមន៍ជនជាតិដើមភាគតិចនោះមានលក្ខណៈស្របច្បាប់ ហើយអនុញ្ញាតឱ្យរដ្ឋបាលសុរិយោដី ចុះបញ្ជី និងចេញប័ណ្ណជូនសហគមន៍នោះដោយពេញលក្ខណៈច្បាប់។<br><br>ដែនកំណត់ពេលវេលាអតិបរមាសម្រាប់កំណត់ស្ថានភាពផ្លូវច្បាប់នៃសហគមន៍ជនជាតិដើមភាគតិចគួរតែត្រូវបានកំណត់ដើម្បីធានាថាសហគមន៍មិនត្រូវបានទុកចោលអស់រយៈពេលជាច្រើនឆ្នាំ។ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ផែនទីបណ្ដោះអាសន្នគួរតែត្រូវបានបង្កើតឡើងដើម្បីកំណត់អត្តសញ្ញាណសហគមន៍ និងអចលនវត្ថុរបស់សហគមន៍ ហើយផែនទីទាំងនោះគួរតែត្រូវបានប្រើប្រាស់ដោយក្រសួងពាក់ព័ន្ធទាំងអស់ ដើម្បីផ្អាកសម្បទាន និងការកំណត់ដីផ្សេងទៀតនៅក្នុងតំបន់នោះដែលអាចរំខានដល់ការទាមទារដីសហគមន៍ជនជាតិដើមភាគតិច។<br><br>លើសពីនេះ យើងស្នើឱ្យមានអាណត្តិច្បាស់លាស់សម្រាប់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងធនធានដល់សហគមន៍ជនជាតិដើមភាគតិច ដើម្បីជួយរៀបចំផែនទីនៃទ្រព្យសម្បត្តិសមូហភាពរបស់ពួកគេ។ | |
| មាត្រា ៣៧ | និយមន័យនេះអាចដាក់នៅក្នុងផ្នែកនិយមន័យ។ មាត្រានេះអាចត្រូវបានជំនួសដោយបទប្បញ្ញត្តិដែលសង្កត់ធ្ងន់ថា "លក្ខណៈវិនិច្ឆ័យជនជាតិភាគតិច វប្បធម៌ និងសង្គម" សម្រាប់សមាជិកភាពសហគមន៍ជនជាតិដើមភាគតិចមិនអាចរើសអើងដោយផ្អែកលើគោលការណ៍រដ្ឋធម្មនុញ្ញនៃសមភាពយេនឌ័រ និងការមិនរើសអើងឡើយ។ | ស្នើឱ្យផ្លាស់ទៅផ្នែកនិយមន័យ។ |
| មាត្រា ៣៨ | តាមយោបល់ក្នុងមាត្រា ៣៦ គួរលុបចោលលក្ខខណ្ឌតម្រូវឱ្យមានការទទួលស្គាល់ដោយអាជ្ញាធរកាន់កាប់ដីរដ្ឋ ក្នុងកថាខណ្ឌទី២ នៃមាត្រានេះ។<br><br>គួរលុបចោលកថាខណ្ឌទី៣ នៃមាត្រានេះ ហើយទុកលទ្ធភាពឱ្យមានការសម្រេចដោះស្រាយដោយយន្តការដែលផ្តល់យោបល់ក្នុងមាត្រា ៣៦ ចំពោះដីដែលមិនទាន់ត្រូវបានចុះបញ្ជីសុរិយោដីថាជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលនៃនីតិសាធារណៈ នៅឡើយ។<br><br>ផែនទីគម្របព្រៃឈើដែលធ្វើ និងសម្រេចអនុម័តក្រោយឆ្នាំ១៩៩៣ ជាពិសេសក្រោមច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ និងក្រោយពីមានការកាន់កាប់ ប្រើប្រាស់ អាស្រ័យផលលើដីជាក់ស្តែងតាំងពីមុនថ្ងៃទី ៣១ សីហា ឆ្នាំ២០០១ មិនគួរអនុញ្ញាតអាចយកធ្វើជាមូលដ្ឋានតែឯកឯងក្នុងការ | សូមលុបចោលចំណុច និងថែងបន្ថែម ស្របតាមយោបល់ក្នុងមាត្រានេះ។<br><br>"បានបង្កើតលំនៅឋានរបស់ពួកគេ និងជាកន្លែងដែលពួកគេធ្វើកសិកម្ម និងចិញ្ចឹមសត្វ ព្រមទាំងកន្លែងសាសនា និងវប្បធម៌"<br><br>"ពួកគេត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអាជ្ញាធរពាក់ព័ន្ធដែលមានអាណត្តិជាមួយអាជ្ញាធររដ្ឋបាលលើដីរដ្ឋ។ សហគមន៍អាចបន្តធ្វើដូច្នេះក្រោមច្បាប់នេះ។" |

| មាត្រា | ឃោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | បដិសេធសិទ្ធិទាមទាររបស់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជា របស់ភោគីស្របច្បាប់ផ្សេងៗទៀតឡើយ។<br><br>សូមមើល មាត្រា ៨ មាត្រា ១០ មាត្រា ២៥ ដល់មាត្រា ២៧ មាត្រា ៣២ មាត្រា ៣៨ និងមាត្រា ៤០ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ផង។<br><br>បន្ថែមពីលើដីសម្រាប់លំនៅដ្ឋាន និងកសិកម្មបែបប្រពៃណី បន្ថែមដីសម្រាប់កន្លែងសាសនា និងវប្បធម៌របស់ពួកគេ (UNDRIP មាត្រា ១២) និងធនធានសមូហភាពផ្សេងទៀត ដូចជាដីជួរគោក្របី ឬកន្លែងកសាងសហគមន៍។ សូមមើល ឧ. កម្មសិទ្ធិដីសមូហភាពរបស់ Liz Alden Wily ក្នុងសតវត្សទី ២១ (២០១៨)៖ ពាក់កណ្តាលប្រទេសដែលបានសិក្សាមានការការពារសិទ្ធិដីធ្លីសហគមន៍រឹងមាំ ដែលរួមបញ្ចូលថា "ការទទួលស្គាល់ និងការការពារមិនត្រូវបានកំណត់ចំពោះកសិដ្ឋាន និងផ្ទះទេ ជួរភ្នំ វាលភក់ និងព្រៃឈើក្នុងដែនសហគមន៍ ក៏ត្រូវបានទទួលស្គាល់ថាជាកម្មសិទ្ធិសហគមន៍ផងដែរ»។<br><br>បន្ថែមពីលើដីសម្រាប់លំនៅដ្ឋាន និងកសិកម្មបែបប្រពៃណី បន្ថែមដីសម្រាប់កន្លែងសាសនា និងវប្បធម៌របស់ពួកគេ (UNDRIP មាត្រា ១២) និងធនធានសមូហភាពផ្សេងទៀត ដូចជាដីជួរគោក្របី ឬកន្លែងកសាងសហគមន៍។ សូមមើល ឧ. កម្មសិទ្ធិដីសមូហភាពរបស់ Liz Alden Wily ក្នុងសតវត្សទី ២១ (២០១៨)៖ ពាក់កណ្តាលប្រទេសដែលបានសិក្សាមានការការពារសិទ្ធិដីធ្លីសហគមន៍រឹងមាំ ដែលរួមបញ្ចូលថា "ការទទួលស្គាល់ និងការការពារមិនត្រូវបានកំណត់ចំពោះកសិដ្ឋាន និងផ្ទះទេ ជួរភ្នំ វាលភក់ និងព្រៃឈើក្នុងដែនសហគមន៍ ក៏ត្រូវបានទទួលស្គាល់ថាជាកម្មសិទ្ធិសហគមន៍ផងដែរ»។ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ច្បាប់នេះក៏គួរការពារសិទ្ធិទទួលបាន និងប្រើប្រាស់អនុផលព្រៃឈើ និងប្រភពទឹកនៅលើដីដែលត្រូវបានវិនិច្ឆ័យ និងចុះបញ្ជីជាសម្បត្តិរដ្ឋនៅក្រៅព្រំដែននៃក្បាលដីដែលបានចុះបញ្ជីជាដីសហគមន៍។ ដើម្បីធ្វើដូច្នេះ ច្បាប់អាចទទួលស្គាល់សិទ្ធិដែលមិនមានកម្មសិទ្ធិ (ដូចជាប្រាក់ចំណេញមុន) ដល់អនុផលព្រៃឈើ និងសិទ្ធិទទួលបានទឹក។ | |
| មាត្រា ៣៩ | ស្របតាមយោបល់ក្នុងមាត្រា ៥ និងមាត្រា ១៤៦ ព្រមទាំង ស្មារតីនៃមាត្រា មាត្រា ២៥ ដល់មាត្រា ២៧ មាត្រា ៣២ និងមាត្រា ៣៨ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច គួរលុបចោលបញ្ញត្តិហាមឃាត់ចំពោះសិទ្ធិចាត់ចែងទ្រព្យរបស់សហគមន៍ ក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ប៉ុន្តែរាល់ការលក់ដូរ បែងចែក ជួលរយៈពេលវែង ឬការបង្កើតសិទ្ធិប្រត្យក្សផ្សេងៗលើអចលនវត្ថុរបស់សហគមន៏ អាចតម្រូវឱ្យមានការពិគ្រោះយោបល់ និងសុំការឯកភាពពីអាណាព្យាបាលរដ្ឋបាល ជាមុន (ហើយករណីអាណាព្យាបាលរដ្ឋបាល បដិសេធចំពោះសំណើចាត់ចែងទ្រព្យណាមួយ ត្រូវ ផ្តល់ហេតុផលច្បាស់លាស់ និងសមរម្យ)។<br><br>ច្បាប់នេះគួរចែងបញ្ជាក់ និងអនុញ្ញាតឱ្យសហគមន៍ទទួលអំណោយ ឬ អច្ច័យទានជាអចលនវត្ថុ ទិញអចលនវត្ថុ និងធ្វើលទ្ធកម្មតាមអាជ្ញាយុកាលតាមការកាន់កាប់ដោយសន្តិវិធី និងដឹងឮជាសាធារណៈដោយមានឆន្ទៈយកជាកម្មសិទ្ធិលើដីកម្មសិទ្ធិរបស់បុគ្គលឯកជន ស្របតាមការចែងក្នុងក្រមរដ្ឋប្បវេណី មាត្រា ១៦២ ដល់មាត្រា ១៧៨ ដោយមិនចាំបាច់ពិគ្រោះ និងសុំការឯកភាពពីអាណាព្យាបាលរដ្ឋបាល។<br><br>សកម្មភាពការងាររបស់រដ្ឋដែលជាតម្រូវការនៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិ គួរត្រូវបានកំណត់ជាក់លាក់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។ | សូមកែសម្រួលកថាខណ្ឌចុងក្រោយនៃមាត្រានេះ តាមខ្លឹមសារនៃយោបល់ចំពោះមាត្រានេះ។<br><br>លុបៈ "បទប្បញ្ញត្តិនៃមាត្រានេះ មិនមែនជាឧបសគ្គចំពោះសកម្មភាពការងាររបស់រដ្ឋ ដែលជាតម្រូវការផលប្រយោជន៍ជាតិ ឬតម្រូវការបន្ទាន់របស់ប្រទេសជាតិនោះទេ។"<br><br>"យោងទៅតាមទំនៀមទម្លាប់របស់ពួកគេ និងស្របតាមការការពារវដ្តធម្មនុញ្ញសម្រាប់សមភាពយេនឌ័រ និងការមិនរើសអើង ហើយត្រូវស្ថិតនៅក្រោមប្រធានបទ..." |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ហើយការធ្វើលទ្ធកម្មដីរបស់សហគមន៍ជនជាតិដើមភាគតិចសម្រាប់គម្រោងហេដ្ឋរចនាសម្ព័ន្ធ ឬការផ្ដល់ការអនុញ្ញាតរុករករ៉ែ ឬសម្បទានរ៉ែ ដែលប៉ះពាល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចណាមួយ គួរត្រូវបានហាមឃាត់ដាច់ខាត លើកលែងតែមានការយល់ព្រមយ៉ាងពិតប្រាកដ គ្មានការបង្ខិតបង្ខំ និងអាចលុបចោលការយល់ព្រម ឬការព្រមព្រៀងវិញនៅពេលណាក៏បាន ដោយសហគមន៍នោះ ហើយគ្មានតម្រូវ ឬគ្មានខចែងឱ្យសហគមន៍នោះទទួលខុសត្រូវចំពោះសំណងការខូចខាត ឬជំងឺចិត្តអ្វីទាំងអស់។<br><br>សូមមើល មាត្រា ៣ ដល់មាត្រា ៥ មាត្រា ៨ មាត្រា ១០ មាត្រា ២៥ ដល់មាត្រា ២៧ មាត្រា ៣០ មាត្រា ៣២ និងមាត្រា ៤០ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចផង។<br><br>ដូចដែលបានកត់សម្គាល់ខាងលើ ច្បាប់គួរតែទទួលស្គាល់ និងការពារសិទ្ធិទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ស្របតាម UNDRIP ។<br><br>Re: "បទប្បញ្ញត្តិនៃមាត្រានេះ មិនមែនជាឧបសគ្គចំពោះសកម្មភាពការងាររបស់រដ្ឋ ដែលជាតម្រូវការផលប្រយោជន៍ជាតិ ឬតម្រូវការបន្ទាន់របស់ជាតិឡើយ"។ នេះហាក់ដូចជាបញ្ជាក់ថាក្នុងករណី "តម្រូវការជាតិ ឬជាបន្ទាន់" ជនជាតិដើមភាគតិច អាចបាត់បង់សិទ្ធិទាំងអស់របស់ពួកគេ។ នេះគួរតែត្រូវបានដកចេញ ព្រោះដំណើរការអស្សាមិករណ៍ត្រូវបានកំណត់រួចហើយនៅកន្លែងផ្សេង។<br><br>វាគួរតែមានភាពច្បាស់លាស់ជាងនេះទៅទៀតអំពីអ្វីដែលពិសេស និងមិនត្រូវបានអនុញ្ញាតនៅពេលនិយាយអំពី "សិទ្ធិ និងការការពារដូចគ្នានឹងកម្មសិទ្ធិឯកជន" ទល់នឹង "គ្មានសិទ្ធិក្នុងការបោះចោល"។ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| មាត្រា ៤០ | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ជាលិខិតូបករណ៍រដ្ឋបាល មានលក្ខណៈខុសពី វិធានប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលកត់សម្គាល់បានតាមការចំណាំជាទម្លាប់ ឬតាមប្រសាសន៍ផ្ទាល់មាត់របស់អាជ្ញាធរប្រពៃណី។ គួរអនុញ្ញាតឱ្យធ្វើ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ជាគ្រាមភាសារបស់សហគមន៍ជនជាតិដើមភាគតិច ជាសំណេរ ឬខ្សែអាត់ ទុកជាគោល ចំណែកអត្ថបទជាភាសាខ្មែរ ត្រូវចាត់ទុកជាឯកសារជំនួយស្មារតីរបស់រដ្ឋបាល។<br><br>សូមមើល មាត្រា ៣ ដល់មាត្រា ៥ មាត្រា ១៣ មាត្រា ៣៣ មាត្រា ៣៤ និងមាត្រា ៣៥ នៃសេចក្ដីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិច។<br><br>ក្នុងកថាខណ្ឌទី៣ គួរលុបចោលពាក្យថា ដីឯកជនរបស់រដ្ឋ ហើយជំនួសដោយ ដីជាចំណែកឯកជននៃទ្រព្យសម្បូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ។<br><br>គួរចែងក្នុងមាត្រានេះផងដែរ អំពីសិទ្ធិចេញចូលបន់ស្រន់សែនព្រៃនគោរពផ្នូរសពរបស់ញាតិមិត្តនៃសមាជិកដែលត្រូវបានអនុញ្ញាតឱ្យចាកចេញ ឬដែលត្រូវបណ្ដេញចេញពីសហគមន៍ ផង។<br><br>កថាខណ្ឌចុងក្រោយដែលចែងឱ្យកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការសុំចូលជាសមាជិកសហគមន៍ និងការសុំចេញពីសហគមន៍ ដោយអនុក្រឹត្យ អាចប៉ះពាល់ដល់វិធានទំនៀមទម្លាប់ប្រពៃណីរបស់សហគមន៍ និងមិនស្របតាមស្មារតីនៃសេចក្ដីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ដូច្នេះ គួរទុកឱ្យសហគមន៍កំណត់វិធានពាក់ព័ន្ធក្នុងលក្ខន្តិកៈ ឬនិង បទបញ្ជាផ្ទៃក្នុងដូចខាងលើ ហើយលុបចោលកថាខណ្ឌនេះ។<br><br>សមាជិកភាពក្នុងសហគមន៍ជនជាតិដើមភាគតិច គួរតែត្រូវបានកំណត់ដោយសហគមន៍ជនជាតិដើមភាគតិចផ្ទាល់ ចាប់ពីថ្នាក់ក្រោមឡើង។ ការកំណត់អាចជាទម្រង់ពាក្យសំដី ដរាបណាវា | សូមកែសម្រួលមាត្រានេះ តាមខ្លឹមសារនៃយោបល់សម្រាប់មាត្រានេះ។<br><br>"ក្នុងករណីដែលសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ស្នើសុំចាកចេញពីសហគមន៍ជនជាតិដើមភាគតិច សមាជិកនោះអាចទទួលបានចំណែកសមស្របនៃដីឯកជនរបស់រដ្ឋ ដែលសហគមន៍ប្រើប្រាស់ជាកម្មសិទ្ធិឯកជនរបស់សមាជិកនោះ ស្របតាមបទប្បញ្ញត្តិមូលដ្ឋាន ដែលត្រូវតែជានា ការអនុវត្តស្មើៗគ្នាសម្រាប់ការចាកចេញពីសមាជិកសហគមន៍ ដោយមិនគិតពីភេទ អាយុ ឬលក្ខណៈរើសអើងណាមួយផ្សេងទៀត"។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | តំណាងឱ្យផលប្រយោជន៍សហគមន៍ជនជាតិដើមភាគតិច។ អនុក្រឹត្យមួយមិនអាចអនុវត្តសម្រាប់សហគមន៍ទាំងអស់បានទេ ដោយសារពួកគេមានរបៀបរស់នៅខុសៗគ្នា។ គួរយកចិត្តទុកដាក់ជាពិសេសផងដែរ ដល់សហគមន៍ជនជាតិដើមភាគតិចអំពីការផ្លាស់ប្តូរផ្លូវច្បាប់ ដោយសារសមាជិកសហគមន៍ជាច្រើនមិននិយាយ/អានភាសាខ្មែរ។<br><br>ទាក់ទងនឹងការដាក់បញ្ចូល និងការបំបែកកម្មសិទ្ធិឯកជនចេញពីកម្មសិទ្ធិសមូហភាព ការរួមបញ្ចូលគឺជាកាតព្វកិច្ច ប៉ុន្តែការបំបែកទ្រព្យសម្បត្តិគឺមិនតាមការស្ម័គ្រចិត្ត។ នេះអាចបណ្តាលឱ្យមានអាកប្បកិរិយារើសអើង ដូចជាស្ត្រីមិនសូវទទួលបានទ្រព្យសម្បត្តិនៅពេលចាកចេញពីសហគមន៍។ | |
| មាត្រា ៤១ | គួរមានការចែងបញ្ជាក់អំពីភាពផ្តាច់មុខក្នុងការទទួលបានសិទ្ធិលើអចលនវត្ថុរបស់សហគមន៍ សម្រាប់ដោះស្រាយករណីមានការអនុញ្ញាតឱ្យសមាជិកចាកចេញពីសហគមន៍ ករណីមានការយល់ព្រមពីសហគមន៍លើការប្រើប្រាស់ដីសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬលើការផ្តល់ការអនុញ្ញាតរុករករ៉ែ ឬសម្បទានរ៉ែ ហើយបើកលទ្ធភាពឱ្យសហគមន៍ជួល ប្រវាស់ ចាត់ចែង ដីជាចំណែកឯកជនមួយចំនួន ដើម្បីទ្រទ្រង់ជីវភាព ឬនិងបង្កើនលទ្ធភាពផលិតកម្មលើដីរបស់សហគមន៍ ក្រោយពីបានពិគ្រោះ និងទទួលបានការឯកភាពពីអាណាព្យាបាលរដ្ឋបាល។<br><br>សូមមើល មាត្រា ៣ ដល់មាត្រា ៥ មាត្រា ២៥ ដល់មាត្រា ២៧ និងមាត្រា ៣២ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចផង។<br><br>ទាក់ទងនឹង "គ្មានអាជ្ញាធរនៅក្រៅសហគមន៍ណាមួយអាចទទួលបានសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចឡើយ។ ព្រមានដោយ "លុះត្រាតែមានការយល់ព្រមដោយឥតគិតថ្លៃ ជាមុន និងជូនដំណឹងរបស់ពួកគេ"។ សហគមន៍ជនជាតិដើមភាគតិចគួរតែត្រូវបានអនុញ្ញាតឱ្យផ្តល់សិទ្ធិជាបុត្រសម្ព័ន្ធលើដីរបស់ពួកគេទៅឱ្យបុគ្គល និងអង្គការ/អង្គភាព | សូមកែសម្រួលមាត្រានេះ តាមខ្លឹមសារនៃយោបល់សម្រាប់មាត្រានេះ។<br><br>បន្ថែម៖ គ្មានអាជ្ញាធរ ឬជនណាដែលនៅក្រៅសហគមន៍អាចទទួលបានសិទ្ធិណាមួយលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចឡើយ លុះត្រាតែមានការយល់ព្រមដែលបានទទួលព័ត៌មានជាមុន និងដោយសេរី និងស្របតាមច្បាប់ ទំនៀមទម្លាប់ និងការអនុវត្តរបស់សហគមន៍។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ដូចជាការបង្កើតឥណទានកាបូន ការអនុញ្ញាតឱ្យធ្វើអាជីវកម្មរ៉ែ ឬភាពងាយស្រួលសម្រាប់ប្រព័ន្ធប្រើប្រាស់សាធារណៈ ឬហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត នៅពេលដែលដំណើរការយ៉ាងម៉ត់ចត់ដើម្បីធានាបាននូវសេរីភាពជាមុន។ និងការយល់ព្រមដែលមានព័ត៌មានមាននៅនឹងកន្លែង ហើយសហគមន៍រក្សានូវសេរីភាពក្នុងការដកហូត ឬបញ្ចប់ការយល់ព្រម ឬកិច្ចព្រមព្រៀងដែលពាក់ព័ន្ធដោយគ្មានការទទួលខុសត្រូវលើផ្នែកនៃសហគមន៍ជនជាតិដើមភាគតិច។ | |
| មាត្រា ៤៣ | ដីកប់សព មិនគួរអនុញ្ញាតឱ្យឋិតនៅក្នុងប្លង់ដីលំនៅឋាន ឬប្លង់ដីកសិកម្ម ឬប្លង់ដីពាណិជ្ជកម្ម ឧស្សាហកម្មឡើយ ហើយគួរកំណត់ជាក្បាលដីដាច់ដោយឡែក និងចែងក្នុងផ្នែកទី២ នៃជំពូក៣ទាំងអស់។<br><br>សូមមើលយោបល់ចំពោះមាត្រា ៣៤ និងមាត្រា ៣៥ ផង។ | សូមលុបកថាខណ្ឌចុងក្រោយ នៃមាត្រានេះ ចេញ ហើយយកទៅចែងក្នុងផ្នែកទី២ នៃជំពូក៣ ខាងលើ ស្របតាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៤៥ | អឡ្ឋសិទ្ធិភាពនៃសហកម្មសិទ្ធិលើអចលនវត្ថុ ក្រៅពីរបស់សហគមន៍ជនជាតិដើមភាគតិច របស់វត្ត និងរបស់ដីបញ្ចុះសព គួរមានបញ្ញត្តិនៅក្នុងច្បាប់នេះ ដើម្បីឱ្យមានលក្ខណៈពេញលេញនៃមូលដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងអចលនវត្ថុដែលឋិតក្រោមរបបសហកម្មសិទ្ធិ ទូទៅ។ | សូមចែងអំពីអឡ្ឋសិទ្ធិភាពនៃសហកម្មសិទ្ធិលើអចលនវត្ថុក្នុងច្បាប់នេះ ស្របតាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៤៧ | ការបញ្ចូលនូវឃ្លាថា "ឬមានការចែងផ្ទុយគ្នា" នាំឱ្យមានភាពមិនច្បាស់លាស់នៃបញ្ញត្តិច្បាប់នេះ។ គួរចែងបញ្ជាក់ថា ផ្ទុយជាមួយអ្វី ហើយត្រូវដោះស្រាយលុបបំបាត់ភាពផ្ទុយគ្នានោះដោយរបៀបណា។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៥៨ | ការមានឃ្លាថា "លុះត្រាតែមានការផ្ទុយពីលក្ខណៈរបស់វា" ធ្វើឱ្យបញ្ញត្តិនៃមាត្រាមានភាពមិនច្បាស់ លាស់។ គួរចែងបញ្ជាក់អំពីករណីលើកលែងនេះ។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៥៩ | ប្រសិនបើអំណាចក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចត្រូវរក្សាទុក នោះត្រូវតែមានការដាក់កំហិតយ៉ាងម៉ឹងម៉ាត់ដើម្បីធានាថាសម្បទានបែបនេះមិនរំខានដល់ការទាមទារដីស្របច្បាប់របស់អ្នកដទៃ ឬនាំទៅដល់ការកើនឡើងនៃជម្លោះដីធ្លី។ ការកំណត់លើទំហំ និងការកាត់បន្ថយរយៈពេលនៃសម្បទានដីសេដ្ឋកិច្ចនៅក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីគួរដាក់ឱ្យប្រើប្រាស់ឡើងវិញ និងបំពេញបន្ថែម រួមជាមួយនឹងការដាក់កំហិតនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចតែ | បន្ថែម៖ រដ្ឋាភិបាលអាចចេញឯកសារផ្លូវច្បាប់ដែលផ្តល់សម្បទានដីបានលុះត្រាតែលក្ខខណ្ឌរួមមាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការចុះបញ្ជីដីធ្លី និងលក្ខខណ្ឌផ្សេងទៀតដែលមានចែងក្នុងច្បាប់នេះ ឬ/និងអនុក្រឹត្យដែលអាចអនុវត្តបាន។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | មួយសម្រាប់បុគ្គល ឬនីតិបុគ្គល និងលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់កំណត់អំណាចគ្រប់គ្រងរបស់នីតិបុគ្គលដោយនីតិបុគ្គលផ្សេងទៀត។ បន្ថែមពីនេះទៀត គួរតែមានការណែនាំច្បាស់លាស់អំពីកត្តាដែលតម្រូវឱ្យបង្កើតគោលបំណងសេដ្ឋកិច្ចសមហេតុផលសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច។ អ្នកកាន់សម្បទានដីសេដ្ឋកិច្ចគួរតែត្រូវបានទាមទារនៅក្រោមការណែនាំបែបនេះ ដើម្បីរាយការណ៍អំពីវឌ្ឍនភាពរបស់ពួកគេឆ្ពោះទៅរកការសម្រេចបាននូវគោលដៅសេដ្ឋកិច្ច។ ហើយលក្ខខណ្ឌដែលដីត្រូវដាក់ប្រើប្រាស់ក្នុងរយៈពេល ១២ខែ ត្រូវតែយកមកវិញ។<br><br>លើសពីនេះ បទប្បញ្ញត្តិគួរតែត្រូវបានបន្ថែម តម្រូវឱ្យអ្នកកាន់កាប់សម្បទានដីគោរពតាមគោលការណ៍ទទួលស្គាល់ជាអន្តរជាតិលើការវិនិយោគប្រកបដោយទំនួលខុសត្រូវ ដូចមាននៅក្នុងគោលការណ៍សម្រាប់ការវិនិយោគប្រកបដោយ ទំនួលខុសត្រូវក្នុងវិស័យកសិកម្ម និងប្រព័ន្ធស្បៀងអាហារ។ បទប្បញ្ញត្តិនេះគួរតែរួមបញ្ចូល ការចូលរួមពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់ (ដោយគោរពសិទ្ធិរបស់ពួកគេក្នុងការផ្តល់ឱ្យ ឬរក្សាការយល់ព្រមដែលបានទទួលព័ត៌មានជាមុន និងដោយសេរី) ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមមុនពេលការសម្រេចចិត្តណាមួយ ថាតើត្រូវបន្តការវិនិយោគឬទេ និងបញ្ចូលយន្តការបណ្តឹងសារទុក្ខដោយយុត្តិធម៌ និងងាយស្រួល និងការត្រួតពិនិត្យហេតុប៉ះពាល់អវិជ្ជមានក្នុងអំឡុងពេលអនុវត្តគម្រោង។ ក្នុងករណីដែលសម្បទានដីត្រូវបានផ្តល់ឱ្យនៅលើដីដែលជនជាតិដើមភាគតិច និងសហគមន៍មិនមែនជនជាតិដើមភាគតិចផ្សេងទៀតកាន់កាប់ និងប្រើប្រាស់តាមបែបប្រពៃណី គួរមានការផ្តល់សំណង និងការប្រគល់ដីនោះវិញតាមដែលអាចធ្វើបាន។<br><br>រដ្ឋាភិបាលក៏គួរតែពិចារណាលើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលគ្របដណ្តប់លើសម្បទានទាំងអស់។ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | គួរបន្ថែមលក្ខខណ្ឌច្បាស់លាស់ដែលភ្ជាប់ជាមួយ "ឆន្ទានុសិទ្ធិ" របស់រដ្ឋាភិបាលថា ឯកសារផ្លូវច្បាប់ដែលផ្តល់សម្បទានដីអាចចេញបានលុះត្រាតែមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ការចុះបញ្ជីដីធ្លី និងលក្ខខណ្ឌផ្សេងទៀតដែលមានចែងក្នុងច្បាប់នេះ ឬ/និងអនុក្រឹត្យជាធរមានដែលអាចអនុវត្តបានពេញលេញ។ | |
| មាត្រា ៦០<br>មាត្រា ៦១<br>និងមាត្រា<br>៦៣ | គួរបញ្ចូលបញ្ញត្តិក្នុងមាត្រា ៦០ មាត្រា ៦១ និងមាត្រា ៦៣ ទៅក្នុងមាត្រាតែមួយ។<br><br>គួរតែរួមបញ្ចូលនិយមន័យនៃ "គោលបំណងសេដ្ឋកិច្ច" ឬនៅក្នុងវិធីផ្សេងទៀតបញ្ជាក់យ៉ាងច្បាស់ពីអ្វីដែលធ្វើ និងអ្វីដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា "ការកេងប្រវ័ញ្ចលើដីកសិកម្មឧស្សាហកម្ម"។<br><br>ផងដែរ របៀបកំណត់គ្រួសារដែលមានលក្ខណៈគ្រប់គ្រាន់ជា "គ្រួសារក្រីក្រ"។ ប្រហែលជានេះអាចស្ថិតនៅក្នុងបទប្បញ្ញត្តិមួយ ប៉ុន្តែនិយមន័យនៅក្នុងច្បាប់នេះនឹងមានប្រយោជន៍។<br><br>ទាក់ទងនឹង មាត្រា៦១ និយមន័យនៃ "គោលបំណងសេដ្ឋកិច្ច" ឬលម្អិតបន្ថែមទៀតអំពីអ្វីដែលធ្វើ និងអ្វីដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា "ការកេងប្រវ័ញ្ចដីកសិកម្មឧស្សាហកម្ម" នឹងមានប្រយោជន៍។<br><br>តើលទ្ធផលនៃការផ្អាកសម្បទានដីសេដ្ឋកិច្ច និងការពិនិត្យឡើងវិញនៃសម្បទានដីសេដ្ឋកិច្ចត្រូវបានបង្ហាញក្នុងច្បាប់នេះដែរឬទេ ?<br><br>ទាក់ទងនឹង មាត្រា៦៣៖ ច្បាប់ភូមិបាលគួរតែកំណត់ឱ្យកាន់តែច្បាស់អំពីលក្ខណៈផ្លូវច្បាប់របស់អ្នកកាន់កាប់ដីសម្បទានសង្គមកិច្ច។ អ្នកទទួលដីសម្បទានសង្គមកិច្ចមានសិទ្ធិកាន់កាប់ប្រើប្រាស់និងចំណេញពីដី (មាត្រា ៦៩) និងការពារការប្រើប្រាស់ផ្តាច់មុខ (មាត្រា ៦៨) ដែលជាសិទ្ធិធម្ម | សូមបញ្ចូលបញ្ញត្តិក្នុងមាត្រា ៦០ មាត្រា ៦១ និងមាត្រា ៦៣ ទៅក្នុងមាត្រាតែមួយ។<br><br>បន្ថែមនិយមន័យនៃ "គោលបំណងសេដ្ឋកិច្ច" ឬបញ្ជាក់យ៉ាងច្បាស់នូវអ្វីដែលធ្វើ និងអ្វីដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា "ការកេងប្រវ័ញ្ចលើដីកសិកម្មឧស្សាហកម្ម"។<br><br>គួរបន្ថែមនិយមន័យ ឬលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់គ្រួសារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា "គ្រួសារក្រីក្រ"។<br><br>និយមន័យនៃ "គោលបំណងសង្គម" នឹងមានប្រយោជន៍។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | តានៃសិទ្ធិអចលនទ្រព្យ។ ប៉ុន្តែពួកគេមិនត្រូវបានអនុញ្ញាតឱ្យលក់ ជួលបន្ត ឬផ្តល់អំណោយនោះទៅឆ្ងាយទេ (មាត្រា ៧០) រហូតទាល់តែពួកគេបានប្រើប្រាស់ដីប្រកបដោយផលិតភាពរយៈពេល ៥ ឆ្នាំ ហើយបំប្លែងសិទ្ធិសម្បទានទៅជាកម្មសិទ្ធិស្របច្បាប់ (មាត្រា ១១ មាត្រា ១៨ នៃអនុក្រឹត្យលេខ ១៩)។ វាមានតម្លៃក្នុងការយោងលើច្បាប់ពាក់ព័ន្ធផ្សេងទៀត និង/ឬបន្ថែមបទប្បញ្ញត្តិដែលដាក់ចេញនូវសិទ្ធិ និងកាតព្វកិច្ចជាក់លាក់របស់សម្បទានិកដីសម្បទានសង្គមកិច្ច។ | |
| មាត្រា ៦២ | សូមមើល មាត្រា ៥ នៃច្បាប់ស្តីពីសម្បទាន ឆ្នាំ២០០៧។<br>គួររៀបរាប់បញ្ចូលក្នុងមាត្រានេះនូវ សម្បទានអភិវឌ្ឍទេសចរណ៍ ព្រមទាំង សម្បទានអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធដូចចែងក្នុងច្បាប់ស្តីពីសម្បទាន ផង។<br><br>តើសម្បទានសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ស្ថិតនៅក្រោមច្បាប់នេះ ឬក៏ច្បាប់មួយទៀត?<br><br>ដីសម្បទានមិនគួរត្រូវបានចេញ/ដំណើរការទេ ប្រសិនបើដីនោះត្រួតលើដីដែលសហគមន៍ជនជាតិដើមភាគតិចទាមទាររហូតដល់ការទាមទាររបស់ជនជាតិដើមភាគតិចត្រូវបានវាយតម្លៃ និងដោះស្រាយ។ ក្នុងករណីដែលសម្បទានដីត្រូវបានផ្តល់អោយលើដីដែលជនជាតិដើមភាគតិចកាន់កាប់ និងប្រើប្រាស់តាមបែបប្រពៃណី និងសហគមន៍មិនមែនជនជាតិដើមភាគតិចផ្សេងទៀត ការផ្តល់សំណងគួរតែត្រូវបានផ្តល់ និងផ្តល់ដីឡើងវិញតាមដែលអាចធ្វើបាន។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៦៤ | ច្បាប់នេះគួរតែចែងឱ្យច្បាស់អំពីស្ថាប័នដែលមានសមត្ថកិច្ចចេញលិខិតសម្បទាដី (គោលការណ៍អនុញ្ញាតឱ្យផ្តល់ កែប្រែ ដកហូត ដីសម្បទានសេដ្ឋកិច្ច ឬសម្រេចអនុញ្ញាតឱ្យយកដីឯកជនរបស់រដ្ឋទៅផ្តល់សម្បទានសង្គមកិច្ច)។<br><br>លិខិតសម្បទានដី គួរតែត្រូវភ្ជាប់ដោយលក្ខខណ្ឌលម្អិត ដែលកំណត់ជាបន្ទុក និងក្នុងទម្រង់ជាកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ឬកិច្ចសន្យាបញ្ជាក់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដីក្នុងគម្រោងសម្បទានដីសង្គមកិច្ច។ | សូមកែកថាខណ្ឌទី៣នៃមាត្រានេះ ទៅជា លិខិតសម្បទានដីត្រូវតែភ្ជាប់ដោយលក្ខខណ្ឌលម្អិត ដែលកំណត់ជាបន្ទុក និងធ្វើឡើងក្នុងទម្រង់ជាកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ឬកិច្ចសន្យាបញ្ជាក់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដីក្នុងគម្រោងសម្បទានដីសង្គមកិច្ច។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ខណៈពេលដែលភាពស្មុគ្រស្មាញសម្រាប់ដំណើរការចុះបញ្ជីសម្បទានដីត្រូវបានដាក់ចេញក្នុងអនុក្រឹត្យ វាចាំបាច់ណាស់ក្នុងការបង្កើតច្បាប់ដែលដំណើរការបែបនេះត្រូវតែរួមបញ្ចូលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយអត្ថន័យជាមួយអ្នកដែលរងផលប៉ះពាល់ដោយការផ្តល់សម្បទានដី ជាពិសេសជនជាតិដើមភាគតិច ប្រជាជន សហគមន៍ប្រពៃណីក្នុងស្រុក ស្ត្រី យុវជន និងក្រុមងាយរងគ្រោះផ្សេងទៀត។ ការពិគ្រោះយោបល់ជាសាធារណៈបែបនេះធានាថា វិវាទដីធ្លីដែលអាចកើតមានឡើង ឬវិវាទផ្សេងទៀតត្រូវបានបង្ហាញជាមុននៅក្នុងដំណើរការ ហើយអាចជៀសវាង ឬចរចាបានកាន់តែមានប្រសិទ្ធភាព។ លើសពីនេះ ព័ត៌មានលម្អិតទាំងអស់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច (ដូចជាឈ្មោះសម្បទានិក ព័ត៌មានទំនាក់ទំនងលម្អិត ទំហំសម្បទានដី ការពិពណ៌នាគម្រោង និងពេលវេលាកំណត់ ។ល។) គួរតែផ្សព្វផ្សាយជាសាធារណៈដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់បានដឹងអំពីលក្ខណៈ វិសាលភាព និងស្ថានភាពនៃការវិនិយោគលើដីទាំងនេះ។<br><br>សេចក្តីយោងទៅ "តម្លៃកិច្ចសន្យា" គឺមិនច្បាស់លាស់។ តើនេះមានន័យថាលិខិត និងប្រយោគបង្កើតកាតព្វកិច្ចតាមកិច្ចសន្យាឬ? | |
| មាត្រា ៦៥ | សូមមើល មាត្រា ១៨ នៃអនុក្រឹត្យលេខ ១៩ អនក្រ បក ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច និង អនុក្រឹត្យលេខ ១៤៦ អនក្រ បក ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច។<br><br>គួរមានការចែងក្នុងច្បាប់នេះឱ្យច្បាស់អំពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងការសម្រេចដកហូតដីសម្បទាន សេដ្ឋកិច្ច។<br><br>អនុក្រឹត្យលេខ ១៤៦ អនក្រ បក ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច មិនបានចែងច្បាស់អំពីសមត្ថកិច្ច និងលក្ខខណ្ឌក្នុងការសម្រេចដកហូតដីសម្បទានសេដ្ឋកិច្ចទេ ។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។<br><br>"មិនគោរពតាមប្រការដាក់លាក់ដែលបានបញ្ជាក់ក្នុងកិច្ចសន្យា ឬមិនប្រើប្រាស់ដីតាមសម្បទានក្នុងរយៈពេល ១២ ខែ ដោយគ្មានហេតុផលទទួលយកសម្រាប់ការពន្យារពេល។" |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ការដកហូតដីសម្បទាន ខុសពី ការពន្យារ ការព្យួរ និងការបញ្ចប់កិច្ចសន្យាសម្បទាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច តាមការចែងក្នុងអនុក្រឹត្យលេខ ១៤៦ ឆ្នាំ២០០៥ ពុំមានសមត្ថកិច្ចក្នុងការដកហូតដីសម្បទានទេ។<br><br>សិទ្ធិសម្រេចដកហូតដីសម្បទានសង្គមកិច្ច មិនគួរ ផ្តល់ឱ្យតែក្រុមប្រឹក្សាឃុំសង្កាត់នោះទេ ប៉ុន្តែគួរផ្តល់ឱ្យអ្នកផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចនោះ និងរដ្ឋមន្ត្រីនៃក្រសួងទទួលបន្ទុកវិស័យសុរិយោដី ផង។<br><br>គួរជំនួសឃ្លាថា "ខចែងដោយឡែកដែលមានចែងក្នុងកិច្ចសន្យា" ដោយ "ខចែងជាលក្ខខណ្ឌដាច់ខាតក្នុងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច"។<br><br>ករណីមិនគោរពខចែងជាលក្ខខណ្ឌដាច់ខាត តុលាការត្រូវបង្គាប់ភាគីដែលមានកំហុស ឱ្យអនុវត្ត ឬបំពេញតាមលក្ខខណ្ឌនោះក្នុងអំឡុងពេលកំណត់ សមស្រប និងឱ្យសងសំណងការខូចខាតជាក់ស្តែង សិន មុននឹងឈានដល់ការសម្រេចទុកជាមោឃៈនៃលិខិតសម្បទានដីសេដ្ឋកិច្ច និងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច នោះ។<br><br>តើនេះមានគោលបំណងដើម្បីផ្តល់នូវដំណើរការសម្រាប់ការដកហូតឬ? តើវាគួរតែរួមបញ្ចូលៈ<br><br>១. ការសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការដកហូត<br>២. ប្តឹងឧទ្ធរណ៍ទៅតុលាការ<br>៣. សេចក្តីសម្រេចរបស់តុលាការលើបណ្តឹងឧទ្ធរណ៍។<br><br>ឬតើនេះពិចារណាវិធីពីរយ៉ាងដើម្បីដកហូតៈ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ១. ការសម្រេចចិត្តរបស់រដ្ឋាភិបាលដើម្បីលុបចោល; ឬ<br>២. ដំណើរការតុលាការប្រភេទមួយចំនួនដែលឯករាជ្យនៃការសម្រេចចិត្តរបស់រដ្ឋាភិបាល។ មិនច្បាស់៖ នេះគួរតែត្រូវបានបញ្ជាក់ឱ្យច្បាស់លាស់ និងដំណើរការ ឬដំណើរការដែលមានចែងនៅក្នុងច្បាប់ ឬនៅក្នុងបទប្បញ្ញត្តិ/អនុក្រឹត្យដែលកំពុងអនុវត្ត។<br><br>លើសពីនេះ ច្បាប់ភូមិបាលឆ្នាំ២០០១ មានប្រយោគល្អមួយចែងថា ប្រសិនបើក្រោយ ១២ខែ ដីមិនត្រូវបានធ្វើអាជីវកម្ម សម្បទានអាចនឹងត្រូវដកហូតវិញ ប៉ុន្តែវាហាក់ដូចជាត្រូវបានដកចេញនៅទីនេះ។ ឃ្លានេះគួរតែត្រូវបានរក្សាទុក។ | |
| មាត្រា ៦៦ | អត្ថបទនេះអាចយល់បានថាចង់កំណត់សិទ្ធិណាមួយនៃការកាន់កាប់មិនអំណោយផល ប៉ុន្តែវាបរាជ័យក្នុងការដោះស្រាយរបៀបគ្រប់គ្រងការកាន់កាប់ដីធ្លីដែលមិនទៀងទាត់ដែលមានស្រាប់ដោយគ្មានការផ្លាស់ទីលំនៅ។ ដោយមិនអនុវត្តដំណើរការស្នើសុំសម្រាប់ SLCs ជាជាងទុក SLCs ទៅតាមការសម្រេចចិត្តរបស់អាជ្ញាធរពាក់ព័ន្ធ ច្បាប់នេះទុកជម្រើសមួយចំនួនសម្រាប់កសិករនៅតាមជនបទក្នុងការប្រកបរបរចិញ្ចឹមជីវិត។<br><br>ដីសម្បទានមិនគួរត្រូវបានចេញ/ដំណើរការទេ ប្រសិនបើដីនោះត្រួតលើដីដែលសហគមន៍ជនជាតិដើមភាគតិចទាមទាររហូតដល់ការទាមទាររបស់ជនជាតិដើមភាគតិចត្រូវបានវាយតម្លៃ និងដោះស្រាយ។ ក្នុងករណីដែលសម្បទានដីត្រូវបានផ្តល់អោយលើដីដែលជនជាតិដើមភាគតិចកាន់កាប់ និងប្រើប្រាស់តាមបែបប្រពៃណី និងសហគមន៍មិនមែនជនជាតិដើមភាគតិចផ្សេងទៀត ការផ្តល់សំណងគួរតែត្រូវបានផ្តល់ និងផ្តល់ដីឡើងវិញតាមដែលអាចធ្វើបាន។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៦៧ | គួរចែងបញ្ជាក់អំពីសិទ្ធិពិសេសរបស់សម្បទានិក និងបញ្ជាក់អំពីអាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវការពារស្ថានភាពរបស់សម្បទានិក ព្រមទាំង ភារកិច្ច និងវិធានការ ដែលត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។<br><br>បន្ថែម៖ "និងកាតព្វកិច្ចគោរពព្រំដែន" |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | អនុក្រឹត្យលេខ ១៤៦ អនក្រ បក ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច មិនបានចែងច្បាស់អំពីសិទ្ធិពិសេស និងកិច្ចការពារនេះទេ។<br><br>សម្បទានិកគួរតែទទួលខុសត្រូវផងដែរចំពោះការជឹង និងគោរពព្រំដែនរវាងដីរបស់ពួកគេ និងដីផ្សេងទៀត។ នេះនឹងជួយដោះស្រាយជម្លោះមួយចំនួនដែលកើតឡើងរវាងសម្បទានដីសេដ្ឋកិច្ច និងសហគមន៍មូលដ្ឋាន។ | "សហគមន៍មូលដ្ឋានក៏មានសិទ្ធិទទួលបានការការពារប្រឆាំងនឹងការទន្ទ្រាន និងការរំលោភដីធ្លី និងទិដ្ឋភាពផ្សេងទៀតនៃការចិញ្ចឹមជីវិតរបស់ពួកគេដោយអ្នកសម្បទាន។ |
| មាត្រា ៦៨ | គួរបញ្ជាក់ក្នុងចំណងជើង និងខ្លឹមសារនៃមាត្រានេះថាអនុវត្តចំពោះតែសម្បទានដីសេដ្ឋកិច្ច។<br><br>គួរបញ្ជាក់ថា ក្នុងករណីស្លាប់គ្រួសារម្ចាស់សម្បទានអាចបន្តកាន់សិទ្ធិសម្បទាន។ | សូមកែសម្រួលស្របតាមយោបល់សម្រាប់មាត្រានេះ។<br><br>"លើកលែងតែករណីមរណភាពរបស់អ្នកកាន់កាប់សម្បទានដោយសារគ្រួសាររបស់ពួកគេអាចបន្តកាន់សិទ្ធិ" |
| មាត្រា ៦៩ | និយមន័យនៃ "អនុផលនៃដី" អាចមានប្រយោជន៍។ | |
| មាត្រា ៧០ | រាល់ដីសម្បទានថ្មីៗគួរតែត្រូវបានធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីថាជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលនៃនីតិសាធារណៈ មុនចេញលិខិតសម្បទាន និងចុះកិច្ចសន្យាសម្បទានជាមួយសម្បទានិក។<br>ចំពោះសម្បទានដីដែលមានស្រាប់កន្លងមក គួរតែតម្រូវឱ្យក្រសួងទទួលបន្ទុកគ្រប់គ្រងវិស័យសុរិយោដី លើកគម្រោងផែនការ និងសហការជាមួយអាជ្ញាធរ គ្រប់គ្រងដីរដ្ឋ អាជ្ញាធរដែនដី សម្បទានិក ឬមុខសញ្ញាអ្នកទទួលដី និងប្រជាពលរដ្ឋក្នុងនិងជុំវិញតំបន់ដីសម្បទាន សម្រាប់អនុវត្តនីតិវិធីចុះបញ្ជីកម្មសិទ្ធិពិសេស ឱ្យបានរួចរាល់ក្នុងអំឡុងយ៉ាងយូរ ៥ ឆ្នាំគិតចាប់ពីច្បាប់នេះចូលជាធរមាន។<br><br>ច្បាប់នេះគួរផ្តល់លទ្ធភាពឱ្យមុខសញ្ញាអ្នកទទួលដី សម្បទានដែលរស់នៅ ឬកាន់កាប់បង្កបង្កើនផលលើដីជាក់ស្តែងដោយផ្ទាល់ ក្នុងការប្រវាស់ ឬជួលផ្នែកខ្លះនៃដីតាមការបញ្ជាក់អនុញ្ញាតលាយល័ក្ខណ៍អក្សរពីមេឃុំ ចៅសង្កាត់ ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់ និងផលិតកម្មលើចំណែកដីស | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។<br><br>"សម្បទានដីសង្គមកិច្ចត្រូវចេញតាមរយៈដំណើរការប្រកបដោយតម្លាភាព និងការចូលរួម ហើយធានាបាននូវការពិគ្រោះយោបល់ជាមួយអ្នកទទួលសក្តានុពល ដើម្បីដោះស្រាយផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពួកគេ ស្របតាមការវាយតម្លៃសង្គម និងបរិស្ថាន។ ការផ្តល់សម្បទានដីសង្គមកិច្ចគួរតែជៀសវាងតំបន់ដែលមានជម្លោះដីធ្លីដែលមានស្រាប់ ឬសក្តានុពល និងតំបន់នៅជិតសហគមន៍ជនជាតិដើមភាគតិច ដែលប័ណ្ណកម្មសិទ្ធិសហគមន៍ជនជាតិដើមមិនទាន់បានចុះបញ្ជី។" |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ម្រាប់បង្កបង្កើនផល។<br>ពេលមុខសញ្ញាអ្នកទទួលដីក្នុងគម្រោងសម្បទានដី សង្គមកិច្ច បានអនុវត្តពេញលេញនូវលក្ខខណ្ឌជាច់ខាត និងគ្រប់ពេលកំណត់សម្រាប់លទ្ធកម្មកម្មសិទ្ធិលើដីសម្បទានសង្គមកិច្ច អ្នកផ្តួចផ្តើមគម្រោងសម្បទានដីសង្គមកិច្ច ឬរដ្ឋ គួរទទួលបន្ទុកក្នុងការស្នើសុំឱ្យរដ្ឋបាលសុរិយោដី ធ្វើការបំបែកក្បាលដី និងចុះបញ្ជីបន្តនូវការផ្ទេរកម្មសិទ្ធិលើដីនោះជូនមុខសញ្ញាអ្នកទទួលដី ដោយឥតបង់ថ្លៃ។<br><br>ក្រៅពីនេះដើម្បីដោះស្រាយចំពោះកំណើនប្រជាពលរដ្ឋ និងការថយចុះនូវដីឯកជនរបស់រដ្ឋដែលនៅទំនេរ ច្បាប់នេះគួរបង្កើតជម្រើសបន្ថែមទៀតនៃសម្បទានដីសង្គមកិច្ច ដែលផ្តល់ឱ្យដោយឥតគិតថ្លៃ ក្នុងទម្រង់ជាសិទ្ធិផលុបភោគ ឬសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានថ្លៃឈ្នួលស្មើសូន្យ។<br><br>គួរបញ្ជាក់ឱ្យច្បាស់ថា គ្មានសម្បទានដីសង្គមកិច្ចអាចត្រូវបានផ្តល់ដោយគ្មានការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់ ហើយថាសម្បទានមិនអាចផ្តល់ឱ្យលើដីដែលមានសិទ្ធិតាមប្រពៃណីរួចហើយនោះទេ។<br><br>គួរបន្ថែមគោលការណ៍ស្មុលសម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ចក្នុងច្បាប់ ដើម្បីជៀសវាងការទុកអ្វីៗទាំងអស់ទៅអនុក្រឹត្យ។<br><br>គួរតែដាក់បញ្ចូលពាក្យដែលឯកសារដែលផ្តល់កិច្ចសន្យាសម្បទានដីសង្គមកិច្ច ឬសម្បទានដីសង្គមកិច្ចត្រូវតែចេញ/ធ្វើឡើងក្នុងនាមប្តីប្រពន្ធទាំងពីរ ហើយថារាល់ការលក់បន្ត ឬផ្ទេរសម្បទានដីសង្គមកិច្ចដែលត្រូវបានអនុញ្ញាតបន្ទាប់ពីការប្រើប្រាស់ដីជាក់ស្តែងរយៈពេល ៥ឆ្នាំ ត្រូវតែទទួលបានការយល់ព្រមពីសមាជិកគ្រួសារទាំងអស់ដែលធ្វើការ ឬ/និងវិនិយោគលើដី។ | "ប្រសិនបើអ្នកទទួលដីសម្បទានសង្គមកិច្ច..."<br><br>"លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ និងដកហូតដីសម្បទានសង្គមកិច្ច..." |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | លក្ខខណ្ឌនៃការដកហូតក៏គួរត្រូវបានសរសេរក្នុងអនុក្រឹត្យដែរ។<br><br>សម្បទានដីសង្គមកិច្ចនឹងត្រូវចេញតាមរយៈដំណើរការប្រកបដោយតម្លាភាព និងការចូលរួម ហើយធានាបាននូវការពិគ្រោះយោបល់ជាមួយអ្នកដែលមានសក្តានុពលក្នុងការទទួលបានដើម្បីដោះស្រាយផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពួកគេ ស្របតាមការវាយតម្លៃសង្គម និងបរិស្ថាន។<br><br>ការផ្តល់សម្បទានដីសង្គមកិច្ច គួរតែជៀសវាងតំបន់ដែលជម្លោះដីធ្លីដែលអាចកើតមាន រួមទាំងអ្នកកាន់កាប់សិទ្ធិប្រពៃណី (លិខិតដែលបានផ្តល់ឱ្យត្រូវបានទទួលស្គាល់ - សូមមើលខាងលើ) និងតំបន់នៅជិតសហគមន៍ជនជាតិដើមភាគតិចដែលមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិចនៅឡើយ។<br><br>ច្បាប់គួរតែបញ្ជាក់ថាសម្បទានដីសង្គមកិច្ចនឹងត្រូវចេញតាមរយៈដំណើរការប្រកបដោយតម្លាភាព និងការចូលរួម ហើយធានាបាននូវការពិគ្រោះយោបល់ជាមួយអ្នកដែលមានសក្តានុពលក្នុងការទទួលបានដើម្បីដោះស្រាយផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពួកគេ ស្របតាមការវាយតម្លៃសង្គម និងបរិស្ថាន។<br><br>សូមពិចារណាផងដែរនូវវិធានការ និងយន្តការដែលមានប្រសិទ្ធភាពបន្ថែមទៀតសម្រាប់ការត្រួតពិនិត្យការអនុវត្តរបស់អ្នកទទួលដី និងការដកហូតសម្បទានដីសង្គមកិច្ចអសកម្ម និងការលុបចោលកិច្ចព្រមព្រៀងផ្ទេរកម្មសិទ្ធិឯកជនខុសច្បាប់ដែលបានធ្វើឡើងក្នុងអំឡុងពេលមានយុត្តាធិការ និងការផ្តល់សម្បទានដីសង្គមកិច្ចក្នុងទម្រង់ផ្សេងទៀតនៃការប្រើប្រាស់ដីធ្លី ដូចជាផលុបភោគ និង/ឬការជួលអចិន្ត្រៃយ៍ដែលគ្មានកម្រៃ។ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| មាត្រា ៧១ | មាត្រានេះចែងអំពីសិទ្ធិរបស់សម្បទានិកនៃសម្បទានដីសេដ្ឋកិច្ច ដូច្នេះគួរលុបចេញនូវឃ្លាចុងក្រោយនៃកថាខណ្ឌទី៤ ដែលថា "ឬអាចបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរហូតដល់គ្រប់ (៥)ប្រាំ ឆ្នាំ"។ ការកំណត់អំពីសិទ្ធិរបស់សន្តតិជនរបស់មុខសញ្ញាអ្នកទទួលដីសម្បទាន (សម្បទានិកនៃសម្បទានដីសង្គមកិច្ច) គួរចែងក្នុងមាត្រា ៧០។<br><br>ការប្រើពាក្យ "ភតិសន្យាអចិន្ត្រៃយ៍" នៅក្នុងកថាខណ្ឌទី 3 អាចបង្ក ការភ័ន្តច្រឡំ ដោយសារប្រយោគក្រោយមកនិយាយថា វាមិនបង្កើតការជួលអចិន្ត្រៃយ៍ទេ។<br><br>តើការបទបញ្ញត្តិនេះអនុវត្តតែនៅពេលដែលសម្បទានិកជាបុគ្គលមិនមែនជាក្រុមហ៊ុនទេ? បទបញ្ញត្តិនេះ សំដៅលើការស្លាប់របស់សម្បទានិក ដែលពាក់ព័ន្ធតែចំពោះអ្នកកាន់កាប់បុគ្គលប៉ុណ្ណោះ។ ប្រសិនបើមាត្រានេះអនុវត្តចំពោះតែបុគ្គលម្នាក់ៗ ឈ្មោះនៃមាត្រានេះអាចកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីចំនុចនេះ។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។<br><br>"សិទ្ធិសម្បទានបុគ្គលនៃសម្បទានដីសេដ្ឋកិច្ច"<br><br>"បានផ្តល់សិទ្ធិជួលដីរដ្ឋ" |
| មាត្រា ៧២ | គួរបញ្ជាក់ថា សម្បទានដីមិនអាចត្រូវបានផ្តល់ឱ្យលើដីដែលមានសិទ្ធិប្រពៃណីដែលមានស្រាប់នោះទេ។ | |
| មាត្រា ៧៣ | សូមមើលយោបល់ក្នុងមាត្រា ៧០។<br><br>ច្បាប់នេះគួរចែងបញ្ជាក់អំពីអត្ថន័យនៃ "ការគ្រប់គ្រងនីតិបុគ្គល ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដដែលៗ"ដែលទទួលបានលិខិតសម្បទានដីសេដ្ឋកិច្ច។<br><br>តើក្រោមច្បាប់ថ្មីនេះ ទំហំសរុបធំបំផុតនៃដីសម្បទានសេដ្ឋកិច្ច ត្រូវបានកំណត់ថាប៉ុន្មាន ? តើច្បាប់នេះនឹងនិរាករណ៍ច្បាប់ភូមិបាលឆ្នាំ២០០១ ឬទេ ? ដើម្បីជៀសវាងនូវការបេកស្រាយ ច្បាប់នេះគួរតែកំណត់ចិរវេលាអតិបរមានៃសម្បទានដីសេដ្ឋកិច្ច ស្របតាមការចែងអំពីសិទ្ធិជួលអចិន្ត្រៃយ៍ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី លក្ខខណ្ឌសំខាន់ៗសម្រាប់ការពន្យារចិរវេលា ឬបន្ត | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។<br><br>ជំនួស "គ្រប់គ្រងជាញឹកញាប់" ដោយ "គ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល"<br><br>"ដីសម្បទានសេដ្ឋកិច្ច មិនអាចផ្តល់ដោយគ្មានការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយអត្ថន័យ និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពិតប្រាកដ ដែលត្រូវបញ្ចប់មុនពេលផ្តល់សម្បទានដីសេដ្ឋកិច្ច ដោយមានការចូល |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចសារជាថ្មី ទំហំសរុបអតិបរមានៃដីសម្បទានសេដ្ឋកិច្ចដែលរូបវន្តបុគ្គល ឬនីតិបុគ្គលមួយ ឬដដែលៗ អាចទទួលបានដោយស្របច្បាប់។<br><br>ច្បាប់មុនបានកំណត់ទំហំអតិបរមានៃ ដីសម្បទានសេដ្ឋកិច្ច- យើងសូមផ្តល់អនុសាសន៍ឱ្យដាក់កម្រិតឡើងវិញ ដើម្បីធានាដីគ្រប់គ្រាន់សម្រាប់សហគមន៍ជនបទ។ ទោះបីជាទំហំដី ត្រូវបានចែងនៅក្នុងអនុក្រឹត្យក៏ដោយ វាជាការល្អបំផុតក្នុងការធ្វើម្តងទៀតនៅក្នុងមាត្រា នេះ ដើម្បីភាពច្បាស់លាស់។ លើសពីនេះ យើងសូមណែនាំថា សម្បទានដីសេដ្ឋកិច្ចដែលលើសពីទំហំដែលបានកំណត់ត្រូវតែលុបចោល ដែលអាចបង្កប់ន័យដោយកថាខណ្ឌទីមួយ។<br><br>ដើម្បីធានាថា ដីសម្បទានសេដ្ឋកិច្ច ជៀសវាងកំហុសទូទៅនៃការត្រួតស៊ីគ្នាជាមួយនឹងការទាមទារដីធ្លីរបស់សហគមន៍មូលដ្ឋាន លក្ខណគួរតែត្រូវបានកំណត់ដើម្បីធានាបាននូវការពិគ្រោះយោបល់ជាសាធារណៈ និង ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម។ | រួមប្រកបដោយប្រសិទ្ធភាព និងសំណាងពីប្រជាជនក្នុងតំបន់។" |
| មាត្រា ៧៤ និងមាត្រា ៧៥ | វិធានដី ព្រមទាំង គោលការណ៍ និងវិធាននៃការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរត្រូវអនុវត្តចំពោះទាំងកម្មសិទ្ធិករ និងម្ចាស់សិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុ រួមទាំង ភោគីភតិកៈ ផលុបភោគី សម្បទានិក មុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ច និងម្ចាស់សិទ្ធិស្របច្បាប់ផ្សេងទៀត។<br><br>តើវិធានដីធ្លីអ្វីខ្លះក្នុងមាត្រា៧៤? តើទាំងនេះខុសពីគោលការណ៍ និងវិធានដែលមានចែងក្នុងមាត្រា ៧៥ (ដែលហាក់ដូចជាសំដៅដល់ច្បាប់ស្តីពីការគ្រប់គ្រងដីធ្លី និង នគរូបនីយកម្មនាពេលខាងមុខ) ដែរឬទេ? | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៧៦ | គួរមានការចែងពន្យល់ក្នុងច្បាប់នេះឱ្យច្បាស់អំពីសិទ្ធិបុព្វក្រៃ របស់រដ្ឋ និងរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត ព្រមទាំងវិសាលភាពកម្មសិទ្ធិឯកជន របស់បុគ្គលឯកជន និងពន្យល់ថាការអនុវត្តសិទ្ធិបុព្វក្រៃ ខុសពីការធ្វើអស្សាមិករណ៍ ឬការដកហូតកម្មសិទ្ធិ ឬ សិទ្ធិស្របច្បាប់ផ្សេងៗ | សូមចែងពន្យល់អំពី សិទ្ធិបុព្វក្រៃ និងការអនុវត្តបន្ទាន់នៃវិធានដីដោយកម្រិតពីការប្រើប្រាស់កម្មសិទ្ធិ បើមិនដូច្នេះទេ សូមលុបមាត្រានេះចោល។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ទៀតលើអចលនវត្ថុ បែបណា។ បើមិនអាចពន្យល់បាន គួរតែកុំនិយាយអំពីសិទ្ធិបុព្វក្រៃ ក្នុងច្បាប់នេះអី។<br><br>តើការអនុវត្តបន្ទាន់នៃវិធានដីដោយកម្រិតពីការប្រើប្រាស់កម្មសិទ្ធិ មានន័យបែបណា?<br><br>"ផលប្រយោជន៍សាធារណៈ" ដូចដែលបានអនុវត្តនៅក្នុងមាត្រានេះ និងមាត្រាផ្សេងទៀតនៅក្នុងច្បាប់នេះ គួរតែត្រូវបានកំណត់ក្នុងនិយមន័យច្បាស់លាស់ ព្រោះថាផលប៉ះពាល់សម្រាប់ការវិនិយោគ - នៅកម្រិតដីផ្ទាល់ខ្លួន ឬកម្រិតអាជីវកម្មកសិកម្ម - នឹងមានផលប៉ះពាល់ប្រសិនបើមានការភ័យខ្លាចថាអចលនទ្រព្យអាចត្រូវបានដកហូត ដោយរដ្ឋនៅពេលណាក៏បាន។ បន្ថែមពីលើការអនុវត្តតាមច្បាប់ស្តីពីអស្សាមិករណ៍ មាត្រានេះអាចរួមបញ្ចូលការយោងទៅលើសំណង និងដំណើរការសមស្រប និងយុត្តិធម៌។ | |
| មាត្រា ៧៧ | តើ សេវភាពរដ្ឋបាល មានអ្វីខ្លះ ហើយបង្កើតឡើងដោយរបៀបណា ? តើការបង្កើតសេវាភាពរដ្ឋបាល មានអានុភាពស្មើនឹងការដកហូតមួយផ្នែក ឬមួយកម្រិត នូវសិទ្ធិស្របច្បាប់លើអចលនវត្ថុដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ មាត្រា ៥៨ និងច្បាប់អស្សាមិករណ៍ ឬទេ ?<br>រដ្ឋ គួរឈប់ និងជៀសវាងនូវការដកហូតមួយផ្នែក ឬមួយកម្រិតនូវសិទ្ធិឯកជនស្របច្បាប់ ឬសិទ្ធិសមូហភាពស្របច្បាប់ តាមការចេញសេចក្តីសម្រេចរដ្ឋបាល លិខិតបទដ្ឋានគតិយុត្ត បទបញ្ជា ឬច្បាប់ ដោយគ្មានការផ្តល់នូវសំណងសមរម្យ និងយុត្តិធម៌។ | សូមចែងបញ្ជាក់ និងពន្យល់លើសំណួរដែលលើកជាយោបល់ចំពោះមាត្រានេះ។ |
| មាត្រា ៧៨ | សូមមើលយោបល់ផ្នែកចុងក្រោយ ក្នុងមាត្រា ៧៧។<br>គួរមានការកំណត់ឱ្យច្បាស់អំពីអាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិអំណាចតាមមាត្រានេះ ព្រមទាំង ចែងអំពីនីតិវិធីបង្កើតសុពលភាពនៃសេចក្តីសម្រេចរបស់អាជ្ញាធរនេះ។ លើសពីនេះរាល់ការកំណត់ព្រំដី និងការផ្លាស់ប្តូរប្រភេទ ចំណាត់ថ្នាក់ និងទំហំផ្លូវ ក៏ដូចជាដីចំណី មិនត្រូវមានអានុភាពជាការដកហូតកម្មសិទ្ធិ សិទ្ធិភោគៈ ឬសិទ្ធិប្រត្យក្សស្របច្បាប់ផ្សេងៗលើដី ដែលមាន | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ជាក់ស្តែងមុនមានការកំណត់របស់អាជ្ញាធរនោះឡើយ ប៉ុន្តែអាចមានអានុភាពសម្រាប់អនុវត្តប្លង់តម្រង់ជួរថ្មី តែប៉ុណ្ណោះ។<br>គួរមានការចែងបញ្ជាក់អំពីអត្ថន័យនៃរបងធម្មតា ឬសំណង់ស្រាល និងការចេញថ្លៃចំណាយចំពោះការរុះរើសង់ថ្មីឡើងវិញ។ លើសពីនេះគោលការណ៍ក្នុងគោលនយោបាយដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គម គួរតែត្រូវបានយកមកអនុវត្តចំពោះការរុះរើរបង សំណង់ ដែលសង់តាមទម្លាប់ក្នុងមូលដ្ឋានកន្លងមកទោះមានច្បាប់អនុញ្ញាត ឬឥតច្បាប់អនុញ្ញាត ក៏ដោយ និងចំពោះដើមឈើកំពុង ឬជិត ផ្តល់ផលដែលត្រូវកាប់ចោល ផង។<br>ការសម្រេចពង្រីកទំហំផ្លូវក្នុងដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធកន្លងមក ជាទង្វើដកហូតសិទ្ធិភោគៈស្របច្បាប់ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ និងច្បាប់អស្សាមិករណ៍ ដូចកម្មសិទ្ធិស្ថាពរផងដែរ ដោយគ្មានផ្តល់សំណងសមរម្យ និងយុត្តិធម៌ ជាមុន។<br><br>ចំពោះករណីពាក់ព័ន្ធដីរបស់សហគមន៍ជនជាតិដើមភាគតិច សូមមើល មាត្រា ៣ ដល់មាត្រា ៥ មាត្រា ៨ មាត្រា ១០ មាត្រា ២៨ មាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចផង។<br><br>ដំណើរការចាត់ថ្នាក់ និង/ឬការកំណត់ព្រំដី និងការបោះបង្គោលព្រំដីឡើងវិញដើម្បីកំណត់ជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ការពង្រីកផ្លូវ និងសិទ្ធិសាធារណៈ និងការបម្រុងដីសម្រាប់ផ្លូវសាធារណៈមានលក្ខណៈមិនច្បាស់លាស់ ហើយទុកចន្លោះសម្រាប់វិវាទដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការដោះស្រាយការទាមទារដីធ្លី និងការអភិវឌ្ឍសហគមន៍ឱ្យបានរីកចម្រើន។<br><br>អត្ថបទនេះគួរកែសម្រួលដើម្បីបញ្ជាក់ដំណើរការនេះ និងបង្កើនតម្លាភាព - រួមទាំងលក្ខន្តិកៈច្បាស់លាស់សម្រាប់ការជូនដំណឹង និងការពិគ្រោះយោបល់ជាមួយសហគមន៍ពាក់ព័ន្ធ និងការ | |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | អនុញ្ញាតឱ្យមានការប្តឹងផ្តល់ចំពោះដីដែលបានចាត់ថ្នាក់ និង/ឬចាត់ថ្នាក់ឡើងវិញ ឬការពង្រីក ឬការបម្រុងដី នឹងធានាថាអ្នកកាន់កាប់សិទ្ធិស្របច្បាប់ត្រូវបានគោរព និងការពារដោយរដ្ឋ។ | |
| មាត្រា ៨០ | ជាការល្អដែលគួរមាន គោលការណ៍ និងនីតិវិធីពិសេសដោយឡែកសម្រាប់ការចុះបញ្ជីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត និងសម្រាប់ការចុះបញ្ជីក្បាលដីធំៗដែលចាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត ដើម្បីសម្រួល និងពន្លឿននូវការចុះបញ្ជីដីរបស់រដ្ឋ និងរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត ដើម្បីអាចគ្រប់គ្រង និងចាត់ចែងមានប្រសិទ្ធភាពស្របតាមការចែងក្នុងច្បាប់នេះ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។<br><br>គោលការណ៍ និងនីតិវិធីពិសេសនេះ គួរអនុវត្តចំពោះដីរបស់សហគមន៍ជនជាតិដើមភាគតិច ផង។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៨២ | គួរបញ្ចូល និងញែក កម្មសិទ្ធិសមូហភាព (ដីរបស់សហគមន៍ជនជាតិដើមភាគតិច ដីរបស់វត្ត និងដី បញ្ចុះសព) ចេញពី កម្មសិទ្ធិសាធារណៈ និងកម្មសិទ្ធិឯកជនរបស់បុគ្គលឯកជន។<br><br>សូមមើល មាត្រា ៣ ដល់មាត្រា ៥ មាត្រា ២៥ ដល់មាត្រា ២៧ និងមាត្រា ៣២ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចផង។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៨៣ | គួរបញ្ជាក់ថាក្នុងបញ្ជីដីឈ្មោះច្រើនអាចមាននៅលើប័ណ្ណកម្មសិទ្ធិ ព្រោះច្បាស់ពីច្បាប់នេះ និងក្រមរដ្ឋប្បវេណី។ | "អត្តសញ្ញាណរបស់ម្ចាស់" |
| មាត្រា ៨៤ | គួរមានសៀវភៅចុះបញ្ជីសិទ្ធិលើសម្បទានដីសង្គមកិច្ច ការដកហូតដីសម្បទានពីមុខសញ្ញាទទួលដីដែលបំពាន និងលទ្ធកម្មកម្មសិទ្ធិតាមរយៈសម្បទានដី សង្គមកិច្ចផង។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៨៧ | មុនពេលផុតអំឡុងពេលកំណត់សម្រាប់ការរក្សាទុកនូវឯកសារសុរិយោដីទាំងឡាយ គួរតម្រូវឱ្យធ្វើបរិវត្តកម្មឯកសារសុរិយោដីទាំងឡាយ ទៅជាទម្រង់ឌីជីថល ហើយរក្សាទុកក្នុងប្រព័ន្ធទិន្នន័យឌីជីថលជាអចិន្ត្រៃយ៍។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ និងស្របតាមមាត្រា ១០១។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| មាត្រា ៨៨ | "ប្រភេទនៃការប្រើប្រាស់ដី" បន្ថែមការប្រើប្រាស់ជាលក្ខណៈប្រពៃណី ដើម្បីធានាថាការប្រើប្រាស់ដីស្របច្បាប់ទាំងអស់ត្រូវបានទទួលស្គាល់។<br><br>ដោយ ផ្នែកអំពីសហកម្មសិទ្ធិ និងកម្មសិទ្ធិសហព័ទ្ធរួមគ្នាមានច្រើន សេចក្ដីយោងណាមួយចំពោះអ្នកកាន់កាប់/ម្ចាស់គួរតែរួមបញ្ចូលឯកសារយោងពហុវចនៈផងដែរ។ | "ប្រភេទនៃការប្រើប្រាស់ដី រួមទាំងប្រពៃណី តំបន់ប្រើប្រាស់ដី..."<br>"ត្រូវចេញឱ្យតែម្ចាស់អចលនវត្ថុប៉ុណ្ណោះ" |
| មាត្រា ៩៨ | ការតម្រូវឱ្យធ្វើបច្ចុប្បន្នភាពព័ត៌មាន និងទិន្នន័យសុរិយោដីនៅគ្រប់ជាន់ថ្នាក់ដំណាលគ្នា ជាគោលការណ៍ល្អ ប៉ុន្តែមុនពេលមានប្រព័ន្ធសុរិយោដីបែប ឌីជីថលដែលមានដំណើរការយ៉ាងមានប្រសិទ្ធភាព និងសុវត្ថិភាព តើរដ្ឋបាលសុរិយោដីអាចធ្វើបច្ចុប្បន្នភាពដំណាលគ្នាយ៉ាងម៉េចកើត ? គួរចែងក្នុងអន្តរ បញ្ញត្តិអំពីការអនុវត្តកថាខណ្ឌទី៣នៃមាត្រានេះ។ | សូមចែង តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ៩៩ | ការចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ថា "ការប្រើប្រាស់ព័ត៌មាន និងទិន្នន័យសុរិយោដីដែលផ្តល់ដោយរដ្ឋបាលសុរិយោដី មិននាំឱ្យជាប់ការទទួលខុសត្រូវរបស់រដ្ឋបាលសុរិយោដីឡើយ" មានអានុភាពមិនស្របគ្នា ឬមិនគាំទ្រចំពោះការចែងក្នុងកថាខណ្ឌទី៤ នៃមាត្រាទី៨៨ ដែលចែងថា "ទម្រង់ដែលមានព័ត៌មានសុរិយោដី និងចេញដោយរដ្ឋបាលសុរិយោដី គឺជាមូលដ្ឋាននៃការអះអាងជាផ្លូវការមួយនៃលិខិតគតិយុត្ត" ហើយក៏មិនស្របតាមគោលការណ៍នៃអភិបាលកិច្ច គឺគណនេយ្យភាពនៃទង្វើរបស់ភ្នាក់ងារ ឬអង្គភាពរដ្ឋ។<br><br>សូមមើលយោបល់ក្នុងមាត្រា ៧ ផង។<br><br>ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលការណ៍នៃការធានារបស់រដ្ឋអំពីកម្មសិទ្ធិ (រួមទាំងសិទ្ធិពិតប្រាកដស្របច្បាប់ផ្សេងទៀត) ច្បាប់គួរតែផ្តល់ការទទួលខុសត្រូវ ប្រសិនបើទង្វើ ឬការសម្រេចចិត្តរបស់រដ្ឋបាលសុរិយោដី (និងភ្នាក់ងារដែលធ្វើសកម្មភាពជំនួសខ្លួន) រាជរដ្ឋាភិបាល និងស្ថាប័នរដ្ឋ (ដូចជា ក្រសួងទទួលបន្ទុករដ្ឋបាលសុរិយោដី) ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់តតិយជនស្លូតត្រង់ ដែលពឹងផ្អែកទាំងស្រុងលើព័ត៌មានដែលបានកត់ត្រាក្នុងបញ្ជីដីធ្លី និង/ឬផ្តល់នៅ | សូមលុបកថាខណ្ឌទី៣នៃមាត្រានេះចោល ឬរដ្ឋបាលសុរិយោដី ត្រូវទទួលខុសត្រូវចំពោះព្យុះសនកម្មដែលបង្កឡើងដោយការផ្តល់ពត៌មាននិងទិន្នន័យសុរិយោដីមិនត្រឹមត្រូវ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ក្នុងព័ត៌មាន/វិញ្ញាបនបត្រសុរិយោដីដែលទទួលបានពីរដ្ឋបាលសុរិយោដី ។ នៅពេលដែលរដ្ឋអនុវត្តសិទ្ធិដកហូតកម្មសិទ្ធិឯកជន រដ្ឋត្រូវចំណាយលើការចំណាយទាំងអស់ និងការចំណាយពាក់ព័ន្ធផ្សេងទៀតទាំងសម្រាប់ការកែតម្រូវក្បាលដីដែលរងផលប៉ះពាល់ដោយសកម្មភាពនៃការទទួលយក/ការដកហូតរបស់រដ្ឋ និងការចុះបញ្ជីជាបន្តបន្ទាប់នៃការផ្លាស់ប្តូរក្បាលដី ។ | |
| មាត្រា ១០១ | យើងសូមគាំទ្រពេញទំហឹងចំពោះការកសាងប្រព័ន្ធទិន្នន័យឌីជីថល និងធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសុរិយោដី ដើម្បីជំរុញការផ្តល់សេវាសាធារណៈក្នុងវិស័យសុរិយោដីឱ្យកាន់តែប្រសើរ។ | |
| មាត្រា ១០២ ដល់មាត្រា ១០៥ | គួរចែងបញ្ចូលឱ្យច្បាស់នូវ មន្ត្រីតំណាងអាជ្ញាធរកាន់កាប់ដីរដ្ឋ មន្ត្រីរបស់យន្តការគ្រប់គ្រងដីរដ្ឋ របស់យន្តការគ្រប់គ្រងអចលនវត្ថុរបស់រដ្ឋ និងរបស់នីតិបុគ្គលនៃនីតិសាធារណៈ ថាត្រូវមានកាតព្វកិច្ចចូលរួម និងសហការណ៍ក្នុងដំណើរការនៃសម្រង់សុរិយោដី ផងដែរ។ ការខកខានមិនបានចូលរួមសហការណ៍ និងធ្វើការជំទាស់តវ៉ាក្នុងពេលបិទផ្សាយជាសាធារណៈនូវ ឯកសារនៃការវិនិច្ឆ័យ អាចនាំឱ្យបាត់បង់សិទ្ធិលើអចលនវត្ថុនោះដោយសារការធ្វេសប្រហែសលើការគ្រប់គ្រង ឬការកាន់កាប់អចលនវត្ថុនោះ លើកលែងតែមានអំពើឃុបគិតខុសច្បាប់ ឬបំពានធ្ងន់ធ្ងរលើនីតិវិធីចុះបញ្ជីដីធ្លីដែលនាំឱ្យមានការខកខានក្នុងការចូលរួមសហការណ៍ និងជំទាស់តវ៉ានោះ។ ការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ និងរបស់ក្រសួងស្ថាប័នសាធារណៈ ព្រមទាំងរបស់មន្ត្រី ឬភ្នាក់ងារតំណាងឱ្យស្ថាប័នសាធារណៈក្នុងការកាន់កាប់ ឬគ្រប់គ្រងដីធ្លី ត្រូវមានកម្រិតដូចគ្នាស្របតាមគោលការណ៍ស្មើភាពចំពោះមុខច្បាប់។<br><br>គួរបន្ថែមបទប្បញ្ញត្តិលើកទឹកចិត្តឱ្យអ្នកគ្រប់គ្នាមើលព័ត៌មាន ជាសាធារណៈ បង្ហាញឯកសារទាក់ទងនឹងក្បាលដីនៅក្នុងសហគមន៍របស់ពួកគេលើសពីក្បាលដីរបស់ពួកគេ ហើយដាក់ពាក្យបណ្តឹងប្រឆាំងនឹងដីដែលមានបញ្ហា ឬមិនបានកាន់កាប់/ឬកាន់កាប់ដោយខុសច្បាប់ដែលត្រូវបានទាមទារដោយជនណាម្នាក់ ។<br>VGGT para. ១៧.៣ ចែងថា "រដ្ឋគួរតែខិតខំដើម្បីធានាថាមនុស្សគ្រប់គ្នាអាចកត់ត្រាសិទ្ធិកាន់កាប់របស់ពួកគេ និងទទួលបានព័ត៌មានដោយគ្មានការរើសអើងលើមូលដ្ឋានណាមួយ។ ក្នុង | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រាទាំងនេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ករណីសមស្រប ភ្នាក់ងារអនុវត្ត ដូចជាការចុះបញ្ជីដីធ្លី គួរតែបង្កើតមជ្ឈមណ្ឌលសេវាកម្ម ឬការិយាល័យចល័ត ដោយគិតពីលទ្ធភាពទទួលបានពីស្ត្រី ក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ។ សូមមើលផងដែរនូវមតិយោបល់ខាងលើទាក់ទងនឹងរដ្ឋធម្មនុញ្ញកម្ពុជា និង CEDAW ដែលហាមឃាត់ការរើសអើងលើស្ត្រី។<br><br>កងកម្លាំងប្រដាប់អាវុធមិនគួរមានការពាក់ព័ន្ធទេ ដោយយោងទៅលើច្បាប់ស្តីពីលក្ខន្តិកៈយោធានៃកងយោធពលខេមរភូមិន្ទ។ មាត្រានេះគួរតែសំដៅទៅលើប៉ូលិសយុត្តិធម៌ជាជាងកម្លាំងប្រដាប់អាវុធ។<br><br>ទាក់ទងនឹងមាត្រា ១០៣៖ ដោយផ្អែកលើផ្នែកលម្អិត ស្តីពីសហកម្មសិទ្ធិ និងកម្មសិទ្ធិសហព័ទ្ធរួមគ្នា សេចក្តីយោងណាមួយចំពោះអ្នកកាន់កាប់/ម្ចាស់ គួរតែរួមបញ្ចូលឯកសារយោងជាច្រើនដែលពាក់ព័ន្ធផងដែរ។<br><br>ទាក់ទងនឹងមាត្រា ១០៤៖ ដើម្បីធានាបាននូវអក្ខរកម្ម និងការយល់ដឹងផ្នែកច្បាប់នៅកម្រិតសហគមន៍ ក៏ដូចជាលើកកម្ពស់ការដាក់បញ្ចូលក្នុងរាជរដ្ឋាភិបាល  ពិចារណាលើការផ្សព្វផ្សាយឯកសារអប់រំជាមូលដ្ឋានដែលពន្យល់អំពីដំណើរការ និងសិទ្ធិបន្ថែមលើឯកសារវិនិច្ឆ័យ ក៏ដូចជាការផ្សព្វផ្សាយដែលផ្តោតជាក់លាក់លើស្ត្រី យុវជន និងក្រុមងាយរងគ្រោះ។<br><br>ទាក់ទងនឹងមាត្រា១០៥៖ កងកម្លាំងប្រដាប់អាវុធមិនគួរមានការពាក់ព័ន្ធទេ ដោយយោងទៅលើលក្ខន្តិកៈទូទៅសម្រាប់មន្ត្រីយោធានៃកងយោធពលខេមរភូមិន្ទ។ អត្ថបទនេះអាចប្រើប្រាស់ប៉ូលិសយុត្តិធម៌ជំនួសកងកម្លាំងប្រដាប់អាវុធ។ | |
| មាត្រា ១០៧ | អនុក្រឹត្យ គួររួមបញ្ចូលព័ត៌មានលម្អិតជាក់លាក់ដែលនឹងបញ្ជាក់អំពីនីតិវិធីសម្រាប់ការប្រើប្រាស់ដំណើរការរបស់គណៈកម្មការសុរិយោដីប្រកបដោយប្រសិទ្ធភាព។ | "ដោយអនុក្រឹត្យ ដែលរួមមានវិធានស្តីពីវិសាលភាព និងយុត្តាធិការ ការស្នើសុំការវិនិច្ឆ័យ សិទ្ធិរបស់ភាគី លក្ខន្តិកៈនៃ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | | ការកំណត់ ការជ្រើសរើស និងសមាសភាពនៃក្រុមជំនុំជំរះ នីតិវិធី ការផ្ដល់សេចក្ដីសម្រេច និងសិទ្ធិប្ដឹងទៅកាន់តុលាការ។" |
| មាត្រា ១០៩ | គួរលុបមាត្រានេះចោល ហើយដាក់ជំនួសវិញនូវការចែងថា ករណីមានបណ្ដឹង ទាមទារសិទ្ធិលើដីដែលតំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យរដ្ឋ ឬរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត អះអាង និងបង្ហាញសម្អាងសមរម្យ ថាជាប្រភេទដីសាធារណៈ ឬទ្រព្យសម្បត្តិសាធារណៈ ទោះជាមិនទាន់បានចុះបញ្ជីកម្មសិទ្ធិក៏ដោយ គណៈកម្មការសុរិយោដី ត្រូវលើកចោលបណ្ដឹងនោះ និងបើកសិទ្ធិឱ្យប្ដឹងទាមទារទៅតុលាការមានសមត្ថកិច្ចនៃទីតាំងអចលនវត្ថុ ។ ការខកខានរបស់គណៈកម្មការសុរិយោដីក្នុងការសម្រេចចាត់ការលើបណ្ដឹង ឬ និងក្នុងការលើកចោលបណ្ដឹងក្នុងរយៈពេល ១៨០ ថ្ងៃប្រតិទិន គិតចាប់ពីពេលទទួលបានបណ្ដឹង ត្រូវបើកសិទ្ធិដោយស្វ័យប្រវត្តឱ្យប្ដឹងទាមទារទៅតុលាការមានសមត្ថកិច្ច។<br><br>កន្លងមកភាពមិនដំណើការតាមនីតិវិធីឱ្យបានឆាប់រហ័សរបស់យន្តការគណៈកម្មការសុរិយោដីលើករណីវិវាទដីធ្លីមួយចំនួន បានក្លាយជារនាំងរារាំងសិទ្ធិទទួលបានយុត្តិធម៌។<br><br>ខណៈពេលដែលវាមានសារៈសំខាន់ក្នុងការមានស្ថាប័នពិសេសសម្រាប់ដោះស្រាយវិវាទដីធ្លី គណៈកម្មការសុរិយោដីមិនគួរមានសិទ្ធិអំណាចផ្ដាច់មុខលើវិវាទដីធ្លីចំពោះការបដិសេធសិទ្ធិនៃការប្ដឹងតវ៉ាណាមួយ និង/ឬសិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌ទាន់ពេលវេលានោះទេ។ ក្នុងករណីដែលភាគីវិវាទយល់ថា សកម្មភាព ឬសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីមិនបានអនុវត្តតាមច្បាប់ ឬកំណត់ពេលវេលាតាមនីតិវិធី ពួកគេគួរតែមានសិទ្ធិយ៉ាងច្បាស់លាស់នៃបណ្ដឹងសម្រាប់ការវិនិច្ឆ័យចុងក្រោយ និងជាប់កាតព្វកិច្ចដោយគ្មានការពន្យារពេលដោយអយុត្តិធម៌។ លក្ខខណ្ឌដែលភាគីជម្លោះអាចស្វែងរកដំណោះស្រាយតាមផ្លូវតុលាការគួរតែត្រូវបានដាក់ឱ្យច្បាស់ក្នុងបទប្បញ្ញត្តិបន្ថែមទៀត។ ដោយពាក់ព័ន្ធនោះគឺគណៈកម្មការសុរិយោដីគួរតែតម្រូវឱ្យចេញសេចក្ដី | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | សម្រេចក្នុងរយៈពេលកំណត់ ដើម្បីជៀសវាងការពន្យារពេលមិនសមហេតុផល និងធានាថា ការសម្រេចចិត្តត្រូវបានចេញ ឬជាដែនសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីត្រូវបានលុបចោល។<br><br>ចំពោះករណីវិវាទ ឬទំនាស់ជាមួយសហគមន៍ជនជាតិដើមភាគតិច សូមមើលយោបល់ក្នុងមាត្រា ៣៦ (អំពីក្រុមការងារពិសេសចាត់តាំងដោយក្រសួងទទួលបន្ទុកវិស័យសុរិយោដី និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ) និងសូមមើល មាត្រា ៤០ មាត្រា ៨មាត្រា ១០ មាត្រា ២៨ មាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ផង។ | |
| មាត្រា ១១០ | គួរចែងថា គណៈកម្មការសុរិយោដីត្រូវចាត់ការដោះស្រាយវិវាទឱ្យចប់សព្វគ្រប់តាំងពីថ្នាក់ក្រុងស្រុកខណ្ឌដល់ថ្នាក់ជាតិក្នុងរយៈពេល ១៨០ ថ្ងៃប្រតិទិន គិតចាប់ពីពេលទទួលបានបណ្តឹង ហើយបើកសិទ្ធិដោយស្វ័យប្រវត្តឱ្យប្តឹងទាមទារទៅតុលាការមានសមត្ថកិច្ចពេលផុតរយៈពេលកំណត់នេះ។<br><br>គួរអនុវត្តផងចំពោះវិវាទរវាងភាគី និងភាគីឯកជនម្ខាងទៀតដែលកាន់វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) លើភាគខ្លះនៃដីវិវាទ ខណៈភាគខ្លះទៀតនៃដីវិវាទ មិនទាន់មានប័ណ្ណកម្មសិទ្ធិ ទោះជាដីនោះត្រូវបានចុះក្នុងបញ្ជីសំគាល់សិទ្ធិភោគៈ ឬសិទ្ធិកាន់កាប់ប្រើប្រាស់ ឬនិងអាស័យផលលើដីធ្លីឬអចលនវត្ថុ ក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ លើកលែងតែផ្អែកតាមការព្រមព្រៀងដោយស្ម័គ្រចិត្តរបស់គូភាគីវិវាទសម្រាប់ដោះស្រាយករណីវិវាទនោះ គណៈកម្មធិការសុរិយោដី មិនអាចសម្រេចផ្ទុយពីខ្លឹមសារនៃវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ដែលមានសុពលភាពត្រឹមត្រូវឡើយ។<br><br>ចំពោះករណីវិវាទ ឬទំនាស់ជាមួយសហគមន៍ជនជាតិដើមភាគតិច សូមមើលយោបល់ក្នុងមាត្រា ៣៦ (អំពីក្រុមការងារពិសេសចាត់តាំងដោយក្រសួងទទួលបន្ទុកវិស័យសុរិយោដី និងគណៈកម្ម | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ការសុរិយោដីថ្នាក់ជាតិ) និងសូមមើល មាត្រា ៤០ មាត្រា ៨មាត្រា ១០ មាត្រា ២៨ មាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ នៃសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច។ | |
| មាត្រា ១១៣ | មុខតំណែងនេះ មានអំណាចច្រើនដោយគ្មានការត្រួតពិនិត្យច្បាស់លាស់។ ប្រកាសអាចរួមបញ្ចូលបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យ ឬច្បាប់នេះអាចរួមបញ្ចូលឃ្លាដែលកត់សម្គាល់ពីសក្តានុពលសម្រាប់ការដាក់ទណ្ឌកម្មចំពោះការខកខានក្នុងការអនុវត្តភារកិច្ចឱ្យបានត្រឹមត្រូវ។ | "ដោយប្រកាសរបស់ MLMUPC និងត្រូវទទួលទណ្ឌកម្មចំពោះការខកខានក្នុងការអនុវត្តភារកិច្ចដោយយុត្តិធម៌ និងប្រកបដោយប្រសិទ្ធភាព។" |
| មាត្រា ១១៦ | កាលបរិច្ឆេទកាត់ផ្តាច់ឆ្នាំ២០០១ គឺមានភាពចម្រូងចម្រាស និងអយុត្តិធម៌ចំពោះអ្នកដែលបានកាន់កាប់ដីដោយសន្តិវិធីតាំងពីឆ្នាំ២០០១។ ដូច្នេះ កាលបរិច្ឆេទកាត់ផ្តាច់ថ្មីគួរតែត្រូវបានបង្កើតឡើងសម្រាប់ការកាន់កាប់ស្របច្បាប់។ | |
| មាត្រា ១១៧ | តើការចុះបញ្ជីភោគៈមិនគ្រប់គ្រាន់ ឬការចុះបញ្ជីកម្មសិទ្ធិមិនគ្រប់គ្រាន់ មានន័យដូចម្តេច ? តើឯកសារត្រឹមត្រូវ និងពេញលេញរបស់រដ្ឋបាលសុរិយោដី មានន័យដូចម្តេច ?<br>គួរមានការចែងកំណត់ឱ្យច្បាស់លាស់អំពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងការបញ្ជាឱ្យអ្នកកាន់កាប់អចលនវត្ថុ តាមការចែងក្នុងប្រយោគទី១នៃកថាខណ្ឌទី១ ចាកចេញពីទីតាំងអចលនវត្ថុនោះ ព្រមទាំង មូលហេតុនៃការបញ្ជាឱ្យចាកចេញ។<br>ជាការចាំបាច់ដែលអាជ្ញាធរមានសមត្ថកិច្ច ត្រូវគោរពការណ៍ដែលចែងក្នុងកថាខណ្ឌចុងក្រោយនៃមាត្រា១២០ (ដែលគោលការណ៍នេះក៏មានចែងក្នុងមាត្រា ៤២ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ជាធរមាន ផងដែរ)។ | |
| មាត្រា ១១៨ | អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ គួរអនុវត្តចំពោះតែអចលនវត្ថុរបស់បុគ្គលឯកជនដែលបានចុះបញ្ជីកម្មសិទ្ធិ និងចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ រួចហើយ។<br>ចំពោះអចលនវត្ថុដែលឋិតក្នុងការកាប់កាប់ជាភោគៈ ទោះមានប័ណ្ណ ឬអត់បណ្ណ ត្រូវរក្សាទុកក្រោមវិធានស្តីពីភោគៈ រួមទាំង ការបោះបង់ភោគៈ៣ឆ្នាំជាប់ៗគ្នា ការកាន់កាប់ជាប់លាក់ និងការតវ៉ាចំពោះអ្នកដែលមកទន្ទ្រានលើដីភោគៈ ស្របតាមគោលការណ៍ក្នុងច្បាប់ភូមិបាល ឆ្នាំ២០០១ (មាត្រា ៤០ ) ដែលមានបញ្ចូលក្នុងមាត្រា ១២១ នៃសេចក្តីព្រាងច្បាប់។ | សូមលុបកថាខណ្ឌចុងក្រោយនៃមាត្រានេះចេញ ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | សូមមើល ក្រមរដ្ឋប្បវេណី មាត្រា ១៦២។ | |
| មាត្រា ១១៩ | សូមមើលយោបល់ពាក់ព័ន្ធនឹងការកំណត់ថាជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលនៃនីតិសាធារណៈ (ក្នុងមាត្រា ២០)។<br>ក្នុងកថាខណ្ឌចុងក្រោយនៃមាត្រានេះ ឃ្លាដែលថា "ត្រូវទុកជាសម្បត្តិរដ្ឋ" គួរកែថា "ត្រូវរក្សាឋានៈជាទ្រព្យសម្បត្តិរដ្ឋ ដែលគ្មានបន្ទុកកាន់កាប់ជាភោគៈ ប៉ុន្តែអាចមានបន្ទុកប្រើប្រាស់ អាស្រ័យផលសេវភាព ឬ ផលុបភោគ តាមស្ថានភាពជាក់ស្តែង និងស្ថានភាពគតិយុត្ត"។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ១២១ | យើងត្រូវការភាពច្បាស់លាស់បន្ថែមទៀតលើអ្វីដែលប្លង់ទន់ និងទម្រង់នៃភស្តុតាងផ្សេងទៀតនឹងមានកម្រិតនៃការទទួលស្គាល់ភស្តុតាង ស្ថានភាពផ្លូវច្បាប់របស់ពួកគេនឹងស្ថិតក្នុងពេលនេះ និងដំណើរការបែបណាសម្រាប់ការបំប្លែងឯកសារទាំងនោះទៅជាប្លង់រឹង។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ១២២ | រយៈពេលលើសពី ១៥ ថ្ងៃ គួរតែកំណត់ជាថ្ងៃប្រតិទិន ដើម្បីងាយស្រួលក្នុងការរាប់ចំនួនថ្ងៃ ហើយ រយៈពេលជាខែ ឬសប្តាហ៍ គួរប្តូរជាចំនួនថ្ងៃវិញ ហើយរយៈពេលមួយឆ្នាំត្រូវគិតថា ៣៦៥ ថ្ងៃប្រតិទិន។<br><br>ការចុះបញ្ជីដីធ្លីគឺជាអាទិភាពចម្បងរបស់ MLMUPC និងរាជរដ្ឋាភិបាល។ ដើម្បីគាំទ្រដល់ការចុះបញ្ជីយ៉ាងទូលំទូលាយ បុគ្គលទាំងឡាយគួរតែអាចដាក់ពាក្យស្នើសុំចុះបញ្ជី និងចេញវិញ្ញាបនបត្រនៃភាពជាម្ចាស់ នៅពេលដែលពួកគេបំពេញតាមតម្រូវការច្បាប់។ ការអនុញ្ញាតឱ្យរដ្ឋបាលសុរិយោដី ដែលជារឿយៗត្រូវចំណាយលើសទម្ងន់ និងខ្វះធនធាន ដើម្បីកំណត់ថាតើនៅពេលណា និងប្រសិនបើការចុះឈ្មោះដោយឯកឯងអាចកើតឡើង ទំនងជានឹងបញ្ឈប់ដំណើរការលើកិច្ចខិតខំប្រឹងប្រែងចុះឈ្មោះ។ ការកំណត់ពេលវេលាសម្រាប់ដំណើរការការទាមទារចុះបញ្ជីជាបណ្តោះអាសន្នអាចជួយជៀសវាងលទ្ធផលអវិជ្ជមាននេះដោយមិនដាក់បន្ទុកលើមន្ត្រីសុរិយោដីដើម្បីដំណើរការការទាមទារភ្លាមៗ។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| មាត្រា ១២៣ | ដើម្បីឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ លុះត្រាតែមានចេតនាប្រព្រឹត្តបទល្មើសដែលច្បាប់បានកំណត់។ ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុឱ្យបុគ្គលមិនមែនជាភោគីពិតប្រាកដ ដោយសារអំពើរបស់បុគ្គល ឬមន្ត្រីសាធារណៈផ្សេងទៀត ធ្វើការក្លែងបន្លំ បំភាន់ ឬបញ្ជាក់អះអាងខុសពីការពិត មិនគួរឱ្យរដ្ឋបាលសុរិយោដី ទទួលខុសត្រូវទេ ប្រសិនបើមន្ត្រីសុរិយោដីពាក់ព័ន្ធមិនបានដឹងហេតុ នៃការក្លែងបន្លំ ការបំភាន់ ឬការបញ្ជាក់អះអាងខុសពីការពិតនោះ ហើយមានការអនុវត្តយ៉ាងត្រឹមត្រូវពេញលេញតាមនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុនោះ។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ១២៥ | ការបន្ថែម "សមធម៌" ដើម្បីបង្ហាញពីគោលការណ៍នៃយុត្តិធម៌ សមភាពយេនឌ័រ និងបរិយាប័នសង្គម។ | "Equity" សមធម៌ |
| មាត្រា ១២៧ | ដើម្បីធានាបាននូវភាពយុត្តិធម៌ និងបញ្ចៀសវិវាទដីធ្លីបន្ថែមទៀត ការបោះបង្គោលព្រំគួរតែរួមបញ្ចូលអ្នកពាក់ព័ន្ធទាំងអស់។ ដូចគ្នានេះដែរ អ្នកកាន់កាប់ដីទាំងអស់ រួមទាំងអ្នកកាន់សិទ្ធិតាមទំនៀមទម្លាប់ គួរតែជាភាគីនៃកិច្ចព្រមព្រៀងរវាងដីជាប់គ្នា។ | "ត្រូវតែអញ្ជើញអ្នកពាក់ព័ន្ធ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី យុវជន និងក្រុមងាយរងគ្រោះ..."<br><br>"អ្នកកាន់កាប់ដីជាប់គ្នា រួមទាំងអ្នកកាន់សិទ្ធិទំនៀមទម្លាប់" |
| មាត្រា ១២៩ | គួរតែផ្លាស់ប្តូរ "អាច" ទៅ "គួរតែ" ហើយផ្តល់ជូនថា "អ្នកពាក់ព័ន្ធទាំងអស់នឹងត្រូវបានអញ្ជើញឱ្យផ្តល់ចម្លើយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងទៀតសម្រាប់ការវិនិច្ឆ័យដីធ្លី ដោយយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី យុវជន និងក្រុមងាយរងគ្រោះ។ | "អ្នកពាក់ព័ន្ធទាំងអស់នឹងត្រូវបានអញ្ជើញឱ្យផ្តល់ចម្លើយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងទៀតដែលទាក់ទងនឹងការវិនិច្ឆ័យ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី យុវជន និងក្រុមងាយរងគ្រោះ"។ |
| មាត្រា ១៣០ | ការប្តឹងតវ៉ាអំពីវិការៈនៃនីតិវិធីចុះបញ្ជីដីធ្លី និងអំពីភាពមិនត្រឹមត្រូវនៃឯកសារនៃការវិនិច្ឆ័យ មិនត្រឹមតែជាសិទ្ធិទេ ប៉ុន្តែត្រូវជាកាតព្វកិច្ចផង ហើយអនុវត្តស្មើភាពគ្នាចំពោះបុគ្គលឯកជន សមូហភាព និងតំណាងរបស់អាជ្ញាធរសាធារណៈផង។ | សូមកែសម្រួល កថាខណ្ឌទី៤ នៃមាត្រានេះ តាមយោបល់សម្រាប់មាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ដើម្បីធានាបាននូវភាពត្រឹមត្រូវផ្នែកច្បាប់នៅកម្រិតសហគមន៍ សូមពិចារណាផងដែរ រួមទាំងឯកសារអប់រំជាមូលដ្ឋានដែលពន្យល់អំពីដំណើរការ និងសិទ្ធិបន្ថែមលើឯកសារវិនិច្ឆ័យ ក៏ដូចជាការផ្តល់ការផ្សព្វផ្សាយដែលផ្តោតជាពិសេសទៅលើស្ត្រី យុវជន និងក្រុមងាយរងគ្រោះ។ | |
| មាត្រា ១៣១ | គួរបង្កើនរយៈពលសម្រាប់ទុកឱ្យមន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យធ្វើការសម្រុះសម្រួលវិវាទ រហូតដល់ ៦០ ថ្ងៃប្រតិទិន ហើយចាំបាច់ត្រូវមានកំណត់ហេតុនៃការសម្រុះសម្រួល មុននឹងបញ្ជូនបណ្តឹងទៅគណៈកម្មការសុរិយោដី។<br><br>បន្ទាប់មក ដូចយោបល់ក្នុងមាត្រា ១១០ គួរចែងថា  គណៈកម្មសុរិយោដី ត្រូវដោះស្រាយឱ្យចប់សព្វគ្រប់តាំងពីថ្នាក់ក្រុងស្រុកខណ្ឌ ដល់ថ្នាក់ជាតិ លើកលែងតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់គូភាគីវិវាទ ក្នុងរយៈពេល ១៨០ ថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃទទួលបាននូវការបញ្ជូនពាក្យបណ្តឹងនោះ និងបើកសិទ្ធិដោយស្វ័យប្រវត្តឱ្យប្តឹងទាមទារទៅតុលាការមានសមត្ថកិច្ចពេលផុតរយៈពេលកំណត់នេះ។<br><br>សូមមើលយោបល់ក្នុងមាត្រា ៣៦ (អំពីក្រុមការងារពិសេសចាត់តាំងដោយក្រសួងទទួលបន្ទុកវិស័យសុរិយោដី  និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ) ផង។ | សូមកែសម្រួល តាមយោបល់សម្រាប់មាត្រានេះ។ |
| មាត្រា ១៣២ | កថាខណ្ឌចុងក្រោយនៃមាត្រានេះ គួរលើកមកដាក់មុនកថាខណ្ឌទី៥ ព្រោះក្រោយពីមានចុះបញ្ជី និងចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុរួចហើយ គណៈកម្មការសុរិយោដី លែងមានសមត្ថកិច្ចហើយ លើកលែងតែក្នុងករណីដូចបានលើកជាយោបល់ក្នុងមាត្រា ១១០។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៣៧ | វាមានតម្លៃក្នុងការរួមបញ្ចូលតម្រូវការដាក់លាក់ និងរួមបញ្ចូលបន្ថែមទៀតលើការផ្តល់សេចក្តីជូនដំណឹងជាសាធារណៈនៅទូទាំង ដើម្បីធានាថាសហគមន៍បានយល់ដឹង និងអាចដោះស្រាយការទាមទារដីធ្លីដែលមានជម្លោះ និងជៀសវាងជម្លោះបន្ថែមទៀត។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៤៥ | សូមមើលយោបល់ក្នុងមាត្រា ១។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ការចុះបញ្ជីដីទាំងអស់របស់សហគមន៍ជនជាតិដើមភាគតិចមួយជាកម្មសិទ្ធិសមូហភាពទៅក្នុងប្លង់តែមួយ ជាគោលការណ៍ល្អ ប៉ុន្តែគោលការណ៍នេះគួរអនុវត្តចំពោះតែករណីដីទាំងឡាយ ទាំងដីចំណែកឯកជន និងដីចំណែករួម ដែលសហគមន៍មួយអះអាងទាមទារ គ្មានវិវាទ ឬគ្មានការជំទាស់ ឬករណីមានវិវាទ ឬការជំទាស់ ត្រូវបានដោះស្រាយដោយការព្រមព្រៀងគ្នា ឬដោយសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ាក្នុងអំឡុងពេលមិនលើសពី ៣ ទៅ ៥ ឆ្នាំ ស្របតាមការការផ្តល់យោបល់ក្នុងមាត្រា ៣៦។<br>លើសពីនេះគួរអនុញ្ញាតឱ្យមានការចុះបញ្ជីដីរបស់សហគមន៍ដែលគ្មានវិវាទ ឬគ្មានជំទាស់ ទាំងអស់លើប្លង់រួមបឋម និងអនុញ្ញាតឱ្យមានការបញ្ចូលបន្ថែម ឬដកចេញពីប្លង់រួមវិញនូវដីដែលដោះស្រាយរួច ដីដែលសហគមន៍បានទិញ ទទួលអំណោយ ទទួលអច្ច័យទាន លទ្ធកម្មតាមអាជ្ញាយុកាលក្រោមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬដីដែលសហគមន៍ចែកឱ្យសមាជិកដែលត្រូវបានអនុញ្ញាតឱ្យចាកចេញពីសហគមន៍។ | |
| មាត្រា ១៤៦ | ស្របតាមយោបល់ក្នុងមាត្រា ២៥ គួរលុបចោលសញ្ញាណនៃដីឯកជនរបស់រដ្ឋ និងដីសាធារណៈរបស់រដ្ឋ ចេញពីរបបកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហើយដាក់ជំនួសវិញ ដោយសញ្ញាណនៃដីចំណែកឯកជន (ដីលំនៅឋាន ឬដីបានរៀបចំនិវេសនដ្ឋាន ដីប្រកបកសិកម្មដាំដុះដាក់ស្តែងជាដីស្រែ ឬចម្ការ រួមទាំងដីដែលបានប្រើប្រាស់ជូរវេនដំណាំ)  និងដីចំណែករួម (ដីបម្រុងចាំបាច់សម្រាប់ឆ្លើយតបតម្រូវការដីលំនៅដ្ឋាន និងដីដាំដុះចិញ្ចឹមសត្វ ក្នុងរយៈពេល ៥០ ឆ្នាំខាងមុខ ដែលមានមុខងារបច្ចុប្បន្នជាព្រៃសម្រាប់ទាញយកអនុផលព្រៃឈើ និងឈើសម្រាប់សង់លំនៅដ្ឋានបែបប្រពៃណីរបស់សមាជិកសហគមន៍ កន្លែងយកទឹក និងវាលស្មៅចិញ្ចឹមសត្វពាហនៈ ដែលត្រូវកាត់ឱ្យសហគមន៍ ដីព្រៃអារក្ស និង ដីកប់សព ក្នុងទំហំសមស្រប និងស្ថានភាពជាក់ស្តែង) នៃកម្មសិទ្ធិសមូហភាពរបស់សហគមន៍។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
| --- | --- | --- |
| | ហើយស្របតាមយោបល់ក្នុងមាត្រា ៣៦ ដីរបស់សហគមន៍ជនជាតិដើមភាគតិច មិនចាំបាច់តម្រូវឱ្យមានការទទួលស្គាល់ដោយអាជ្ញាធរដែនដី និងមិនគួរត្រូវបានកម្រិតដោយព្រំប្រទល់រដ្ឋបាលឃុំសង្កាត់ ក្រុងស្រុកខណ្ឌ ឬ ខេត្តឡើយ ប៉ុន្តែអាចតម្រូវឱ្យឋិតក្នុងតំបន់ភូមិសាស្ត្រប្រមូលផ្តុំ ឬតំបន់រណបសមស្របដែលអាចធ្វើដំណើរទៅមកពីចំណុចកណ្តាលនៃសហគមន៍ដោយថ្មើរជើងក្នុងកន្លះថ្ងៃបាន។<br><br>សមាសភាពនៃកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគួរតែរួមបញ្ចូលដីដែលប្រើប្រាស់សម្រាប់ទម្រង់កសិកម្មណាមួយ មិនមែនត្រឹមតែកសិកម្មដែលធ្វើឡើងតាម រយៈការអនុវត្តប្រពៃណីប៉ុណ្ណោះទេ។ នេះនឹងលុបបំបាត់ដែនកំណត់ណាមួយលើសហគមន៍ដែលចង់ទទួលយកបច្ចេកវិទ្យានិងបច្ចេកទេសកសិកម្មទំនើប។ លើសពីនេះ ដីដែលបានចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មិនត្រូវចាត់ទុកជាដីរបស់រដ្ឋទៀតទេ ដើម្បីឱ្យសហគមន៍ជនជាតិដើមភាគតិចដែលកាន់កាប់ប័ណ្ណកម្មសិទ្ធិអាចប្រើប្រាស់សិទ្ធិកាន់កាប់ដោយស្របច្បាប់ ដើម្បីការពារដីរបស់ពួកគេ និងប្រើប្រាស់ដីឱ្យបានល្អបំផុត។ ហើយអាចស្ថិតនៅក្រោមអាណាព្យាបាលនៃស្ថាប័នរដ្ឋដែលបានកំណត់ (ឧ. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ) សម្រាប់ទង្វើនៃការផ្តាច់មុខ ការលក់ ការផ្លាស់ប្តូរ ឬផ្ទេរកម្មសិទ្ធិយ៉ាងច្បាស់លាស់ទៅ/ជាមួយបុគ្គល/អង្គភាពណាមួយនៅខាងក្រៅសហគមន៍ជនជាតិដើមភាគតិច។ | |
| មាត្រា ១៤៧ | ស្របតាមយោបល់ក្នុងមាត្រា ៤០ មិនគួរមានការបង្កើតគំរូបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិចឡើយ ប៉ុន្តែតាមសំណើរបស់សហគមន៍មួយៗ ក្រសួងទទួលបន្ទុកគ្រប់គ្រងវិស័យសុរិយោដី ដោយសហការជាមួយ ក្រសួងមហាផ្ទៃ ឬនិងដៃគូអភិវឌ្ឍ អាចជួយផ្តល់យោបល់ និងជំនួយបច្ចេកទេសហិរញ្ញវត្ថុ ឧបករណ៍ ការប្រើគ្រាមភាសារបស់ជនជាតិ និងភាសាខ្មែរ ក្នុងការចងក្រងនូវវិធានប្រពៃណីដែលមានលក្ខណៈជាបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍តាមការកំណត់របស់អាជ្ញាធរប្រពៃណី ឬគណៈកម្មការប្រពៃណីរបស់សហគមន៍នោះ។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។<br><br>"នៃរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្របតាមការការពាររដ្ឋធម្មនុញ្ញសម្រាប់សមភាពយេនឌ័រ និងទំនៀមទម្លាប់ជនជាតិដើមភាគតិច"។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | សហគមន៍ជនជាតិដើមភាគតិច មិនមែនរដ្ឋាភិបាលទេ គួរតែទទួលខុសត្រូវក្នុងការកំណត់ និងអនុវត្តវិធានផ្ទៃក្នុង ជាភាសារបស់ពួកគេផ្ទាល់ និង/ឬភាសាខ្មែរ ជាលាយលក្ខណ៍អក្សរ ឬការថតសំឡេងតាមជម្រើសរបស់ពួកគេ។ ចំពោះវិសាលភាពដែលរដ្ឋាភិបាលចាំបាច់ត្រូវចូលរួមក្នុងការបង្កើតគំរូបទប្បញ្ញត្តិផ្ទៃក្នុង វាគួរតែត្រូវបានចែងថា គោលការណ៍សំខាន់គឺជានាសមធម៌យេនឌ័រ និងការរួមបញ្ចូលសង្គមនៅក្នុងបទប្បញ្ញត្តិផ្ទៃក្នុង។ | |
| មាត្រា ១៤៨ | គួរកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រា ៣៦។<br><br>ពង្រឹងវិធានការការពារបណ្តោះអាសន្នសម្រាប់ដីដែលទាមទារដោយសហគមន៍ជនជាតិដើមភាគតិច ឬក្រុម ដោយមិនគិតពីស្ថានភាពនៃការបង្កើតជាភាពស្របច្បាប់មុន និងពីការចាប់ផ្តើមដំណើរការពាក្យសុំ ICLT ការការពារដីពីការទាមទារឬការចេញ ឬ/និងប្រតិបត្តិការរបស់សម្បទានណាមួយ មិនថាសម្បទានដី សម្បទានរុករក/ធ្វើអាជីវកម្មរ៉ែ សម្បទានវារីអគ្គិសនី ការអភិវឌ្ឍន៍ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឬទម្រង់សម្បទានផ្សេងទៀត រហូតដល់ការទាមទាររបស់ជនជាតិដើមភាគតិចត្រូវបានវាយតម្លៃ និងដោះស្រាយ។ រៀបចំផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច ក្នុងការទាមទារសំណងទៅតុលាការ ប្រសិនបើអាជ្ញាធរពាក់ព័ន្ធខកខានក្នុងការការពារដីសហគមន៍ជនជាតិដើមភាគតិចដែលបានកំណត់អំឡុងពេលការពារបណ្តោះអាសន្ន ក៏ដូចជាដំណើរការស្នើសុំការផ្តល់កម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច។<br><br>ផ្តល់អាណត្តិច្បាស់លាស់សម្រាប់ក្រសួងទទួលបន្ទុករដ្ឋបាលសុរិយោដី ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងធនធានដល់សហគមន៍ជនជាតិដើមភាគតិច ដើម្បីជួយរៀបចំផែនទីនៃទ្រព្យសម្បត្តិសមូហភាពរបស់ពួកគេ។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| មាត្រា ១៤៩ | ក្នុងការអនុវត្តកថាខណ្ឌទី២ នៃមាត្រានេះ គួរចែងឱ្យរាជរដ្ឋាភិបាល ត្រូវគោរពគោលការណ៍ដែលបានផ្តល់យោបល់ក្នុងមាត្រា ២០ មាត្រា ២៩ និងមាត្រា ៣០។<br>សូមមើលយោបល់ក្នុងមាត្រា ១២២ ផង។ | សូមចែងបញ្ជាក់ឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៥០ | រយៈពេលកំណត់ក្នុងកថាខណ្ឌទី៣នៃមាត្រានេះ គួរតម្លើងរហូតដល់ ៣០ ថ្ងៃប្រតិទិនគិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ ករណីដែលម្ចាស់អចលនវត្ថុ ឬតំណាងរបស់ម្ចាស់អចលនវត្ថុ ស្នាក់នៅ ឬរស់នៅក្នុងប្រទេសកម្ពុជា និងតម្លើយរហូតដល់ ៦០ ថ្ងៃប្រតិទិនថ្ងៃប្រតិទិនគិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ ករណីដែលម្ចាស់អចលនវត្ថុ ឬតំណាងរបស់ម្ចាស់អចលនវត្ថុ ស្នាក់នៅ ឬរស់នៅក្រៅប្រទេស កម្ពុជា។<br><br>គួរមានការកំណត់លម្អិតអំពីបែបបទ និងនីតិវិធីនៃការប្រគល់ ឬនិងការចុះផ្សាយលិខិតបង្គាប់ ដែលមានការបញ្ជាក់ច្បាស់លាស់អំពីគោលបំណង មូលហេតុ និងមូលដ្ឋានគតិយុត្ត ហើយផ្តល់ឱកាសឱ្យតវ៉ាជំទាស់ចំពោះបង្គាប់នោះ រួមទាំងសិទ្ធិប្តឹងតវ៉ាទៅតុលាការ។<br><br>គួរមានចែងអំពីនីតិវិធីចុះបញ្ជីលើកដំបូងលើក្បាលដីដែលមិនត្រូវបានវាស់វែង ឬមិនត្រូវបានចេញវិញ្ញាបនបត្រសំគាល់ម្ចាស់ក្នុងដំណើរការអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (ការចុះបញ្ជីលើកដំបូងបំពេញបន្ថែម) ដោយសារហេតុផលមានវិវាទ ឬការតវ៉ាជំទាស់ដោះស្រាយមិនទាន់ចប់ជាស្ថាពរ ផង។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៥២ | ក្នុងការអនុវត្តកថាខណ្ឌទី២ នៃមាត្រានេះ គួរចែងឱ្យកសួងទទួលបន្ទុកវិស័យសុរិយោដី ត្រូវគោរពគោលការណ៍ដែលបានផ្តល់យោបល់ក្នុងមាត្រា ២០ មាត្រា ២៩ មាត្រា ៣០ និងមាត្រា ១៥០។<br><br>សូមមើលយោបល់ក្នុងមាត្រា ១២២ ផង។ | សូមចែងបញ្ជាក់ឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| | ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលការណ៍នៃការធានារបស់រដ្ឋអំពីកម្មសិទ្ធិ (រួមទាំងសិទ្ធិពិតប្រាកដស្របច្បាប់ផ្សេងទៀត) ច្បាប់គួរតែផ្តល់ការទទួលខុសត្រូវ ប្រសិនបើទង្វើ ឬការសម្រេចចិត្តរបស់រដ្ឋបាលសុរិយោដី (និងភ្នាក់ងារដែលធ្វើសកម្មភាពជំនួសខ្លួន) រដ្ឋាភិបាល និងស្ថាប័នរដ្ឋ (ដូចជា ក្រសួងទទួលបន្ទុករដ្ឋបាលសុរិយោដី) ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់តតិយជនស្លូតត្រង់ ដែលពឹងផ្អែកទាំងស្រុងលើព័ត៌មានដែលបានកត់ត្រាក្នុងបញ្ជីដីធ្លី និង/ឬផ្តល់នៅក្នុងព័ត៌មាន/វិញ្ញាបនបត្រសុរិយោដីដែលទទួលបានពីរដ្ឋបាលសុរិយោដី។ នៅពេលដែលរដ្ឋអនុវត្តសិទ្ធិដកហូតកម្មសិទ្ធិឯកជន រដ្ឋត្រូវចាប់ផ្តើម និងចំណាយលើការចំណាយ និងការចំណាយពាក់ព័ន្ធទាំងអស់សម្រាប់ការកែតម្រូវក្បាលដីដែលរងផលប៉ះពាល់ដោយសកម្មភាពនៃការទទួលយក/ការដកហូតរបស់រដ្ឋ និងការចុះបញ្ជីជាបន្តបន្ទាប់នៃការផ្លាស់ប្តូរក្បាលដី។ | |
| មាត្រា ១៥៦ | ក្នុងកថាខណ្ឌចុងក្រោយនៃមាត្រានេះ គួរបន្ថែមពាក្យថា "ច្រើន" បន្ទាប់ពីឃ្លាថា "ក្នុងករណីដែលមានការស្នើសុំចុះបញ្ជី" ។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៦៥ | ដោយសារមានផ្នែកពេញលេញអំពីសហកម្មសិទ្ធិ អ្នកព្រាងគួរតែពិចារណាបន្ថែមនូវបទប្បញ្ញត្តិស្តីពីកម្មសិទ្ធិសហកម្មសិទ្ធិរួមទៅផ្នែកនោះ។ វានឹងបញ្ជាក់អំពីរបបកម្មសិទ្ធិអាពាហ៍ពិពាហ៍ និងធានាឱ្យបាននូវការយល់ដឹងកាន់តែខ្លាំងអំពីឥទ្ធិពលរបស់ច្បាប់លើកម្មសិទ្ធិគ្រួសារ។ ឯកសារយោងទៅក្រមរដ្ឋប្បវេណីក៏អាចសមរម្យ និងមានប្រយោជន៍ផងដែរ។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៧៨ និង មាត្រា ១៧៩ | គួរកំណត់អំឡុងពេលគិតពីថ្ងៃទទួលបានការជូនដំណឹងរបស់រដ្ឋបាលសុរិយោដី ឬកាលបរិច្ឆេទនៃការចុះផ្សាយសេចក្តីជូនដំណឹងរបស់រដ្ឋបាលសុរិយោដី តាមបែបបទកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកគ្រប់គ្រងវិស័យសុរិយោដី។<br>សូមមើលយោបល់ក្នុងមាត្រា ១២២ ផង។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៨០ | ពិចារណារួមបញ្ចូលការយោងទៅរបបទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍របស់ក្រមរដ្ឋប្បវេណីនៅក្នុងកថាខណ្ឌទី១ ដើម្បីបញ្ជាក់ពីសិទ្ធិកម្មសិទ្ធិប្តីប្រពន្ធ។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |

| មាត្រា | យោបល់ និងហេតុផល | សំណើកែលំអ |
|---|---|---|
| មាត្រា ១៨២ | ពិចារណាបញ្ចូលសេចក្ដីយោងទៅក្រមរដ្ឋប្បវេណី ដើម្បីបញ្ជាក់កថាខណ្ឌទី៤។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់ក្នុងមាត្រានេះ។ |
| មាត្រា ១៩៧ | តើអ្នកដែលមិនយល់ស្របនឹងការសម្រេចរបស់ក្រសួងអាចប្ដឹងទៅតុលាការបានទេ? | |
| សទ្ទានុក្រម | តើអ្នកដែលមិនយល់ស្របនឹងការសម្រេចរបស់ក្រសួងអាចប្ដឹងទៅតុលាការបានទេ?<br><br>សទ្ទានុក្រមគួរតែត្រូវបានពិនិត្យបន្ទាប់ពីបញ្ចប់អត្ថបទនៃច្បាប់ ដើម្បីធានាបាននូវភាពពេញលេញ ភាពពាក់ព័ន្ធ (លក្ខខណ្ឌបច្ចុប្បន្នជាច្រើនមិនត្រូវបានរាប់បញ្ចូលក្នុងសេចក្ដីព្រាងច្បាប់បច្ចុប្បន្ន) និងភាពស្មោះត្រង់ចំពោះលក្ខខណ្ឌ។ វាក៏គួរត្រូវបានផ្លាស់ប្ដូរទៅផ្នែកមួយដែលលេចធ្លោជាងនេះទៀតនៃច្បាប់។ | សូមកែសម្រួលមាត្រានេះឱ្យស្របតាមយោបល់នេះ។ |